សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ប្រព័ន្ធវិមជ្ឈការនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០២ ដល់ ឆ្នាំ២០២០

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **ខណ្ណា ម៉ូហាំម៉ាត់រិទ្ធដាខាន**

: **ឡោ គីមប៉**

សាស្ត្រាចារ្យណែនាំ

**លោក យូ តូនី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ចណ្ណា ម៉ូហាំម៉ាត់រិទ្ធជាខាន** និង **ឡោ គីមប៉** ជានិស្សិតឆ្នាំទី៤ ថ្នាក់ **L4A6** បរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់២១ ឆ្នាំសិក្សា ២០២០-២០២១ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

សូមគោរពប្រណិប័តន៍ និងសូមសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះ ៖
លោកឪពុក អ្នកម្តាយ ដែលលោកទាំងពីរបានចិញ្ចឹមបីបាច់ថែរក្សាកូន និងអប់រំប្រៀនប្រដៅកូនតាំងពីតូចរហូតដល់ធំដឹងក្តី ប្រកបដោយព្រហ្មវិហារធម៌ ចេះគោរពចាស់ទុំ ពន្យល់ណែនាំឲ្យកូនប្រព្រឹត្តតែអំពីល្អ និងឲ្យកូនខិតខំសិក្សារៀនសូត្រ។ ដើម្បីឲ្យកូនក្លាយទៅជាកូនល្អ សិស្សល្អ ក៏ដូចជាពលរដ្ឋល្អនៅក្នុងសង្គម ។
យើងខ្ញុំក៏សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះ៖

- ឯកឧត្តម បណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសឲ្យពួកខ្ញុំបាទបានរៀន ក្រេបយកចំណេះវិជ្ជា និង បង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់ខ្ញុំកន្លងមក ។
- ជាពិសេសលោកសាស្ត្រាចារ្យ លោកគ្រូ **ឃូ តូនី** ដែលជាសាស្ត្រាចារ្យណែនាំដែល គាត់បានផ្តល់ដំបូន្មានល្អៗ និងចំណាយពេលវេលាក្នុងការកែសម្រួលរបាយការណ៍មួយនេះ ឲ្យលេចចេញជារូបរាងឡើង ។
- សូមសម្តែងការដឹងគុណ យ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកនិពន្ធ និងរៀមច្បងផងដែរដោយគាត់បានបន្សល់ទុកនូវឯកសារស្រាវជ្រាវ ដែលធ្វើឲ្យយើងខ្ញុំបាទមានការងាយស្រួលក្នុងការយកមកសិក្សាស្រាវជ្រាវ និងបំពេញបន្ថែមក្នុងកិច្ចការស្រាវជ្រាវនេះ។

ជាចុងបញ្ចប់ សូមមេត្តាទទួលនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត និងមិនអាចបំភ្លេចបានពីយើងខ្ញុំ ។ យើងខ្ញុំក៏សូមប្រសិទ្ធិពរជ័យសិរិមង្គលជូនដល់ លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ សូមប្រកបតែជោគជ័យគ្រប់ភារកិច្ច និង សម្រេចបាននូវ ពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

បន្ទាប់ពីធ្វើការសិក្សាយ៉ាងលម្អិតអស់រយៈពេល៤ឆ្នាំឯកទេសនីតិសាស្ត្រ ក្រោមការបង្ហាត់ បង្រៀន និងយកចិត្តទុកដាក់ពីសំណាក់លោក-លោកស្រី សាស្ត្រាចារ្យ បណ្ឌិត ទាំងអស់ដែលមានវត្តមាន នៅក្នុងការណែនាំរបាយការណ៍ដែលពួកខ្ញុំបាទបានសរសេរ និងជាឆ្នាំចុងក្រោយដែល ត្រូវឈានជើងចេញពីសាកលវិទ្យាល័យនាពេលខាងមុខនេះ។ ដើម្បីជាការឆ្លើយតប និងតម្រូវការរបស់សាកលវិទ្យាល័យ និងដើម្បីធ្វើការស្វែងយល់បន្ថែម ពួកខ្ញុំបាទបានធ្វើការស្រាវ ជ្រាវលើប្រធានបទដែលមានកម្មវត្ថុស្ដីពី " **ប្រព័ន្ធវិមជ្ឈការនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០២ ដល់ ឆ្នាំ២០២០** " ក្រោមការដឹកនាំ និងកែសម្រួលយ៉ាងយកចិត្តទុកដាក់ជាទីបំផុតពីសំណាក់ លោក សាស្ត្រាចារ្យណែនាំ **ឃូ តូនី** ដែលជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

ហេតុដែលពួកយើងខ្ញុំបាទធ្វើការជ្រើសរើសប្រធានបទមួយនេះយកមកធ្វើការស្រាវជ្រាវ ដោយសារតែពួកខ្ញុំបាទផ្ទាល់មានគោលបំណងចង់ធ្វើការស្វែងយល់ឲ្យកាន់តែយល់ដឹងច្បាស់អំពី ប្រព័ន្ធវិមជ្ឈការដែលបង្កើតឲ្យមានក្រុមប្រឹក្សាឃុំ សង្កាត់ រាជធានី ស្រុក ខណ្ឌ ដោយមានការគ្រប់គ្រងយ៉ាងច្បាស់លាស់ដែលមានច្បាប់ចែង នឹងគ្រប់គ្រងយ៉ាងត្រឹមត្រូវច្បាស់លាស់។

ពួកយើងខ្ញុំបាទមានជំនឿជាក់ថា របាយការណ៍មួយនេះប្រាកដជាមានចំណុចខ្វះខាត កំហុសឆ្គងពាក្យពេជន៍ និង អត្ថន័យមួយចំនួនជាក់ជាមិនខាន ។ ដូច្នេះពួកយើងខ្ញុំមានសេចក្ដីសោមនស្សរីករាយនិងទទួលរាល់មតិរិះគន់នានាក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់គ្នាសូមអរគុណ ។

# មាតិកា

**ទំព័រ**

## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ០១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ០១

៣.គោលបំណងនៃការស្រាវជ្រាវ ........ ០២

៤. ដែនកំណត់នៃការស្រាវជ្រាវ ........ ០២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ០២

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ០២

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ០៣


## ជំពូកទី១

## ប្រព័ន្ធវិមជ្ឈការ


១.១ និយមន័យនៃវិមជ្ឈការ ........ ០៤

១.២ ប្រភេទនៃវិមជ្ឈការ ........ ០៦

១.២.១ វិមជ្ឈការបច្ចេកទេស ........ ០៧

១.២.២ វិមជ្ឈការដែនដី ........ ០៧

១.៣ គោលបំណងនៃការធ្វើវិមជ្ឈការ ........ ០៧

១.៤ វិមជ្ឈការនៅកម្ពុជានាពេលបច្ចុប្បន្ន ........ ០៨

១.៤.១ រដ្ឋបាលឃុំ សង្កាត់ ........ ០៩

១.៤.២ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ........ ០៩

១.៥ ទំហំនៃវិមជ្ឈការដែលរៀបចំនៅកម្ពុជា ........ ១០


## ជំពូកទី២

## មែកធាង និងទិសដៅនៃប្រព័ន្ធវិមជ្ឈការ


២.១ វិមជ្ឈការនយោបាយ ........ ១២

២.២ វិមជ្ឈការរដ្ឋបាល ........ ១៣

២.២.១ វិសហមជ្ឈការ ........ ១៤

២.២.២ ការប្រគល់អំណាចប្រតិភូកម្ម ........ ១៤

២.៣ វិមជ្ឈការសារពើពន្ធ ..................................................... ១៥
២.៤ វិមជ្ឈការសេដ្ឋកិច្ច ឬ ទីផ្សារ ..................................................... ១៥
២.៥ ទិសដៅនៃវិមជ្ឈការ ..................................................... ១៦
  ២.៥.១ ការផ្ដល់ឱកាសឲ្យប្រជាពលរដ្ឋចូលរួមពេញលេញ ..................................................... ១៦
  ២.៥.២ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃការរស់នៅ ..................................................... ១៧

## ជំពូកទី៣

## គុណសម្បត្តិ បញ្ហាប្រឈម និងកំណែទម្រង់

៣.១ គុណសម្បត្តិនៃប្រព័ន្ធវិមជ្ឈការ ..................................................... ១៨
៣.២ បញ្ហាប្រឈម..................................................... ១៩
  ៣.២.១ ប្រព័ន្ធនៃការទទួលខុសត្រូវ និង តម្លាភាព ..................................................... ១៩
  ៣.១.២ ការចូលរួម និងសង្គមស៊ីវិល..................................................... ២០
  ៣.១.៣ ការរៀបចំចាត់ចែងសារពើពន្ធ ..................................................... ២០
  ៣.១.៤ ប្រភពចំណូលរបស់ ឃុំ សង្កាត់..................................................... ២១
  - ចំណូលមូលនិធិ ឃុំ សង្កាត់ ..................................................... ២១
  - ចំណូលផ្ទាល់ ឃុំ សង្កាត់ ..................................................... ២២
  - ចំណូលមុខងារជាភ្នាក់ងារ ..................................................... ២២
៣.៣ កំណែទម្រង់..................................................... ២៣
**សេចក្ដីសន្និដ្ឋាន**..................................................... ២៧
**អនុសាសន៍**..................................................... ២៩
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បណ្តាលប្រទេសជាច្រើននៅលើសកលលោកពួកគេបានបង្កើត និងរៀបចំរដ្ឋបាលរបស់ខ្លួនធ្វើយ៉ាងណាប្រកបដោយភាពងាយស្រួលក្នុងការគ្រប់គ្រងនិងដឹកនាំ ។ ជាក់ស្តែងប្រទេសកម្ពុជាចាប់តាំងពីច្បាប់កំពូលរបស់យើងពោលគឺ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានបង្កើតនឹងផ្លាស់ប្តូរកែប្រែកន្លងមក រួមទាំងសេដ្ឋកិច្ចក្តី និងរបបនយោបាយនៃការគ្រប់គ្រងប្រទេសទៀតសោកកត្តាទាំងនោះហើយទើបធ្វើឲ្យរដ្ឋបាលនៃប្រទេសកម្ពុជាយើង មានការផ្លាស់ប្តូរប្រព័ន្ធនៃការគ្រប់គ្រងតាមរយៈការធ្វើកំណែទម្រង់ពីដំណាក់ការមួយទៅដំណាក់កាលមួយទៀតដើម្បីឲ្យឆ្លើយតបទៅ នឹងតម្រូវការរបស់សង្គមជាតិទាំងមូលឲ្យបានសមស្របទៅនឹងស្ថានភាពឬបរិបទជាក់ស្តែង ។

ទន្ទឹមនឹងនេះផងដែរ វិមជ្ឈការ ក៏ត្រូវបាន រដ្ឋតាមបណ្តាប្រទេសជាច្រើននៅលើសកលលោកយើងនេះបានយកមកអនុវត្តដើម្បីឲ្យ ប្រើប្រាស់ជាមធ្យោបាយ នៃការគ្រប់គ្រងប្រព័ន្ធរដ្ឋបាល របស់ពួកគេយ៉ាងមានប្រសិទ្ធភាព នឹងមានភាពងាយស្រួលទៅតាមមូលដ្ឋាននីមួយៗ ទាំងនេះក្តីក៏ជាយន្តការនៃការកាត់បន្ថយភាពក្រីក្រ និងជាការផ្តល់នូវក្របខណ្ឌនៃការគ្រប់គ្រងការងារឲ្យ ទទួលបាននូវប្រសិទ្ធភាព និងភាពល្អប្រសើរឡើងតាមរយៈការអនុវត្តប្រព័ន្ធគ្រប់គ្រងតាមបែបនយោបាយវិមជ្ឈការ ។

ស្របទៅតាមបរិបទនៃស្ថានការណ៍ជាក់ស្តែងនៃរបបសង្គមរបស់ ព្រះរាជាណាចក្រកម្ពុជាជាប្រទេសមួយដែលកំពុងអនុវត្តនូវនយោបាយវិមជ្ឈការរបស់ខ្លួន និង មានការធ្វើកំណែទម្រង់ជាបណ្តើរៗដើម្បីឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិដោយការចូលរួមពីគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធ ។ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានសិទ្ធិឈរឈ្មោះនិង បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់ខ្លួនហើយប្រជាពលរដ្ឋក៏មានសិទ្ធិផង ដែរក្នុងការចូលរួម ដើម្បីធ្វើការសម្រេចចិត្តនានា និងបង្ហាញពីសេចក្តីត្រូវការរបស់ខ្លួនដែលនេះជាការឆ្លើយតបដែលមានតម្លាភាព និងការទទួលខុសត្រូវរបស់អ្នកដឹកនាំនៅក្នុង ថ្នាក់មូលដ្ឋានប្រយោជន៍ដើម្បីកែលម្អប្រសិទ្ធភាព និងភាពជោគ ជ័យនៃការងាររបស់រដ្ឋាភិបាលផងដែរ ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ចំណោទបញ្ហានៃប្រធានបទខាងលើមានដូចជា ៖

- ហេតុអ្វីចាំបាច់ត្រូវមាន វិមជ្ឈការ ?
- តើការគ្រប់គ្រងរដ្ឋបាលបែបប្រព័ន្ធវិមជ្ឈការមានអត្ថៈប្រយោជន៍ គុណសម្បត្តិ នឹង គុណវិបត្តិដល់ថ្នាក់មូលដ្ឋានដូចម្តេចខ្លះ ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានវិសាលភាពផ្តោតសំខាន់ទៅលើប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលទៅតាមមូលដ្ឋានរបស់ខ្លួនដោយផ្អែកលើការអនុវត្តតាមបែបនយោបាយវិមជ្ឈការ និង ការធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រសិទ្ធភាពនៃការផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។ គោលបំណងចម្បងនៃការស្រាវជ្រាវនេះ គឺផ្តោតទៅលើគោលបំណងសំខាន់ៗគឺៈ

- ទិដ្ឋភាពសំខាន់ៗនៅក្នុងប្រព័ន្ធវិមជ្ឈការ
- គោលបំណងនៃការអនុវត្តនូវនយោបាយវិមជ្ឈការ
- មែកធាង និងទិសដៅនៃប្រព័ន្ធវិមជ្ឈការ
- លក្ខណៈចរិត នឹង បញ្ហាប្រឈមមុខនៃការអនុវត្តទម្រង់ប្រព័ន្ធវិមជ្ឈការ

ការស្រាវជ្រាវនេះផងដែរ គឺធ្វើការវិភាគទៅលើចំណុចទាំងឡាយ ដើម្បីស្វែកចំណុចខ្វះខាតដែលត្រូវកែលម្អ ព្រមទាំងធ្វើសេចក្តីសន្និដ្ឋានទៅលើគ្រប់ចំណុច និង ផ្តល់ជាអនុសាសន៍ទៅលើចំណុចកែលម្អ ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះ មានវិសាលភាពផ្តោតសំខាន់ទៅលើប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់មូលដ្ឋានឃុំ សង្កាត់ ដែលប្រកបដោយភាពងាយស្រួល, ល្អប្រសើរ និង តម្លាភាពដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និង សង្គមជាតិទាំងមូលដើម្បីឈានទៅរកការអភិវឌ្ឍឲ្យបានល្អប្រសើរទៅតាមមណ្ឌលមូលដ្ឋានរបស់ខ្លួន ។ រួមទាំងកំណត់ឲ្យបាននូវ គោលបំណង, ទំហំនៃការរៀបចំ, និងលក្ខណៈសំខាន់ៗនៃប្រព័ន្ធវិមជ្ឈការដែលជាតំរូវការនឹងកំពុងប្រើប្រាស់នៅព្រះរាជាណាចក្រកម្ពុជាយើងនាពេលបច្ចុប្បន្ន ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

នយោបាយវិមជ្ឈការជាប្រព័ន្ធនៃការគ្រប់គ្រងមួយក្នុងការផ្តល់នូវសិទ្ធិ អំណាច និង ការផ្តល់ធនធានមួយចំនួនឲ្យដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តសកម្មភាពបម្រើផលប្រយោជន៍ប្រជាពលរដ្ឋកាន់តែប្រសើរ និងក្នុងការកំណែទម្រង់ជាបណ្តើរតាមស្ថានភាពមួយនៃបរិបទសង្គម និង ការកំណត់ដោយគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ការផ្តល់សិទ្ធិ អំណាច និងធនធានជាគោលការណ៍ចម្បង គឺដើម្បីឲ្យក្រុមប្រឹក្សាឃុំ ក្លាយជានីតិបុគ្គល តាមរយៈនយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងមហាផ្ទៃ និង អន្តរក្រសួងផងដែរ ។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ដើម្បីប្រមូលពត៌មាន យកមកធ្វើការចងក្រងជារបាយការណ៍នៃកិច្ចការស្រាវជ្រាវនេះឲ្យបានល្អ គឺមានការធ្វើសកម្មភាពស្រាវជ្រាវដូចជា ៖

- នៅបណ្ណាល័យ
- ដកស្រងចេញពីសៀវភៅខ្លះដែលពាក់ព័ន្ធនឹងប្រធានបទ
- តាមចំណេះដឹងខ្ញុំដែលបានសិក្សាកន្លងមកពីសាស្ត្រាចារ្យ
- ដកស្រង់ចេញពីប្រសាសន៍របស់សាស្ត្រាចារ្យ

## ៧. រចនាសម្ពន្ធនៃការសិក្សាស្រាវជ្រាវ

ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពក្នុងការស្រាវជ្រាវរបាយការណ៍នេះ ចាំបាច់ត្រូវមានការបែងចែកនូវរចនាសម្ពន្ធឲ្យច្បាស់លាស់ ដែលមាន៣ជំពូកសំខាន់ៗដូចជា៖

- **ជំពូកទី១៖ ប្រព័ន្ធវិមជ្ឈការ** នៅក្នុងជំពូកនេះយើងខ្ញុំ នឹងធ្វើការបងស្រាយពីនិយមមន័យ ប្រភេទនឹងគោលបំណងនៃការធ្វើវិមជ្ឈការ ព្រមទាំងវិមជ្ឈការនៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ននិងទំហំនៃវិមជ្ឈការដែលការរៀបចំនៅកម្ពុជា។
- **ជំពូកទី២៖ មែកធាង និងទិសដៅនៃប្រព័ន្ធវិមជ្ឈការ** សម្រាប់ជំពូកនេះវិញ ពួកយើងនឹងធ្វើការរៀបរាប់ពីមែកធាងនៃប្រព័ន្ធវិមជ្ឈការ មានទិដៅយ៉ាងដូចម្ដេចខ្លះ។
- **ជំពូកទី៣៖ គុណសម្បត្តិ បញ្ហាប្រឈម និងកំណែទម្រង់** រីឯជំពូកនេះដែលជាជំពូកចុងក្រោយ ពួកយើងនឹងធ្វើការ បកស្រាយប្រព័ន្ធវិមជ្ឈការមាន គុណសម្បត្តិ បញ្ហាប្រឈម និងមានកំណែទម្រង់បែបណាខ្លះ។
- **សេចក្តីសន្និដ្ឋាន**
- **អនុសាសន៍**
- **គន្ថនិទ្ទេស**

# ជំពូកទី១
# ប្រព័ន្ធវិមជ្ឈការ

## ១.១. និយមន័យនៃវិមជ្ឈការ

វិមជ្ឈការជារចនាសម្ពន្ធរដ្ឋបាលមួយដែលត្រូវបានរៀបចំឡើងជា នីតិបុគ្គលសាធារណៈ។ នីតិបុគ្គលនេះអាចជាសមូហភាពដែនដី ដែលគេហៅថា ការរៀបចំរចនាសម្ពន្ធរដ្ឋបាលវិមជ្ឈការដែនដី និង អាចជាអង្គការស្វយ័តនៃការ គ្រប់គ្រងសេវាសាធារណៈប្រកបដោយឯកទេសកម្មដែលគេហៅថា ការរៀបចំរចនាសម្ពន្ធរដ្ឋបាលវិមជ្ឈការបច្ចេកទេស ឬសេវា ។

ការធ្វើវិមជ្ឈការនៃការគ្រប់គ្រងរដ្ឋបាល គឺសំដៅដល់ការសម្តែងឡើងពី សេរីភាវូបនីយកម្ម ដែលអនុញ្ញាឲ្យមានការចូលរួមពីសំណាក់អ្នកដែលពាក់ព័ន្ធទាំងឡាយដែលស្ថិតនៅក្នុងការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលសាធារណៈ ។

ប្រព័ន្ធវិមជ្ឈការ គឺ ជាប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមួយ ដែលអាជ្ញាធររដ្ឋបាលកណ្តាលទទួលស្គាល់នូវសិទ្ធិអំណាចក្នុងការសម្រេចរបស់អាជ្ញាធររដ្ឋបាលមូលដ្ឋានដោយមាន ចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នានា ។ ម្យ៉ាងមួយវិញទៀតយើងអាចនិយាយបានថា គឺជាទម្រង់នៃការរៀបចំរបស់អំណាចនីតិប្រតិបត្តិរបស់រដ្ឋដោយ បានធ្វើការទទួលស្គាល់សមូហភាពដែនដីជា នីតិបុគ្គលសាធារណៈផ្សេងទៀត ដែលមានអំណាចនៅក្នុងការ សម្រេចនូវរាល់កិច្ចការទាំងឡាយណាដែល ជាអត្ថៈប្រយោជន៍រួមរបស់ប្រជារាស្ត្រ រស់នៅក្នុងសមូហភាពនោះបាន។

វិមជ្ឈការ គឺមានន័យថា សិទ្ធិ អំណាច ការទទួលខុសត្រូវ និងធនធានមួយចំនួន ត្រូវបានផ្ទេរពីរាជរដ្ឋាភិបាលថ្នាក់ជាតិ(ថ្នាក់កណ្តាល) ទៅក្រុមប្រឹក្សាឃុំសង្កាត់ដែលបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ ឬ តាមលក្ខណៈប្រជាធិបតេយ្យ។[1] ប្រសិនបើ រដ្ឋមិនអាចប្រមូលផ្តុំអំណាចរដ្ឋបាលតែម្នាក់ឯងបាន ហើយទទួលស្គាល់សមូលភាពផ្សេងទៀត មានអំណាចរដ្ឋបានសម្រេចដោយស្វ័យភាពនូវរាល់កិច្ចការផងទាំងពួង ដែលជាផលប្រយោជន៍ទូទៅរបស់ប្រជាជននៅក្នុងសមូហភាពនោះផ្ទាល់ ការគ្រប់គ្រងរបៀបនេះគេហៅថាការគ្រប់គ្រងបែបវិមជ្ឈការដែនដី ។[2]

វិមជ្ឈការ គឺជារបៀបមួយនៃការគ្រប់គ្រងរដ្ឋទោលដែលរបៀបនេះរដ្ឋផ្ទេរអំណាចមួយចំនួនទៅឲ្យសមូហភាពដែនដី និង គ្រឹះស្ថានសាធារណៈ មួយកំណត់ជាក់លាក់អមទៅជាមួយនូវមធ្យោបាយរដ្ឋបាលហិរញ្ញវត្ថុ និងការទទួលខុសត្រូវ។ អាចនិយាយម្យ៉ាងទៀតបានថាជាការទទួលស្គាល់ស្វ័យភាពនៃការគ្រប់គ្រងពោលគឺ សេរីភាពនៃការសម្រេចកិច្ចការមូលដ្ឋានផ្ទាល់។ ស្វ័យភាពមិនមែនជាឯករាជ្យភាពទេ ដូច្នោះ រដ្ឋ ដើម្បីធានាឲ្យមានឯកភាពជាតិនិងរដ្ឋត្រូវត្រួតពិនិត្យលើការគ្រប់គ្រងរបស់សមូហភាព ។

---

[1] គ.ជ.វ.វ ខែឧសភា ឆ្នាំ២០០៨ ។

[2] សៀវភៅនីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៤ អត្ថបទទី ៣៥៣ របស់បណ្ឌិត សាយ បូរី។

វិមជ្ឈការ មានន័យថា សិទ្ធិពិតប្រាកដ ការទទួលខុសត្រូវហើយធនធាន ពិតប្រាកដមួយចំនួនត្រូវបាន ផ្ទេរពីថ្នាក់កណ្តាលរបស់រាជរដ្ឋាភិបាលទៅក្រុមប្រឹក្សា ឃុំ សង្កាត់ តាមរយៈការបោះឆ្នោតជ្រើសតាំង តាមលក្ខណៈប្រជាធិបតេយ្យ ដែលត្រូវបានផ្តល់ស្វ័យភាពក្នុងការសម្រេចលើកិច្ចការនានា ដែលបានចែងនៅក្នុងច្បាប់។ អត្ថន័យខាងលើនេះក៏ត្រូវបានបង្ហាញភាពស្របគ្នាផងដែរ ពីទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិចដែលហៅកាត់ថា USAID ដែលបានឲ្យនិយមន័យពាក្យ វិមជ្ឈការថា ជាដំណើរការផ្ទេរអំណាចទៅឲ្យរដ្ឋបាលថ្នាក់មូលដ្ឋាន ដែលត្រូវបានធ្វើជ្រើសតាំងដោយប្រជាពលរដ្ឋ។

ការកំណត់និយមន័យ វិមជ្ឈការ ជាកិច្ចការដែលពោរពេញដោយភាពពិបាក និង ស្មុគស្មាញ។ តាមការសិក្សាស្រាវជ្រាវបានបង្ហាញថា និយមន័យ និងការផ្តល់ន័យជាច្រើនស្តីពីវិមជ្ឈការទោះជាមានទស្សនៈ និង ទ្រឹស្តីបានលើកឡើងដោយយល់ថា វិមជ្ឈការ សំដៅលើស្មារតីនៃការផ្ទេរសិទ្ធិអំណាច ទំនួលខុសត្រូវ ធនធាន និង ភារកិច្ចខាងមុខងារសាធារណៈ ទៅឲ្យរដ្ឋបាលថ្នាក់ទាបក៏ដោយ។ វិមជ្ឈការត្រូវបានបំបែកខ្លួនជាសមាសភាគសំខាន់ៗរួមមាន វិមជ្ឈការនយោបាយ នឹងប្រជាធិបតេយ្យ វិមជ្ឈការរដ្ឋបាល វិមជ្ឈការហិរញ្ញវត្ថុ នឹងសារពើពន្ធ វិមជ្ឈការបច្ចេកទេស និង វិមជ្ឈការសេដ្ឋកិច្ចជាដើម ។

តាមទស្សនៈរបស់លោក Samaratunge ( សាម៉ារ៉ាធុន ) បានបង្ហាញថាដោយសារតែវាជាគំនិតមួយដ៏ស្មុគស្មាញ ដូច្នេះហើយ ទើបវិមជ្ឈការ ត្រូវបានឲ្យនិយមន័យផ្សេងៗគ្នា តាមស្ថានភាពរស់នៅរបស់មនុស្សទៅតាមតំបន់ និងតាមប្រទេសផ្សេងៗគ្នា ។

វិមជ្ឈការ ជាដំណើរការនៃការផ្ទេរអំណាចទៅឲ្យរដ្ឋបាលមូលដ្ឋាន ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយប្រជាពលរដ្ឋ។ គួរបញ្ជាក់ផងដែរថា សម្រាប់ USAID វិមជ្ឈការទាមទារនូវអត្ថិភាពនៃរដ្ឋបាលមូលដ្ឋាន ដែលត្រូវបានបោះឆ្នោតជ្រើសរើស ពីព្រោះមន្ត្រីមូលដ្ឋានទាំងនោះ នឹងពុំមានស្វ័យភាពទេ ប្រសិនបើពួកគេមិនបានឆ្លើយតបទៅ នឹងអ្នកបោះឆ្នោតមូលដ្ឋាន ។

វិមជ្ឈការមិនមានពន្យល់នៅក្នុងវចនានុក្រមខ្មែរទេ ព្រោះជាពាក្យថ្មីដែលត្រូវបានបង្កើតនៅក្នុងអំឡុងឆ្នាំ ២០០០ ដោយឥស្សរជនខ្មែរមួយរូប នៃរាជរដ្ឋាភិបាលកម្ពុជា។ ទោះយ៉ាងណា យើងអាចស្វែងយល់បានអំពី អត្ថន័យទូទៅនៃពាក្យនេះ បានតាមរយៈវិធីសាស្ត្របំបែកពាក្យ ។

វិមជ្ឈការបានមកពី < វិ > + < មជ្ឈការ > ៖

- វិ គឺ សំដៅដល់អ្វីដែលមិនមែនជា ឬ ដែលផ្ទុយពី ។
- មជ្ឈការ គឺបានន័យថា ការធ្វើឲ្យទៅជាកណ្តាល ។

ដូចនេះ វិមជ្ឈការ បានសេចក្តីថា ការធ្វើមិនឲ្យទៅជាកណ្តាល ឬអាចនិយាយបានថា ការកាត់បន្ថយ ឬ ការបញ្ឈប់ ឲ្យទៅជាថ្នាក់កណ្តាល ។

ក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈ វិមជ្ឈការ សំដៅដល់ការផ្ទេរសិទ្ធិអំណាចសម្រេច ឬ ស្វ័យភាពសម្រេចក្នុងការគ្រប់គ្រង និងផ្តល់សេវាសាធារណៈ ក្នុងដែនកំណត់មួយ ។ ភាគច្រើនគេបែងចែកវិមជ្ឈការជាពីរប្រភេទធំៗ គឺ៖ វិមជ្ឈការបច្ចេកទេស និង វិមជ្ឈការដែនដី ។

## **១.២. ប្រភេទនៃវិមជ្ឈការ**

ប្រជាពលរដ្ឋនៅក្នុង ឃុំ សង្កាត់ មានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ របស់ខ្លួន ហើយប្រជាពលរដ្ឋត្រូវបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវឲ្យចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអភិវឌ្ឍមូលដ្ឋាន ឃុំ សង្កាត់របស់ខ្លួន។ លើសពីនេះទៅទៀត ក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមលក្ខណៈ ប្រជាធិបតេយ្យ។

ដូច្នេះក្រុមប្រឹក្សានេះ ជាតំណាងឲ្យពលរដ្ឋនៅក្នុង ឃុំ សង្កាត់របស់ខ្លួន ។ ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវបានកំណត់មានអាណត្តិចំនួន ៥ ឆ្នាំ ហើយត្រូវបានផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សា ឃុំ សង្កាត់ ថ្មីចូលកាន់តំណែង ។ ហើយក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបានផ្តល់ការទទួលខុសត្រូវ និងភារកិច្ចជាច្រើន ដែលខុសប្លែកទាំងស្រុងពី ការទទួលខុសត្រូវ និង ភារកិច្ចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ កាលពីមុនឆ្នាំ ២០០២ ។ ជាពិសេសភារកិច្ចសំខាន់បំផុតរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ គឺ អភិវឌ្ឍ ឃុំ សង្កាត់ ហើយលើកកម្ពស់សុខុមាលភាព និងមានគណនេយ្យភាពចំពោះ ប្រជាពលរដ្ឋរបស់ខ្លួនថែមទៀតផង ។

ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវធានាឲ្យបានថា សហគមន៍នៅមូលដ្ឋានចូលរួមយ៉ាងពេញលេញ និង សកម្មនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ និង សេចក្តីសម្រេចនានា ដែលមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដូចជា សេចក្តីសម្រេចលើការប្រើប្រាស់ធនធាន សម្រាប់ការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនជាដើម។ ការធ្វើសេចក្តីសម្រេចដែលមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ នោះទើបសេចក្តីសម្រេចទាំងនោះទទួលបាននូវប្រសិទ្ធភាពខ្ពស់ ។

ហេតុនេះហើយវាជាការពិតប្រាកដណាស់ អ្វីក៏ដោយបើគ្មានការចូលរួមពីប្រជារាស្ត្រនោះទេ ទោះបីជារដ្ឋខិតខំប្រឹងប្រែងខ្លាំងយ៉ាងណាក៏ដោយ ក៏វាមិនអាចទៅរួមដែរ ដូចជាការងារអភិវឌ្ឍនានាជាដើម ។ ជាក់ស្តែងប្រសិនបើរាស្ត្រគ្មានលទ្ធភាពក្នុងការចូលរួមនោះទេ ការអភិវឌ្ឍការនោះប្រាកដជាបានត្រឹមតែអភិវឌ្ឍទៅលើខ្លួនឯងតែប៉ុណ្ណោះ ។

ឧទាហរណ៍ ៖ ក្រុមមន្ត្រីដែលទទួលភារកិច្ចតួនាទីជាអ្នកជួយរាស្ត្រ សម្រាប់ធ្វើការអភិវឌ្ឍកិច្ចការណាមួយ ហើយរាស្ត្រមើលឃើញថា មន្ត្រីនោះបានអភិវឌ្ឍខ្លួនឯង ជាជាងការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួនគ្រប់គ្រង ដែរវាអាចសបញ្ជាក់បានថាការអភិវឌ្ឍដែលខ្វះដៃគូរ គឺ មិនទទួលបាននូវប្រសិទ្ធភាពទេ ។

### ១.២.១ វិមជ្ឈការបច្ចេកទេស

វិមជ្ឈការបច្ចេកទេស គឺសំដៅដល់ការប្រគល់សិទ្ធិអំណាចសម្រេច ឬ ស្វ័យភាពសម្រេចក្នុងគ្រប់គ្រងលើកិច្ចការជំនាញ ដោយឡែកណាមួយពីរដ្ឋទៅ អាជ្ញាធររដ្ឋបាលបច្ចេកទេសណាមួយ។

ឧទាហរណ៍៖ អគ្គិសនីកម្ពុជា ក្នុងការគ្រប់គ្រង និងផ្តល់សេវា សាធារណៈផ្នែកអគ្គិសនី។ រដ្ឋាករទឹកស្វយ័ត ក្នុងការគ្រប់គ្រង និង ផ្តល់សេវាសាធារណៈ ផ្នែកផ្គត់ផ្គង់ទឹកស្អាត។ មន្ទីរពេទ្យរដ្ឋ សម្រាប់ការគ្រប់គ្រង និងផ្តល់សេវាសាធារណៈ ផ្នែកសុខាភិបាល ឬ សាកលវិទ្យាល័យរដ្ឋ ដែលបានផ្តល់សេវាសាធារណៈផ្នែកអប់រំជាដើម ។

### ១.២.២. វិមជ្ឈការដែនដី

វិមជ្ឈការដែនដី គឺសំដៅដល់ការប្រគល់ជូនអាជ្ញាធរដែនដីនៅថ្នាក់មូលដ្ឋាន ដែលត្រូវបានបោះឆ្នោតដោយប្រជាពលរដ្ឋនូវសមត្ថកិច្ច និង សិទ្ធិសម្រេចដោយឡែកពីសមត្ថកិច្ចរបស់រដ្ឋ[3] ដើម្បីធានានូវតុល្យភាពអំណាចដ៏ប្រសើរនៅក្នុងដែនដីកំណត់មួយ។[4] ដូចនេះវិមជ្ឈការត្រូវបានសំដៅដល់របាយការណ៍ដែលរដ្ឋាភិបាលប្រគល់ឲ្យ ក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធានដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវរបស់ថ្នាក់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហានេះ ។[5]

## ១.៣. គោលបំណងនៃធ្វើវិមជ្ឈការ

ជាទ្រឹស្តី រដ្ឋជានីតិបុគ្គលសាធារណៈមុនគេបង្អស់ និងតែមួយគត់ ។ ក៏ប៉ុន្តែភាពផ្តាច់មុខនៃនិតិបុគ្គលភាពសាធារណៈរបស់រដ្ឋ មិនអាចធ្វើឲ្យការគ្រប់គ្រងរដ្ឋដំណើរការទៅបានប្រកប ដោយប្រសិទ្ធភាពនោះឡើយ។ ស្ថានភាពដែលរាល់សេចក្តីសម្រេចសាធារណៈត្រូវធ្វើដោយថ្នាក់កណ្តាល ឬ រដ្ឋនឹងពន្លឿតល្បឿននៃការអភិវឌ្ឍ និង ធ្វើឲ្យបាត់បង់ប្រសិទ្ធភាព និងភាពទាន់ពេលវេលាក្នុងការគ្រប់គ្រង និង ផ្តល់សេវាសាធារណៈ តាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។

ហេតុនេះ រដ្ឋបង្កើតឲ្យមាននូវនីតិបុគ្គលផ្សេងទៀត ដាច់ចេញពីរដ្ឋ ដោយបំពាក់ជូននីតិបុគ្គលទាំងនោះនូវស្វ័យភាព សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវតាមច្បាប់ជាធរមាន។ រដ្ឋមានសមត្ថកិច្ចលើគ្រប់វិស័យ តែរដ្ឋធ្វើវិមជ្ឈការ ដោយចែករំលែកសិទ្ធិអំណាច និងសមត្ថកិច្ច របស់ខ្លួនមួយចំនួន ហើយប្រគល់ជូននូវមុខងារ និងធនធាន ( ហិរញ្ញវត្ថុ និង ធនធានមនុស្ស ) ទៅឲ្យអាជ្ញាធរនៅថ្នាក់មូលដ្ឋានដែលនៅជិតប្រជារាស្ត្រប្រចាំថ្ងៃ និង

[3] រដ្ឋ មាននិយមន័យទូលាយនិងនិយមន័យចង្អៀត។ ក្នុងនិតិអន្តរជាតិ រដ្ឋសំដៅដល់រដ្ឋអធិបតេយ្យ និងរដ្ឋឯករាជ្យ រីឯក្នុងនីតិសាធារណៈ រដ្ឋគឺជានីតិបុគ្គលសាធារណៈមួយក្នុងចំណោមនីតិបុគ្គលសាធារណៈ ដែលជាស្ថាប័នសាធារណៈផ្សេងទៀត។

[4] http://www.toupie.org/Dictionaire/Decentrasation.htm

[5] សន្ធានុក្រម, ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, រាជកិច្ចលេខ ៤៥ ឆ្នាំទី៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ទំព័រ៤៥១៣។

ដែលស្គាល់ពីតម្រូវការ និង បញ្ហាប្រឈមមុខដែលកំពុងកើតមានជាក់ស្តែងពាក់ព័ន្ធនឹង ការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈ ។

តាមរយៈវិមជ្ឈការ រដ្ឋធ្វើប្រតិភូកម្មសិទ្ធិអំណាច និង សមត្ថកិច្ច មួយចំនួនទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតណាមួយ ដែលអាចជារាជធានី/ខេត្ត ឬ ក្រុង / ស្រុក/ ខណ្ឌ ឬ ឃុំ / សង្កាត់ ដែលរដ្ឋយល់ថាការសម្រេច និង ការអនុវត្តដោយផ្ទាល់ដោយអាជ្ញាធរមូលដ្ឋាន កម្រិតណាមួយនោះ នឹងមានប្រសិទ្ធភាពជាងការសម្រេចចិត្តដោយរដ្ឋបាលកណ្តាល ។

ជាទូទៅ រដ្ឋប្រគល់ជូនសមត្ថកិច្ចគ្រប់គ្រង និងផ្តល់សេវាសាធារណៈ ដែលជាតម្រូវការមូលដ្ឋានក្នុងជីវភាពប្រចាំថ្ងៃជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា ទឹក ភ្លើង អប់រំ សុខាភិបាល ផ្លូវ និង សេវាដឹកជញ្ជូនជាដើម។ ក៏ប៉ុន្តែទន្ទឹមនេះរដ្ឋតែងតែរក្សាទុកនូវសមត្ថកិច្ចរបស់ខ្លួនលើវិស័យដែលតំណាងឲ្យអធិបតេយ្យរបស់ជាតិ ហើយដែលសិទ្ធិអំណាច និងសមត្ថកិច្ចលើវិស័យទាំងនេះ មិនអាចប្រគល់ជូនថ្នាក់ក្រោមជាតិបានឡើយដូចជាសមត្ថកិច្ចលើ នយោបាយការបរទេស វិស័យការទូត យោធា យុត្តិធម៌ រូបិយប័ណ្ណ ជាដើម ។

គេតែងសង្កេតឃើញថារដ្ឋបាលថ្នាក់ក្រោមជាតិ មិនមានស្ថានតំណាងខេត្តរបស់ខ្លួននៅក្រៅប្រទេសឡើយ, រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មិនមានកងទ័ពដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយឡែកនោះដែរ រីឯតុលាការដំបូងនៅតាមបណ្តាខេត្តគឺជាតុលាការរបស់រដ្ឋទាំងមូល ដែលស្ថិតក្រោមគណៈយុត្តាធិការតែមួយរបស់រដ្ឋ និងមិនស្ថិតក្រោមប្បញ្ញត្តិណាមួយរបស់រដ្ឋបាលថ្នាក់ខេត្តឡើយ។[6] ចុងក្រោយរូបិយប័ណ្ណគឺមានតែមួយគត់សម្រាប់ការប្រើប្រាស់ទូទាំងប្រទេស បានសេចក្តីថា គ្មានរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ អាចបោះពុម្ពរូបិយប័ណ្ណដោយឡែកសម្រាប់ការប្រើប្រាស់ដោយឡែកក្នុងរង្វង់ដែនដី។

## ១.៤. វិមជ្ឈការនៅកម្ពុជានាពេលបច្ចុប្បន្ន

វិមជ្ឈការគឺជាការងារកែទម្រង់ស៊ីជម្រៅមួយ នៃរដ្ឋបាលសាធារណៈខ្មែរ ដែលរហូតមកដល់មុនឆ្នាំ ២០០១ ត្រូវបានចាត់ទុកថាជា រដ្ឋបាលមជ្ឈការ ។ ការកែទម្រង់នេះផងដែរ បានផ្លាស់ប្តូររចនាសម្ពន្ធនៃការគ្រប់គ្រងដែនដី ។ រាជធានី ចែកចេញជាខណ្ឌ រីឯ ខណ្ឌចែកចេញសង្កាត់ ។ ដោយឡែក ខេត្ត ចែកចេញ ជាស្រុក និង ក្រុង ។ ខេត្តមានក្រុងយ៉ាងហោចណាស់មួយ ហើយក្រុងនោះគឺជា មជ្ឈមណ្ឌលរដ្ឋបាល សេដ្ឋកិច្ច ពាណិជ្ជកម្ម របស់ខេត្ត ។

លើសពីនេះ ក្រៅពីទីក្រុងដែលជាទីប្រជុំជនរបស់ខេត្តហើយនោះ ខេត្តខ្លះក៏មានក្រុងលើសពីមួយដែរ ដូចជា ខេត្តកំពង់ចាម មាន ក្រុងសួង រីឯ ខេត្តស្វាយរៀង មាន ក្រុងបាវិត ។ ចំណែកឯ ក្រុង ចែកចេញជា សង្កាត់ ហើយ ស្រុក ចែកចេញជា សង្កាត់ និង ឃុំ ។[7]

---

[6] សៀវភៅ វិមជ្ឈការនៅប្រទេសកម្ពុជា, លី វ៉ុង , ឆ្នាំ២០១៧, ទំព័រ៥។

[7] សៀវភៅ វិមជ្ឈការនៅប្រទេសកម្ពុជា, លី វ៉ុង , ឆ្នាំ២០១៧, ទំព័រ៧។

### ១.៤.១. រដ្ឋបាលឃុំ សង្កាត់

របបគតិយុត្តថ្មីនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវគ្រប់គ្រងដោយច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ រីឯការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបើកផ្លូវដោយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ ច្បាប់ទាំងពីរនេះត្រូវបានអនុម័តនិង ប្រកាសឲ្យប្រើនៅក្នុងឆ្នាំ ២០០១ ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានរៀបចំ ចំនួនបីអាណត្តិរួចមកហើយ ។ រីឯសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋផ្ទាល់ ។

នៅថ្នាក់ក្រោមជាតិ ក៏ដូចជានៅថ្នាក់ជាតិ សមត្ថកិច្ចនៃការគ្រប់គ្រងត្រូវបានបែងចែករវាងអំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ ។ នៅថ្នាក់ក្រោមជាតិ អំណាចនីតិប្បញ្ញត្តិ បានន័យថា អំណាចចេញសេចក្តីសម្រេចជារបស់ក្រុមប្រឹក្សា រីឯអំណាចក្នុងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាត្រូវបានផ្តល់ទៅឲ្យអង្គប្រតិបត្តិមួយរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ។

### ១.៤.២. រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

កំណែទម្រង់រដ្ឋបាលសាធារណៈតាមរយៈនយោបាយវិមជ្ឈការ មិនបានបញ្ឈប់ត្រឹមកម្រិតឃុំ សង្កាត់នោះទេ។ ៧ឆ្នាំ ក្រោយការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ពោលគឺនៅឆ្នាំ ២០០៨ វិមជ្ឈការបានឈានទៅដល់ដំណាក់កាលទី២ ជាមួយនឹងការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

នៅកម្រិតឃុំ សង្កាត់យើងបានដឹងថា ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំអង្គប្រជុំ ក្នុងនាមជាប្រធានក្រុមប្រឹក្សាផង និងជាប្រមុខដឹកនាំអង្គប្រតិបត្តិរបស់ឃុំ ដើម្បីអនុវត្តការសម្រេចរបស់ក្រុមប្រឹក្សាផង ។ ផ្ទុយទៅវិញនៅកម្រិតរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានក្រុមប្រឹក្សា មិនមែនជាប្រមុខដឹកនាំអង្គប្រតិបត្តិទេ ។ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ច ត្រឹមជាប្រធានដែលដឹកនាំអង្គប្រជុំរបស់ក្រុមប្រឹក្សា និងជាអ្នកសម្របសម្រួលកិច្ចការមួយចំនួននៃអង្គប្រជុំរបស់ក្រុមប្រឹក្សាតែប៉ុណ្ណោះ។

ដោយឡែក តួនាទីជាប្រមុខដឹកនាំអង្គប្រតិបត្តិរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានប្រគល់ទៅឲ្យគណៈអភិបាលនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នោះ ។ ដូចនេះ គណៈអភិបាលជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ ចំណុចនេះអាចចាត់ទុកថាជាចំណុចពិសេសមួយ នៃវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា ។

ម្យ៉ាងវិញទៀត ក្នុងនាមជាក្រុមប្រឹក្សា គណៈអភិបាលគឺត្រូវចាត់វិធានការ ដើម្បីធានាឲ្យមន្ត្រី អង្គភាព និង បុគ្គលិករបស់ក្រុមប្រឹក្សាបំពេញនូវតួនាទី ភារកិច្ចរបស់ខ្លួន និង បំពេញការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា ព្រមទាំងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព ។

គណៈអភិបាលមិនមែនជាស្ថាប័នដែលបានកើតចេញពីក្រុមប្រឹក្សាដែលបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋនៅមូលដ្ឋាននោះទេ ហើយក៏មិនមែនកើតចេញពីក្រុមប្រឹក្សាដែលបោះឆ្នោតផ្តល់សេចក្តីទុកចិត្តនោះដែរ ។ គណៈអភិបាលដែលត្រូវបានតែងតាំងឡើងដោយរដ្ឋបាលកណ្តាលដែលមាន ការតែងតាំងដោយព្រះមហាក្សត្រ (ព្រះរាជក្រឹត្យ ) ការតែងតាំងដោយនាយករដ្ឋមន្ត្រី ( អនុក្រឹត្យ ) និងរួមទាំងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ( ប្រកាស ) ។

រីឯ អភិបាល អភិបាលរង ដែលជាអង្គប្រតិបត្តិរបស់ក្រុមប្រឹក្សា គឺមិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ ។ ដូចនេះ អភិបាល អភិបាលរង មិនមានសិទ្ធិក្នុងការបោះឆ្នោតក្នុងក្រុមប្រឹក្សាទេ ។ ចំណុចនេះ ខុសគ្នាពីករណីឃុំ សង្កាត់ ព្រោះ មេឃុំ ចៅសង្កាត់ ក៏ជាសមាជិករបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែរ ដែលហេតុនេះ គាត់មានសិទ្ធិបោះឆ្នោតក្នុងក្រុមប្រឹក្សា ។

គណៈអភិបាល គឺត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និង ជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ។ គណៈអភិបាល ត្រូវរៀបចំដាក់ជូនក្រុមប្រឹក្សាពិនិត្យ និង អនុម័តនូវកម្មវិធីវិនិយោគ ៣ ឆ្នាំ រំកិលប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំ ផែនការអភិវឌ្ឍរយៈពេល ៥ឆ្នាំ និង ក្របខណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នជារៀងរាល់ឆ្នាំ និង របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាដែលត្រូវរាយការណ៍ជូនប្រជាពលរដ្ឋរបស់ខ្លួន ។[8]

ចំណែកឯក្រុមប្រឹក្សាវិញ ត្រូវពិនិត្យមើលសកម្មភាព និងការអនុវត្តរបស់គណៈអភិបាល និង អភិបាល គណៈអភិបាល ឬ អភិបាលដែលបានសម្រេច ឬ អនុវត្តកិច្ចការណាមួយដែលស្ថិតក្នុងដែនដីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាតែពុំទទួលបានការសម្រេចពីក្រុមប្រឹក្សា ការសម្រេចនោះពុំមានសុពលភាពទេ ។

## ១.៥. ទំហំនៃវិមជ្ឈការដែលរៀបចំនៅកម្ពុជា

ដើម្បីអនុវត្តប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ ក្រសួងមហាផ្ទៃត្រូវបានរៀបចំច្បាប់ពីរ ដែលមានទំនាក់ទំនងផ្សាភ្ជាប់គ្នា គឺច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានអនុម័តនៅថ្ងៃទី១២ ខែមករា ឆ្នាំ ២០០១ ហើយត្រូវបានប្រកាសឲ្យបានប្រើនៅថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តនៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០១ ហើយត្រូវបានប្រកាសឲ្យ ប្រើនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គឺជាការបង្ហាញនូវគំនិត និងទំហំវិមជ្ឈការនៅកម្ពុជា ។ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាការកម្រិតនៃបែបបទ និងនីតិវិធីក្នុងការបោះឆ្នោតក្នុងលក្ខខណ្ឌសេរីត្រឹមត្រូវ យុត្តិធម៌ និងឈរលើគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស។

[8] មាត្រា១០០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨។

ដំណើរការវិមជ្ឈការ ត្រូវបានរៀបចំបង្កើតដោយមានអាជ្ញាធរមូលដ្ឋាននៅក្នុងឃុំ សង្កាត់នីមួយៗ ដែលខុសពីរដ្ឋបាលថ្នាក់ជាតិ និងដឹកនាំដោយតំណាងឃុំ សង្កាត់ដែលជាប់ឆ្នោត ដើម្បីអនុវត្តដែនសមត្ថកិច្ច របស់ខ្លួន ក្នុងក្របខណ្ឌឃុំ សង្កាត់។

នៅក្នុងដំណើរការឃុំ សង្កាត់ចាំបាច់ត្រូវការមានទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីបណ្តុះបណ្តាលធនធានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំកសាងផែនការអភិវឌ្ឍមូលដ្ឋាន និងថវិកាឃុំ សង្កាត់ ឲ្យមានការទទួលខុសត្រូវ តម្លាភាព និង អភិបាលកិច្ចល្អ ស្របតាមគោលការណ៍នយោបាយរបស់រាជរដ្ឋាភិបាល។[9]

[9] សន គីណាល់, កម្មវិធីសិលា ( វិមជ្ឈការនៅកម្ពុជា ), ២០០២ ។

# ជំពូកទី២
# មែកធាងនៃប្រព័ន្ធវិមជ្ឈការ

វិមជ្ឈការ ជាធាតុចម្បងមួយក្នុងដំណើរការនៃការអនុវត្តការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់។ ក្រុមប្រឹក្សាឃុំសង្កាត់ជានីតិបុគ្គលមួយដែលមានភារកិច្ចធានា និងអនុវត្តប្រព័ន្ធវិមជ្ឈការ។ តាមសៀវភៅរបស់លោកបណ្ឌិត ដាវីឌ អាយរ៉េស (២០០១) បានចែងមែកធាងវិមជ្ឈការជាបួនសំខាន់ៗគឺ វិមជ្ឈការនយោបាយ វិមជ្ឈការរដ្ឋបាល វិមជ្ឈការសារពើពន្ធ និង វិមជ្ឈការសេដ្ឋកិច្ចឬទីផ្សារ ។ ដោយក្នុងនោះផងដែរធាតុមួយក្នុងចំណោមមែកធាងទាំងបួនរបស់វិមជ្ឈការនោះគឺមានវិមជ្ឈការរដ្ឋបាលត្រូវបានគេចែកចេញជាបីទម្រង់បន្ថែមទៀតនោះគឺ វិសហមជ្ឈការ ការប្រគល់អំណាច និង ការផ្ទេរអំណាចទាំងស្រុង។

**តារាងមែកធាងនៃវិមជ្ឈការ**




## ២.១. វិមជ្ឈការនយោបាយ

វិមជ្ឈការនយោបាយ ជាខ្លឹមសារច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលផ្តល់ឲ្យប្រជាពលរដ្ឋ និងអ្នកទាំងឡាយដែលបានបោះឆ្នោតជ្រើសរើសធ្វើជាតំណាងរបស់ពួកគាត់ (ប្រជាពលរដ្ឋ) នូវអំណាចច្រើនជាងមុនក្នុងការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ។

វិមជ្ឈការនយោបាយនេះហើយដែល USAID ចង់សំដៅលើពេលដែលខ្លួនកំណត់និយមន័យវិមជ្ឈការ ហើយក៏មានការយល់ដឹងកាន់តែច្រើនឡើងៗ ទូទាំងប្រទេសកម្ពុជាថា ប្រជាពលរដ្ឋត្រូវតែរួមចំណែកឲ្យកាន់តែខ្លាំងឡើងៗក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលទាក់ទង នឹងកិច្ចការរបស់ពួកគេ ដោយមានការយល់ចិត្តទុកដាក់

និងការយល់ដឹងច្រើនឡើងៗថា រដ្ឋាភិបាល និងការគ្រប់គ្រងរដ្ឋបាលត្រូវមានលក្ខណៈទន់ភ្លន់ និងឆ្លើយតបនឹងប្រសើរជាងមុន ចំពោះប្រជាពលរដ្ឋហើយអាជ្ញាធរឃុំ ឬ ក្រុមប្រឹក្សាឃុំ កាន់តែនៅជិតស្និទ្ធជាមួយប្រជាពលរដ្ឋ និងអាចធ្វើអន្តរាគមន៍ទាន់ពេលវេលាក្នុងការឆ្លើយតបទៅនឹងតម្រូវការ ។ ការបម្រើការជូនទៅដល់ប្រជាពលរដ្ឋទៅបាន គឺត្រូវការឆ្លងកាត់នូវការជ្រើសរើសពីប្រជាពលរដ្ឋ ។

អ្នកទាំងឡាយណា ដែលគាំទ្រវិមជ្ឈការនយោបាយ បានធ្វើការអះអាងថា ការសម្រេចចិត្តដែលធ្វើឲ្យមានការចូលរួមច្រើនឡើងៗពីសំណាក់ប្រជាពលរដ្ឋនឹងទទួលព័ត៌មាន និងធ្វើការឆ្លើយតបបានប្រសើរជាងមុនចំពោះស្ថានភាព និងតម្រូវការនៅមូលដ្ឋាន ។

## ២.២. វិមជ្ឈការរដ្ឋបាល

វិមជ្ឈការរដ្ឋបាល គឺទាក់ទងទៅនឹងការបែងចែកឡើងនូវអំណាចទំនួលខុសត្រូវ និងធន ធានហិរញ្ញវត្ថុសម្រាប់ផ្តល់សេវាកម្មសាធារណៈ ក្នុងចំណោមលំដាប់ថ្នាក់ថ្នាក់ផ្សេងៗនៃអង្គការចាត់តាំងរបស់រដ្ឋ។ ជាខ្លឹមសារវាសំដៅលើការផ្ទេរទំនួលខុសត្រូវលើការរៀបចំផែនការហិរញ្ញវត្ថុ និងការចាត់ចែងមុខងារសាធារណៈខ្លះៗ ពីអំណាចរដ្ឋបាលកណ្តាល និងទីភ្នាក់ងាររបស់ខ្លួនទៅអង្គភាពមូលដ្ឋាន អង្គភាពក្រោមឱវាទ អាជ្ញាធរ ឬសាជីវកម្មសាធារណៈពាក់កណ្តាលស្វយ័ត ។

តាម UNDP បានឲ្យនិយមន័យ វិមជ្ឈការរដ្ឋបាលថា គឺជាការផ្ទេរ ការទទួលខុសត្រូវក្នុងការរៀបចំផែនការ ការគ្រប់គ្រង និងការបែងចែងប្រភពថវិការពីរដ្ឋាភិបាល និងភ្នាក់ងារផ្សេងៗរបស់ខ្លួន ឲ្យទៅមូលដ្ឋាន អង្គភាពភ្នាក់ងារនៃរដ្ឋាភិបាលមូលដ្ឋាន អង្គភាពស្ថិតនៅក្រោមបង្គាប់រដ្ឋាភិបាលអាជ្ញាធរ ក្រុមហ៊ុនពាក់កណ្តាលស្វយ័ត អាជ្ញាធរមុខងារជាដើម ។

លក្ខន្តិកៈគតិយុត្ត ឬ ទម្រង់ការរបស់រដ្ឋមានឥទ្ធិពលយ៉ាងខ្លាំង ទៅលើការរៀបចំអំណាចរដ្ឋបាលនីមួយៗ។ ប្រទេសកម្ពុជា ជារដ្ឋទោល ( Unilateral State ) និង ជារាជាណាចក្រដែលមិនអាចបំបែកបាន ។[10] ប្រការនេះវាមានផលវិបាកលើការរៀបចំអំណោចរដ្ឋបាល។ ក្នុងប្រទេសមួយដែលជារដ្ឋទោល មានភាពខុសគ្នាជាមួយរដ្ឋសហព័ន្ធនៅក្នុងរដ្ឋទោល រដ្ឋគ្មានដៃគូប្រជែងឡើយ គឺអំណោចទាំងអស់ត្រូវបានស្ថិតនៅក្នុងកណ្តាប់ដៃរបស់រដ្ឋ (អំណោចចេញបទបញ្ជា អំណោចផ្តាច់មុខរបស់រដ្ឋបាលកណ្តាល ) ។

ការគ្រប់គ្រងរដ្ឋបាលមិនតម្រូវឲ្យគេត្រូវតែប្រកាន់យកប្រព័ន្ធរដ្ឋ បាលមជ្ឈការជាដាច់ខាតនោះទេ គេអាចធ្វើវិមជ្ឈការរដ្ឋបាលដោយមិនធ្វើឲ្យប៉ះពាល់ដល់ឯកភាពនយោបាយរបស់រដ្ឋដែរ ដោយបែងចែកអំណាចរដ្ឋបាលតាមប្រព័ន្ធគ្រប់គ្រងមជ្ឈការ ( Centralization ), វិមជ្ឈការ ( Decentralization ), និង វិសហមជ្ឈការ ( Deconcentration ) ។

[10] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

### ២.២.១. វិសហមជ្ឈការ

វិសហមជ្ឈការមានន័យថា រដ្ឋាភិបាល ក្រសួង ឬស្ថាប័នធ្វើប្រតិភូកម្ម ( Delegation ) មុខងារសិទ្ធិអំណាច នឹងធនធាន ( ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក ) ទៅអង្គភាពក្រោម បង្គាប់ឬ ទៅក្រុមប្រឹក្សាណាមួយ ដើម្បីអនុវត្តមុខងារក្នុងនាមរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ ។[11]

ដោយយោងទៅលើអត្ថន័យវិមជ្ឈការ វិសហមជ្ឈការ គឺមានន័យផ្ទុយដោយថាមន្ត្រី និងធនធានត្រូវបានផ្ទេរពីថ្នាក់ជាតិ ( ថ្នាក់កណ្ដាល ) ទៅកាន់ថ្នាក់ក្រោមជាតិ ប៉ុន្តែសិទ្ធិសម្រេចនៅថ្នាក់កណ្ដាលដដែល ។[12]

សញ្ញាណនៃវិសហមជ្ឈការ គឺជាបច្ចេកទេសមួយក្នុងការការរៀបចំរដ្ឋបាលមួយ ដែលត្រូវបានបង្កើតឡើងដើម្បីកែសម្រួលប្រព័ន្ធមជ្ឈការ ហើយដែលបានផ្ដល់ទៅឲ្យអាជ្ញាធរដែនដីអំណាចសម្រេចសេចក្ដីលើកិច្ចការខ្លះៗ ដែលជាធម្មតាអំណាចទាំងអស់នេះជារបស់រដ្ឋបាលកណ្ដាលជា ភ្នាក់ងារដែលទទួល បន្ទុកដឹកនាំអាជ្ញាធរដែនដី ដោយស្ថិតក្រោមអំណាចឋានានុក្រមនៃរដ្ឋបាល កណ្ដាលដដែល។ មានការច្រឡំជាច្រើនចំពោះវិសហមជ្ឈការជាមួយវិមជ្ឈការនោះ ជាក់ស្តែង វិសហមជ្ឈការ មិនបានធ្វើឲ្យមានការផ្លាស់ប្តូរប្រព័ន្ធរដ្ឋបាលឡើយ វាគ្រាន់តែសម្រួលដល់ប្រព័ន្ធ មជ្ឈការប៉ុណ្ណោះ ។

### ២.២.២. ការប្រគល់អំណាចប្រតិភូកម្ម

ការប្រគល់អំណាច គឺសំដៅទៅលើស្ថានភាពមួយ ដែលរដ្ឋបាលកណ្ដាលផ្ទេរការទទួលខុសត្រូវលើការសម្រេចចិត្ត និង ការគ្រប់គ្រងរដ្ឋបាលមុខងារសាធារណៈ ដែលធ្វើឲ្យរដ្ឋបាលមូលដ្ឋាន ឬ ជាអង្គភាពចាត់តាំងពាក់កណ្ដាលស្វ័យត ដែលមិនត្រូវគ្រប់គ្រងទាំងស្រុងដោយរដ្ឋបាល កណ្ដាល ប៉ុន្តែត្រូវរាយការណ៍ទៅឲ្យរដ្ឋបាលកណ្ដាល ។

រីឯការផ្ទេរអំណាចទាំងស្រុង ជារដ្ឋបាលស្វ័យតនៅថ្នាក់ក្រោមជាតិ ដូចរដ្ឋបាលខេត្តស្រុក និង អាជ្ញាធរមូលដ្ឋានដែលត្រូវបានគេរៀបចំតាមច្បាប់ ជាការបែងចែកអង្គការអភិបាលកិច្ច។ ការផ្ទេរសិទ្ធិអំណាចទៅអង្គភាពរដ្ឋបាលខាងលើនេះ គឺជាទម្រង់ប្រគល់អំណាចទាំងស្រុងហើយជាការយល់ដឹងជាទៅទូថាជាវិមជ្ឈការមិនក្លែងក្លាយ ( Genuine Decentralization ) ។ តាមរយៈពេលប្រគល់អំណាចនេះរដ្ឋាភិបាលជាតិត្រូវ ធ្វើអនុប្បទាន ( Relinquishment ) មុខងារមួយចំនួន ឬ បង្កើតអង្គភាពថ្មីដែលមិនស្ថិតនៅ ក្រោមការត្រួតត្រាពីស្ថាប័នណាមួយឡើយ ។

ភាពមិនក្លែងក្លាយនៃការធ្វើ វិមជ្ឈការនេះ អាចត្រូវបានគេដឹងជាមូលដ្ឋានគ្រឹះមួយចំនួនដូចខាងក្រោម ៖

- ទី១ រដ្ឋាភិបាលមូលដ្ឋានមានសិទ្ធិអំណាចស្វ័យភាព ឯករាជ្យភាពក្នុងកិច្ចអភិវឌ្ឍន៍នៅមូល ដ្ឋាន ឬរដ្ឋាភិបាលកណ្ដាលមានការត្រួតពិនិត្យយ៉ាងតិចតួចកិច្ចការរដ្ឋបាលមូលដ្ឋាន ។

---

[11] អង្គការពុទ្ធសាសនាដើម្បីការអភិវឌ្ឍ, ២០០៩។

[12] ក្រសួងផែនការ, ខែឧសភា ឆ្នាំ២០០៩។

- ទី២ រដ្ឋាភិបាលមូលដ្ឋានត្រូវបានគេ ទទួលស្គាល់ភាពត្រឹមត្រូវតាមច្បាប់ និងភាពច្បាស់ លាស់នូវព្រំប្រទល់ភូមិសាស្ត្រដែលខ្លួនបំពេញមុខងារ និងដែនសមត្ថភាពរបស់ខ្លួន។
- ទី៣ រដ្ឋាភិបាលមូលដ្ឋាន មានលក្ខន្តិកៈបែបក្រុមហ៊ុន និង សិទ្ធិអំណាចក្នុងការ រក្សាប្រភពធនធានផ្សេងៗ ដើម្បីបំពេញមុខងាររបស់ខ្លួន ។
- ទី៤ ដើម្បីអភិវឌ្ឍន៍ រដ្ឋាភិបាលមូលដ្ឋានចាំបាច់ ត្រូវធ្វើអនុលោមតាមការប្រគល់អំណាចទាំងស្រុង ( Devolution ) ជាស្ថាប័នក្នុងន័យថា ប្រជាពលរដ្ឋ ជាអ្នកត្រួតពិនិត្យមើលអង្គការ ដែលជាអ្នកផ្តល់សេវាសាធារណៈ តាមសេចក្តីត្រូវការ និងចង់បានរបស់ពួកគេ ហើយជាថ្នាក់រដ្ឋាភិបាលមួយដែលមានឥទ្ធិពលមួយចំនួន ។
- ទី៥ ការប្រគល់អំណាចទាំងស្រុងនោះ ជារបៀបនៃការគ្រប់គ្រងមួយដែលរដ្ឋាភិបាលនៅមូលដ្ឋាន និងរដ្ឋាភិបាលថ្នាក់ជាតិទទួលបាននូវអត្ថប្រយោជន៍ពីគ្នាទៅវិញទៅមក និងមានការសម្រេចសម្រួលគ្នា ។

ការផ្ទេរអំណាចទាំងស្រុង ជាទម្រង់ធំជាងគេរបស់វិមជ្ឈការ គឺសំដៅទៅលើស្ថានភាពមួយដែលរដ្ឋាភិបាលកណ្តាលបានផ្ទេរអំណាចក្នុងការសម្រេចចិត្តហិរញ្ញវត្ថុ និងការចាត់ចែងទៅឲ្យអង្គភាពដែលស្ទើរតែស្វ័យតនៃរដ្ឋបាលមូលដ្ឋាន ។

## ២.៣. វិមជ្ឈការសារពើពន្ធ

ការទទួលខុសត្រូវខាងសារពើពន្ធ ជាធាតុផ្សំមួយយ៉ាងសំខាន់បំផុតនៃវិមជ្ឈការ ព្រោះរដ្ឋបាលមូលដ្ឋានត្រូវតែមានចំណូលគ្រប់គ្រាន់ ( ដែលប្រមូលបាននៅមូលដ្ឋានផ្ទាល់ ឬបញ្ជូនពីរដ្ឋបាលកណ្តាល ) ដើម្បីធ្វើការសម្រេចចិត្តលើការចំណាយសេវាកម្មនានារបស់ឃុំ សង្កាត់របស់ខ្លួន។

វិមជ្ឈការសារពើពន្ធមានទម្រង់ជាច្រើនដែលអាចត្រូវបានសង្ខេបដូចខាងក្រោម ៖

- ហិរញ្ញប្បទានផ្ទាល់ខ្លួន ឬការទូទាត់ចំណាយតាមការយកថ្លៃពីអ្នកប្រើប្រាស់។
- ការពង្រីកប្រាក់ចំណូលក្នុងមូលដ្ឋានតាមរយៈការយកពន្ធអាករនិងការយកថ្លៃសេវាកម្មដោយប្រយោល ។
- ការផ្ទេរហិរញ្ញប្បទានដែលមានលក្ខណៈអន្តររដ្ឋបាល ។
- ការផ្តល់អំណាចក្នុងការខ្ចីហិរញ្ញប្បទាន ដើម្បីបម្រើមូលដ្ឋាន ។[13]

## ២.៤. វិមជ្ឈការសេដ្ឋកិច្ច ឬ ទីផ្សារ

ចេញពីចក្ខុវិស័យរបស់រដ្ឋាភិបាលវិមជ្ឈការសេដ្ឋកិច្ច ឬទីផ្សារ ជាធម្មតាទម្រង់ពេញលេញបំផុតរបស់វិមជ្ឈការ ព្រោះវាផ្ទេរការទទួលខុសត្រូវលើមុខងារផ្សេងៗពីផ្នែកឯកជន។ ជាញឹកញាប់ វិមជ្ឈការសេដ្ឋកិច្ច កើតឡើងតាមរយៈឯកជនភាវូបនីយកម្ម និង ការកាត់បន្ថយនីយ័តកម្មមួយ ឬ បន្សាំគ្នា។[14]

---

[13] Rondinelli, What is Decentralization? World Bank Institute, 1999.

[14] Rondinelli, What is Decentralization? World Bank Institute, 1999.

## ២.៥. ទិសដៅនៃវិមជ្ឈការ

ការធ្វើវិមជ្ឈការនេះ គឺ ដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋឲ្យ ចូលរួមកាន់តែទូលំទូលាយ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែលមានផលប៉ះពាល់ទៅ និង ជីវភាពរស់នៅ និងអនាគតរបស់ខ្លួន ។ លើពីនេះទៅទៀត ដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ។ ហើយធានាការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់សេវា ឲ្យនៅជិតប្រជាពលរដ្ឋ និងយល់ច្បាស់អំពីតម្រូវការចាំបាច់របស់ពួកគាត់ ។

### ២.៥.១. ការផ្តល់ឱកាសឲ្យ ប្រជាពលរដ្ឋចូលរួមពេញលេញ

តាមរយៈប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅឃុំ សង្កាត់ ប្រជាពលរដ្ឋ គ្រប់រូប រួមមាន ស្ត្រី បុរស ចាស់ ក្មេង ជនងាយរងគ្រោះ។ល។ គឺមានសិទ្ធិ និង ចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់ឃុំ សង្កាត់ និង ដំណើរការអភិវឌ្ឍមូលដ្ឋាន ដូចជា ការបញ្ចេញមតិ និង រួមចំណែកតាមមធ្យោបាយផ្សេងៗ។ ហើយប្រជាពលរដ្ឋមានសិទ្ធិលើកឡើង អំពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួន តាមរយៈនីតិវិធី និង យន្តការដែលបានកំណត់ក្នុងក្របខណ្ឌវិមជ្ឈការ ។

ប្រជាពលរដ្ឋអាចបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលពួកគាត់គិតថា អាចតំណាងឲ្យផលប្រយោជន៍របស់ពួកគាត់បានល្អប្រសើរ បំផុត និងអាចមានទំនាក់ទំនងជាមួយពួកគាត់បានយ៉ាងងាយស្រួល ចំពោះការងារដែលពាក់ព័ន្ធនិង ឃុំ សង្កាត់។ ហើយប្រជាពលរដ្ឋអាចលើកឡើងពីបញ្ហាដែលពួកគាត់កំពុងជួបប្រទះ និងផលប្រយោជន៍របស់ពួកគាត់ នៅក្នុងកិច្ចប្រជុំ ឃុំ សង្កាត់ ជាពិសេសតាមដាននិងត្រួត ពិនិត្យនូវការអនុវត្តគម្រោងនៅមូលដ្ឋាន និងការទទួលបានពត៌មានផ្សេងៗទៀតដែលពួកគាត់ចង់ដឹង គឺមានលក្ខណៈងាយស្រួល និងសុក្រឹត្យ។

ការផ្តល់ឱកាសឲ្យពលរដ្ឋចូលរួមពេញលេញគឺជាភារកិច្ចយ៉ាងសំខាន់របស់ក្រុមប្រឹក្សា ឃុំ សង្កាត់។ ដោយការចូលរួមនេះផងដែរអាចជួយឲ្យក្រុមប្រឹក្សា ឃុំ សង្កាត់ អាចស្វែងយល់អំពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋផ្ទាល់ ហើយក៏អាចធ្វើការឆ្លើយតបឲ្យចំគោលដៅ ហើយប្រសិនបើប្រជាពលរដ្ឋបានចូលរួមផ្ទាល់ផងដែរនោះគឺ គាត់ពួកនឹង មានអារម្មណ៍ថាខ្លួនក៏បានចូលរួមចំពោះការទទួលខុសត្រូវក្នុងការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួនគាត់ផ្ទាល់ផងដែរ ដូចនេះរាល់សេចក្តីសម្រេចនៃគម្រោងការអភិវឌ្ឍស្ទើរតែទាំងអស់នោះនឹង ទទួលបាននូវប្រសិទ្ធភាព និង សមទ្ធិផល ។

### ២.៥.២. ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យអភិបាលកិច្ចល្អ និងគុណភាពនៃការរស់នៅ

វិមជ្ឈការ ត្រូវបានចាត់ទុកថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជំរុញអភិបាលកិច្ចល្អហើយ អភិបាលកិច្ចល្អនេះផងដែរ គឺជាការអនុវត្តនូវការងារឲ្យបានសមស្របទៅ និងទិដ្ឋភាពសំខាន់ៗ មួយដូចខាងក្រោម ៖

- ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបំពេញការងារដោយអនុវត្តទៅតាមច្បាប់ និង លិខិតបទដ្ឋាននានា ដែលបានកំណត់ ។
- ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមលក្ខណៈប្រជាធិបតេយ្យ ដោយប្រជាពលរដ្ឋរបស់ខ្លួន ដូចនេះអ្វីដែលក្រុមប្រឹក្សា ឃុំ សង្កាត់ បានសម្រេច និង អនុវត្ត គឺត្រូវទទួលខុសត្រូវយ៉ាងពេញលេញចំពោះប្រជាពលរដ្ឋរបស់ខ្លួន មានន័យថា ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវរៀបចំផែនការយ៉ាងណាដើម្បីឲ្យមានឆ្លើយតបទៅនិង តម្រូវការរបស់ប្រជាពលរដ្ឋ ហើយក៏ត្រូវផ្តល់ព័ត៌មានពីរបៀបធនធានដែលខ្លួនមាន និងត្រូវធានាឲ្យបានថា ធនធានទាំងនោះត្រូវបានប្រើប្រាស់ ដើម្បី បម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព ។
- ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវមានតម្លាភាព នៅក្នុងការងារដែលខ្លួនបានបំពេញទាំងអស់ ហើយត្រូវជម្រាបជូន សាធារណៈជនពី កិច្ចការនានាដែលខ្លួនបានពិភាក្សា ឬ សេចក្តីសម្រេចដែលខ្លួនបានសម្រេច គឺត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈទៅតាមគ្រប់មធ្យោ បាយដែលអាចធ្វើទៅបាន និងទទួលនូវរាល់មតិយោបល់របស់សាធារណៈជន អំពីសេចក្តីសម្រេចនោះមកវិញ ដូច្នេះទើបការអនុវត្តនោះទទួលបាននូវលទ្ធផលល្អ ។

ដោយក្រុមប្រឹក្សា ឃុំ សង្កាត់ ស្ថិតនៅកៀក ប្រជាពលរដ្ឋមូលដ្ឋាន និង ដឹងច្បាស់អំពីសេចក្តីត្រូវការដូចនេះ ក្រុមប្រឹក្សា ឃុំ សង្កាត់ អាចធ្វើការដោះស្រាយ និង កែលម្អនូវជីវភាពនៃរស់នៅ របស់ប្រជាពលរដ្ឋតាមរយៈការឆ្លើយតបទៅនិង តម្រូវការជាក់ស្តែងរបស់ពួកគាត់ ។

# ជំពូកទី៣
# គុណសម្បត្តិ បញ្ហាប្រឈម និង កំណែទម្រង់

ទោះជានយោបាយវិមជ្ឈការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានចាក់ឫសចូលក្នុងប្រព័ន្ធគ្រប់គ្រងក្នុងប្រទេសនេះអស់រយៈពេលមួយទស្សវត្សយ៉ាងណាក្តី ក៏ប្រទេសកម្ពុជានៅតែមានការព្រួយបារម្ភ និងការខ្វះខាតនូវចន្លោះជាច្រើនរបស់រាជរដ្ឋាភិបាល និងថ្នាក់រដ្ឋបាលមូលដ្ឋានដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ នៅទូទាំងប្រទេស ។ យ៉ាងណាមិញប្រទេសកម្ពុជាយើង មានការរីកចម្រើនក៏ដោយការធ្វើវិមជ្ឈការនេះផងដែរ ហើយកម្ពុជាក៏មានបញ្ហាប្រឈមមុខផងដែរ ដែលទាក់ទងនឹងវិមជ្ឈការនេះរួមមានដូចជា ប្រព័ន្ធនៃការទទួលខុសត្រូវ និងតម្លាភាព ការចូលរួម និងសង្គមស៊ីវិល ការរៀបចំចាត់ចែងសារពើពន្ធ និងសមត្ថភាព ។

ដើម្បីប្រទេសកម្ពុជាកាន់តែរីកចម្រើននោះ រដ្ឋាភិបាលក៏បានធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការផងដែរក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងដោះស្រាយនូវបញ្ហាប្រឈមជាអាទិភាពនានា នៅតាមមូលដ្ឋានផ្សេងៗដូចគ្នា ដែលប្រការនេះបានចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់ការលើកស្ទួយជីវភាពរស់នៅ គុណភាពជីវិតរបស់សហគមមូលដ្ឋាន និងកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព បរិយាប័ន្ន និងសមធម៌សង្គមជាដើម ។

## ៣.១. គុណសម្បត្តិនៃការធ្វើវិមជ្ឈការ

ការធ្វើវិមជ្ឈការ គឺបានផ្តល់សារះប្រយោជន៍យ៉ាងច្រើនក្នុងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសមួយ ឲ្យកាន់តែមានភាពរីកចម្រើន និងប្រជាពលរដ្ឋកាន់តែមានការយល់ដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការចូលរួមសកម្មភាពសង្គមផ្សេងៗដើម្បីប្រទេសមានការរីកចម្រើន។ ម្យ៉ាងវិញទៀត វិមជ្ឈការ ក៏បានផ្តល់សិទ្ធិឲ្យប្រជាពលរដ្ឋជ្រើសរើសនូវតំណាងរបស់ខ្លួនតាមរយៈការបោះឆ្នោតដើម្បីដឹកនាំ និងគ្រប់គ្រងប្រទេសទាំងមូលជំនួសពួកគាត់ ។

ជាមួយគ្នានេះដែរ ការធ្វើវិមជ្ឈការនេះក៏ផ្តល់ឲ្យប្រជាពលរដ្ឋចំណេញពេលវេលា ព្រោះរដ្ឋបាលកណ្តាលបានផ្តល់សមត្ថកិច្ចមួយចំនួនទៅឲ្យរដ្ឋបាលដែនដី ដើម្បីបម្រើសេវាជូនប្រជាពលរដ្ឋឲ្យបានគ្រប់គ្រាន់តាមតម្រូវការនៅក្នុងមូលដ្ឋាន និងទាន់ពេលវេលា ។

- ប្រទេសមានប្រព័ន្ធច្បាប់ច្បាប់រឹងមាំ
- បង្ហាញពីភាពប្រជាធិបតេយ្យ ដើម្បីឈានក្លាយទៅជាប្រទេសនីតិរដ្ឋ
- ប្រជាជនពេញចិត្តនឹងអ្នកដឹកនាំដែលខ្លួនបានជ្រើសរើស
- ប្រជាជនពេញចិត្តនឹងការវិភាគទានសម្រាប់មូលដ្ឋានរបស់ខ្លួន

- មិនកកស្ទះរឿងនៅអាជ្ញាធរថ្នាក់ជាតិ
- ប្រទេសមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស
- បើកទូលាយសិទ្ធិសេរីភាពឲ្យប្រជាពលរដ្ឋចូលរួមសហការក្នុងការងាររបស់រដ្ឋអំណាចកណ្តាល ។
- ប្រជាពលរដ្ឋមានលទ្ធភាពចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើសេចក្តីសម្រេចនៅក្នុងមូលដ្ឋានដែលនេះគឺជាការពង្រឹងនិង ពង្រីកនូវការចូលរួមជាសាធារណៈនៅក្នុងការអភិវឌ្ឍរបស់ប្រទេសជាតិ ។
- ផ្តល់នូវសេវាសាធារណៈនៅថ្នាក់ក្រោមជាតិកាន់តែរហ័សនិងមានប្រសិទ្ធភាព។
- អនុញ្ញាតឲ្យអាជ្ញាធរមូលដ្ឋានអាចចេញសេចក្តីសម្រេចផ្សេងៗ ឬលិខិតបទដ្ឋាននានាដោយឡែកសម្រាប់គ្រប់គ្រង និងការអភិវឌ្ឍនៅមូលដ្ឋាន ។
- មានលទ្ធិប្រជាធិបតេយ្យស៊ីជម្រៅ ព្រោះមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋពីមូលដ្ឋានក្នុងការសម្រេចនូវរាល់កិច្ចការទាំងឡាយណាដែលជាប្រយោជន៍របស់រាស្ត្រ ។
- មានប្រជាធិបតេយ្យស៊ីជំរៅ ( អង្គការកើតចេញពីការបោះឆ្នោត )
- ចំណាយពេលវេលាតិចក្នុងការ ទទួលនូវរាល់សេវាដែលនាំឲ្យមានការអភិវឌ្ឍដែលជាកត្តានាំឲ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការរស់នៅ ។
- ស្វ័យភាពនៃការងារដែលនាំឲ្យមានកម្លាំងចិត្ត
- គ្រឹះនៃប្រជាធិបតេយ្យទៅតាមមូលដ្ឋាន
- ការគ្រប់គ្រងសេវាកម្មសាធារណៈមានលក្ខណៈងាយស្រួលក្នុងការធ្វើដែលជាហេតុបណ្តាលឲ្យមានប្រសិទ្ធភាពកាន់តែល្អប្រសើរឡើង ។[15]

## ៣.២. បញ្ហាប្រឈម

### ៣.២.១. ប្រព័ន្ធនៃការទទួលខុសត្រូវ និង តម្លាភាព

ជាការកត់សម្គាល់ និងការព្រួយបារម្ភមួយ ដែលទាក់ទងនឹងទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ជាបរិបទជាតិ ដែលជាក្រុមប្រឹក្សាទាំងនេះត្រូវបានអនុម័ត ។ នៅក្នុងខណៈពេល ដែលប្រព័ន្ធវិមជ្ឈការថ្មីមួយនៃអភិបាលកិច្ចអាច នឹងអនុម័តយកវិធានការផ្សេងៗដើម្បីធានា ឬជំរុញទំនួលខុសត្រូវរបស់អង្គភាពរដ្ឋបាលមូលដ្ឋាន ។ គេត្រូវតែដឹងថាអង្គភាពរដ្ឋបាលមូលដ្ឋានទាំងនេះនឹងដំណើរការទៅក្នុងបរិបទជាតិ ( គោលនយោបាយជាតិ ) ដែលទំនួលខុសត្រូវមានកម្រិតខ្សោយ ហើយដែលគ្មានទម្លាប់ដាក់ទណ្ឌកម្ម ( ទទួលទោស ) ឲ្យបានត្រឹមត្រូវដល់មន្ត្រីដែលបានបរាជ័យមិនបានបំពេញមុខងាររបស់ខ្លួន។ ម្យ៉ាងទៀត តម្លាភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទាក់ទងទៅនឹងទីតាំងរបស់ក្រុមប្រឹក្សាមានន័យថា តម្លាភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទាក់ទងនឹងត្រូវ

[15] សៀវភៅនីតិរដ្ឋបាលទូទៅ, អនុបណ្ឌិត ហៀង សាង, ទំព័រ១៤៣។

បានកាត់យ៉ាងច្រើន ប្រសិនបើការិយាល័យឃុំ ( សាលាឃុំ ) ក៏ជាទីសំណាក់អាស្រ័យរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ( មេឃុំ ចៅសង្កាត់ ) នោះ ។

សាលាឃុំប្រសើរបំផុត គួរតែជាអគារសាធារណៈមួយដែល អាចផ្តល់សិទ្ធិចេញចូលសម្រាប់ប្រជាពលរដ្ឋបោះឆ្នោត និងទំនាក់ទំនងការងារក្នុងដែនឃុំសង្កាត់របស់ខ្លួន ។ នៅពេលដែលសាលាឃុំ សង្កាត់ជាផ្ទះរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់នោះមានភាពខុសគ្នារវាងសាធារណៈ និង ឯកជនភាពមានភាពស្រពិចស្រពិលខ្លាំង ។ ការបារម្ភជាចុងក្រោយនោះ គឺសំដៅថាច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់មិនបានបង្កើតឲ្យមានឯកជននិងមានទំនាក់ទំនងដ៏ខ្លាំងក្លាណាមួយរវាងថ្នាក់ឃុំ សង្កាត់ និង ភូមិ ( អ្នកភូមិ ) នៅក្នុងរង្វង់ឃុំនោះទេ។

ខណៈដែលបទប្បញ្ញត្តិដែលបានពិពណ៌នាខាងលើតម្រូវឲ្យមានការជ្រើសរើសតាំងមេភូមិនោះ។ ច្បាប់នេះទៀតសោធមិនបានផ្តល់មាគ៌ាណាមួយទេ ដើម្បីជ្រើសរើសមេភូមិ ដែលប្រជាពលរដ្ឋមានសិទ្ធិទទួលបានសិទ្ធិតំណាងនៅថ្នាក់ភូមិរបស់ខ្លួននោះ ( មេភូមិ ) ។[16]

### ៣.២.២. ការចូលរួម និងសង្គមស៊ីវិល

ការធ្វើអន្តរកម្មសកម្មភាព រវាងរដ្ឋាភិបាល និងអង្គការចាត់តាំងសង្គមស៊ីវិលនានាដែលបានបកស្រាយពីវិមជ្ឈការបានអះអាងជាមូលដ្ឋានថា ការចូលរួមកាន់តែច្រើនក្នុងដំណើរការនៃការអនុវត្តអភិបាលកិច្ចរបស់ប្រជាពលរដ្ឋ គឺមានឥទ្ធិពលខ្លាំងជាមួយផ្នែកចិត្តវិទ្យា។ បញ្ហានេះបានជួបប្រទះច្រើននៅក្នុងបរិបទនៃប្រទេសកម្ពុជា ដែលការចូលរួមនានាត្រូវបានបំបាក់ទឹកចិត្តជាប្រពៃណីដល់ប្រជាពលរដ្ឋក្នុងសង្គម និងទទួលយកដោយគ្មានការតវ៉ា នូវការសម្រេចចិត្តនានារបស់អ្នកដឹកនាំរបស់ខ្លួន ។ ជាទូទៅស្ថាប័នរដ្ឋាភិបាលមិនសូវមានការឆ្លើយតបនូវសេចក្តីត្រូវការដ៏ប្រសើរចំពោះមុខនោះទេ លុះត្រាតែមានសម្ពាធពីថ្នាក់ក្រោម ។ សម្រាប់កម្ពុជាដែលពុំធ្លាប់ទម្លាប់មានសង្គមស៊ីវិលជួយដាក់សំពាធលើរដ្ឋាភិបាល ឲ្យមានការឆ្លើយតបកាន់តែប្រសើរនោះ ការកើតមាននូវតួនាទីស្របច្បាប់ដ៏សំខាន់មួយសម្រាប់ NGOs ក្នុងការចូលរួមសម្របសម្រួលរាល់សកម្ម ភាពផ្សេងៗរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងអាជ្ញាធរដែលអាចជំរុញឲ្យមានការឆ្លើយតបនានាឲ្យកាន់ តែមានប្រសិទ្ធភាពឡើង ។

### ៣.២.៣. ការរៀបចំចាត់ចែងសារពើពន្ធ

ការផ្តល់អំណាចមកថ្នាក់មូលដ្ឋាន មិនត្រូវបានធានាថា អំណាចដែលបានផ្តល់ឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការកំណត់យកពន្ធផ្សេងៗ នៅមូលដ្ឋានមានប្រសិទ្ធិភាពនោះទេ។ សម្ពាធរវាងឃុំ សង្កាត់អ្នកមាន និងឃុំសង្កាត់អ្នកក្រីក្រ ( ឃុំនៅជនបទ និងសង្កាត់នៅទីក្រុងដែលសម្បូរភោគទ្រព្យ ) ដែលនេះជាការធានាធ្វើយ៉ាងណាឲ្យឃុំ សង្កាត់មានតុល្យភាពរបស់ខ្លួនក្នុងការដោះស្រាយរាល់បញ្ហាប្រមូលសារពើពន្ធនេះ។ កត្តានេះអាចធ្វើឲ្យរដ្ឋបាលឃុំ សង្កាត់កាន់តែមានការប្រយ័ត្នប្រយែងខ្ពស់ ចំពោះបញ្ហានានាដូចជា ការប្រមូលពន្ធ វិធានការ

[16] សៀវភៅប្រព័ន្ធវិមជ្ឈការដែនដី, ឆ្នាំ២០១២, ទំព័រ២១។

សមភាព ដែលត្រូវការយកមកអនុវត្ត និង ការរៀបចំសារពើពន្ធ ចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងស្ថានភាពក្រីក្រ ។

ចំណូលផ្ទាល់ខ្លួនរបស់ឃុំ សង្កាត់ ( មូលនិធិដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រមូលបានក្នុងមូលដ្ឋានរបស់ខ្លួន ) ជាប្រភពផ្តល់មូលនិធិយ៉ាងសំខាន់សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ថ្មី ។ លទ្ធផលដែលទទួលមានដូចតទៅ

- ទីមួយ គឺជាក្រុមប្រឹក្សាដែលមានថវិការតិច ឬគ្មានសោះនឹងបាត់បង់ការគាំទ្រពីនិវេសន៍ជន បទមូលដ្ឋានរបស់ពួកគេ។
- ទីពីរ អង្គការចាត់តាំងផ្សេងៗដូចជា NGOs សមាគមដែលមានមូលនិធិច្រើនជាង អាចត្រូវបានចាត់ទុកអង្គការអភិវឌ្ឍមូលដ្ឋាន ( CBOs ) សំខាន់ច្រើនជាងក្រុមប្រឹក្សាដែលបានជាប់ឆ្នោតថ្មី ។
- ទីបី ឃុំសង្កាត់ដែលមាន មូលដ្ឋានប្រមូលសារពើពន្ធ ក្នុងមណ្ឌលបោះឆ្នោតរបស់ពួកគេប្រសើរជាងឃុំ សង្កាត់ដទៃទៀត ចន្លោះគម្លាតរវាងឃុំ សង្កាត់មានទ្រព្យ និង ឃុំ សង្កាត់ដែលគ្មានទ្រព្យកាន់តែមានគម្លាតឆ្ងាយពីគ្នា ។

ប្រសិនបើគ្មានរូបមន្តដ៏ស័ក្តសិទ្ធិមួយ សម្រាប់ការផ្ទេរសារពើពន្ធពីរដ្ឋបាលកណ្តាល ដែលមានវិធានការសមភាពច្បាស់លាស់ ការរៀបចំផ្តល់មូលនិធិ នឹងរើសអើងដោយជៀសមិនរួច ចំពោះឃុំ សង្កាត់ដែលមានទំហំតូច ( ក្រីក្រ ) ឬឃុំ សង្កាត់ដែលនៅឆ្ងាយដាច់ស្រយាល ដែលមិនមានសមត្ថភាពគ្រប់គ្រាន់ប្រមូលពន្ធដូចឃុំ សង្កាត់ធំ ( មានទ្រព្យសម្បត្តិច្រើន ) ។

ការទទួលខុសត្រូវខាងសារពើពន្ធ ជាធាតុផ្សំយ៉ាងសំខាន់បំផុតនៃវិមជ្ឈការ ព្រោះរដ្ឋបាលមូលដ្ឋានត្រូវតែមានចំណូលគ្រប់គ្រាន់(ដែលប្រមូលបាននៅមូលដ្ឋានផ្ទាល់ ឬបញ្ជូនពីរដ្ឋមូលកណ្តាល) ដើម្បីធ្វើការសម្រេចចិត្តលើការចំណាយសេវាកម្មនានារបស់ឃុំ សង្កាត់របស់ខ្លួន។ វិមជ្ឈការសារពើពន្ធមានទម្រង់ជាច្រើនដែលអាចត្រូវបានសង្ខេបដូចខាងក្រោម៖

- ហិរញ្ញប្បទានផ្ទាល់ខ្លួន ឬការទូទាត់ចំណាយតាមការយកថ្លៃសេវាអ្នកប្រើប្រាស់។
- ការពង្រីកប្រាក់ចំណូលក្នុងមូលដ្ឋាន តាមរយៈការយកពន្ធអាករ និងការយកសេវាថ្លៃសេវាកម្មដោយប្រយោល។
- ការផ្ទេរហិរញ្ញប្បទានដែលមានលក្ខណៈអន្តរកាលរដ្ឋបាល។
- ការផ្តល់អំណាចក្នុងការខ្ចីហិរញ្ញប្បទាប ដើម្បីបម្រើមូលដ្ឋាន។

### ៣.២.៤. ប្រភពចំណូលរបស់ឃុំ សង្កាត់

- **ចំណូលមូលនិធិឃុំ សង្កាត់**

ចំណូលមូលនិធិឃុំ សង្កាត់មានការរួមចំណែកពីចំណូលចរន្តពីថវិការដ្ឋ ការចូលរួមពីជំនួយឥតសំណង និង ការខ្ចីបានពីម្ចាស់ជំនួយ និង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាជាដើម ហើយការចំណាយរបស់មូលនិធិឃុំ សង្កាត់ គឺបានពីការផ្ទេរប្រចាំឆ្នាំទៅក្នុងថវិការឃុំ សង្កាត់ ។

សមាសភាគរបស់មូលនិធិឃុំ សង្កាត់ គឺជាធនធានសរុបនៃមូលនិធិដែលចែកចេញជាពីរសមាសភាគ ដូចទៅ៖ សមាសភាគរដ្ឋបាលទូទៅដែលមានចំនួនច្រើនជាងមួយភាគបី ( ១/៣ ) ធន ធាននៃសមាសភាគនេះ គឺជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបំពេញមុខងាររដ្ឋបាលទូទៅលើការចំណាយប្រតិបត្តិការ និងវិនិយោគ ដោយរដ្ឋបាលឃុំ សង្កាត់ បៀវត្សសម្រាប់មន្ត្រីឃុំ សង្កាត់ ការ ជួល ឬ ការទិញទីតាំង និងសម្រាប់ការចំណាយ ទៅលើសម្ភារៈ និងចំណាយផ្សេងៗទៀតរបស់ ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ធនធានសមាសភាគនេះ ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការការបំពេញបានការទទួលខុសត្រូវ សម្រាប់លើកស្ទួយសេដ្ឋកិច្ចមូលដ្ឋាន កិច្ចអភិវឌ្ឍន៍សង្គម និង សុខុមាលភាពទូទៅរបស់ប្រជាពលរដ្ឋនៅមូល ដ្ឋានដូចជា ការសង្កេត គំនូសប្លង់ ការកសាង ការជួសជុល ការថែទាំផ្លូវ ផ្សាលូទឹក មណ្ឌលសុខភាព សាលា រៀន សហគមន៍ សំណង់ធារាស្ត្រ ឃ្លាំងផ្ទុកកសិផល ប្រព័ន្ធផ្គត់ផ្គង់ទឹក និងហេដ្ឋារចនាសម្ពន្ធ សេដ្ឋកិច្ច សង្គម ផ្សេងទៀត ការចំណាយលើមន្ត្រី/បុគ្គលិក និងចំណាយចរន្តដែលពាក់ព័ន្ធប្រតិបត្តិការហេដ្ឋារចនាសម្ពន្ធមូល ដ្ឋាន និងការផ្តល់សេវាចំណាយគាំទ្រលើកកម្មវិធីអភិវឌ្ឍន៍សហគមន៍ ដែលចាត់ចែងដោយអង្គការមិនមែនរដ្ឋាភិ បាលនៅមូលដ្ឋាន និងអង្គការជួយសហគមន៍ រួមទាំងយុទ្ធនាការផ្តល់ព័ត៌មាន និងអប់រំសម្រាប់ស្ត្រី និងយុវវ័យ នៅមូលដ្ឋាន ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងកម្មវិធីដទៃទៀតដែលមានឥទ្ធិពលដល់ សុខភាព សង្គម និងប្រជាពលរដ្ឋដែលនៅក្នុងមូលដ្ឋាន ។[17]

- **ចំណូលផ្ទាល់ឃុំ សង្កាត់**

ឃុំ សង្កាត់មានថវិកាផ្ទាល់ដែលបានមកពីប្រភពចំណូលផ្សេងៗនៅក្នុងឃុំ សង្កាត់ផ្ទាល់ ដូចជា កម្រៃសេវា ផ្សេងៗ លើដីធ្លី ឬ អគារសារពើពន្ធមូលដ្ឋានដែលបានទទួលពីការអនុវត្តតួនាទីរបស់ខ្លួន ក្នុងនាមអាជ្ញាធរដែនដី លើកម្រៃសេវាលើលិខិតរដ្ឋបាលផ្សេងៗ នៅក្នុងដែនដីរបស់ខ្លួន និងទម្រង់បែបបទផ្សេងៗទៀតដែលពាក់ពន្ធ ជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរឃុំ សង្កាត់ ។[18]

---

[17] សន គីណាល់, កម្មវិធីសិលា ( វិមជ្ឈការនៅកម្ពុជា ), ២០០២។

[18] សៀវភៅប្រព័ន្ធវិមជ្ឈការដែនដី, ឆ្នាំ២០១២, ទំព័រ២៤។

- **ចំណូលមុខងារជាភ្នាក់ងារ**

ឃុំ សង្កាត់មានសិទ្ធិក្នុងការទទួលបាន ចំណូលដែលបានមកពីកា របំពេញភារកិច្ចដោយឃុំ សង្កាត់ ជំនួស ស្ថាប័នកណ្តាលរដ្ឋបាលខេត្ត ក្រុង និងស្ថាប័នដទៃទៀតដែលហៅថា ចំណូលមុខងារជាភ្នាក់ងារ។ និយាយរួម គឺ ការបំពេញភារកិច្ចក្នុងនាមជារាជរដ្ឋាភិបាលជាតិ ដែលមានឈ្មោះថា " មុខងារជាភ្នាក់ងារ " ។[19]

## ៣.៣ កំណែទម្រង់ប្រព័ន្ធវិមជ្ឈការ

តម្រូវឱ្យមានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីអភិវឌ្ឍមូលដ្ឋានកាន់តែល្អប្រសើរ កំណែទម្រង់វិមជ្ឈការ ជាកំណែទម្រង់ក្នុងវិស័យអភិបាលកិច្ចដ៏មានសារៈសំខាន់របស់រាជរដ្ឋាភិបាល ដោយផ្តោតសំខាន់លើការរៀបចំ ឡើងវិញ នូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិដោយឈរលើគោលការណ៍នៃរដ្ឋបាលឯកភាព និងការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។កំណែទម្រង់នេះបានលើកកម្ពស់ដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍ មូលដ្ឋានឆ្លើយតបទៅ នឹងតម្រូវការជាក់ស្តែង របស់ប្រជាពលរដ្ឋ និងរួមចំណែកកាត់បន្ថយភាពក្រីក្រ ប្រកបដោយប្រសិទ្ធភាព។

ដើម្បីធ្វើឱ្យកំណែទម្រង់វិមជ្ឈការ ទទួលបាននូវភាពជោគជ័យ គឺការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ច ដំណើរនេះ គឺជាធាតុផ្សំមួយយ៉ាងសំខាន់មិនអាចខ្វះបាន។ ការចូលរួមពីប្រជាពលរដ្ឋប្រៀបបានដូចជា ត្រីវិស័យ មួយសម្រាប់ចង្អុលបង្ហាញផ្លូវដល់អាជ្ញាធរថ្នាក់ក្រោមជាតិ ឱ្យអាចធ្វើសេចក្តីសម្រេចចិត្តបានគ្រប់ជ្រុងជ្រោយ នឹងឈានទៅការអភិវឌ្ឍមូលដ្ឋានដើម្បី ឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋ។

តាមការលើកឡើងរបស់ឯកឧត្តម តូច ពលពន្លក ទីប្រឹក្សាក្រសួងមហាផ្ទៃមានប្រសាសន៍ថា កំណែ ទម្រង់វិមជ្ឈការ ឬការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិមានសារៈសំខាន់ខ្លាំងណាស់ចំពោះការអភិវឌ្ឍមូលដ្ឋាន ព្រោះបានបង្កិតការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានឱ្យកៀកជិតប្រជាពលរដ្ឋ បង្កើនការ ទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ ពិសេសលើកកម្ពស់ការចូលរួម របស់ប្រជាពលរដ្ឋក្នុងកិច្ចអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ លោកបន្ថែមថា ការចូលរួមពីពលរដ្ឋក្នុងកំណែទម្រង់វិម ជ្ឈការ នេះគឺជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដើម្បីអាចទទួលបានព័ត៌មាន នានាអំពីតម្រូវការ បញ្ហាប្រឈម បំណងប្រាថ្នា បទពិសោធន៍ គំនិតយោបល់ពីប្រជាពលរដ្ឋ ឆ្លើយតបនឹងតម្រូវ ការរបស់ពលរដ្ឋ។

លោកបានបន្ថែមទៀតថា បច្ចុប្បន្នលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) កំពុងសហការជាមួយនឹងកំណែទម្រង់ពីរផ្សេងទៀត គឺកំណែ ទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីរៀបចំកែសម្រួលនូវរចនាស ម្ព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ស្រុក ដោយធ្វើសមាហរណកម្មការិយាល័យជំនាញនានារបស់ក្រសួងនៅថ្នាក់ស្រុកចូល ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ក្នុងគោលបំណងប្រែក្លាយរដ្ឋបាលក្រុង ស្រុកឱ្យទៅជារដ្ឋបាល

[19] សៀវភៅប្រព័ន្ធវិមជ្ឈការដែនដី, ឆ្នាំ២០១២, ទំព័រ២៤។

មូលដ្ឋានច្បាស់លាស់មួយដែលមានសក្តានុពល ដែលអាចប្រមូលផ្តុំទាំងធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានកាន់តែមានប្រសិទ្ធភាព ។ជាផ្នែកមួយនៃការបង្កើតការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព កាន់តែជៀកប្រជាពលរដ្ឋ រាជរដ្ឋាភិបាលបានសម្រេចអនុម័តអនុក្រឹត្យលេខ២៨៥ ស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤។

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការប្រើប្រាស់នូវសិទ្ធិអំណាចសម្រាប់អនុវត្តមុខងារជាជម្រើសរបស់ខ្លួន សំដៅលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងសមធម៌ ឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ដោយឈរលើស្មារតីនេះ រាជរដ្ឋាភិបាលបានដៅវិស័យជាអាទិភាពសំខាន់ៗមួយចំនួន ដើម្បីការអភិវឌ្ឍមូលដ្ឋានក្នុងដំណើរការកែទម្រង់ប្រព័ន្ធវិមជ្ឈការ ។ វិស័យទាំងនោះ រួមមាន វិស័យកសិកម្ម អប់រំ បរិស្ថាន សុខាភិបាល ហេដ្ឋារចនាសម្ព័ន្ធ ទេសចរណ៍ ធារាសាស្ត្រ សង្គមកិច្ច និងសេដ្ឋកិច្ចជាដើម។

ដើម្បីចូលរួមចំណែក ក្នុងដំណើរការ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់នៃខេត្តនីមួយ បានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍ លើវិស័យជាអាទិភាពនៅមូលដ្ឋានរបស់ខ្លួន ដូចជា វិស័យសង្គមកិច្ចនៅមូលដ្ឋាន ក្រុមប្រឹក្សាក្រុងបានបង្កើតគណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ដើម្បីជួយដោះស្រាយបញ្ហាស្ត្រី និងកុមារតាមមូលដ្ឋាន។

នៅក្នុងនោះដែលបញ្ហាស្ត្រីក្រីក្រដែលខ្វះលទ្ធភាពគឺយើងជួយឧបត្ថម្ភគាត់ ដូចជា ការមកសម្រាលកូននៅមណ្ឌលសុខភាព។ មួយវិញទៀតយើងមានកម្មវិធីរបស់រដ្ឋាភិបាល គឺការប្រើប្រាស់ប័ណ្ណសមធម៌ ប័ណ្ណនេះគឺមានផលប្រយោជន៍ច្រើន ជាពិសេសទាក់ទងនឹងសុខភាព ពេលគាត់មានបញ្ហាសុខភាព គាត់ទៅទទួលសេវាតាមពេទ្យរដ្ឋ គឺមិនមានការបង់ប្រាក់ឡើយ។ មួយវិញទៀតប័ណ្ណសមធម៌នេះ ក៏អាចប្រើសម្រាប់ការអនុគ្រោះ ឬក៏ការលើកលែងថ្លៃសេវារដ្ឋបាលផ្សេងទៀតនៅតាមសង្កាត់ និងក្រុង។

ចំពោះការអភិវឌ្ឍវិស័យសេដ្ឋកិច្ចតាមមូលដ្ឋានវិញសង្កាត់ទាំងអស់សុទ្ធតែបានទទួលកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសកសិកម្មធន់នឹងអាកាសធាតុ ដែលកម្មវិធីនេះគាំទ្រដោយរាជរដ្ឋាភិបាល។ ដើម្បីឆ្លើយតបតាមកមូលដ្ឋានវិញការតបណ្តាញអគ្គិសនី និងទឹកស្អាតក្នុង បានពង្រីកទៅដល់ទីប្រជុំជន ដើម្បីបំពេញសេចក្តីត្រូវការរបស់ពលរដ្ឋនៅទីនោះ។

តាមរយៈការអភិវឌ្ឍលើវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច រាជរដ្ឋាភិបាលបង្ហាញការតាំងចិត្តថា "ផែនការទៅថ្ងៃអនាគត គឺការលើកកម្ពស់វិស័យសង្គមកិច្ចយើងនៅតែបន្តធ្វើ និងធ្វើឱ្យបានកាន់តែប្រសើរ តាមរយៈការពង្រឹងគុណភាពសេវាជូនប្រជាពលរដ្ឋ ដោយសារតួនាទីរបស់យើងគឺយើងអនុវត្តតាម តួនាទីភារកិច្ច។ អីចឹង! រាជរដ្ឋាភិបាលបច្ចុប្បន្នកំពុងតែសម្លឹងមើលក្នុងការផ្ទេរមុខងារ គឺយើងផ្ទេរមុខងារដែលបច្ចុប្បន្នមានក្រសួងអប់រំ

និងក្រសួងសុខាភិបាលដែលបានចេញអនុក្រឹត្យស្តីពីការផ្ទេរមុខងារហ្នឹង ហើយក្រសួងអប់រំមានការផ្ទេរមុខងារអប់រំកុមារតូចមកដល់រដ្ឋបាលមូលដ្ឋាន។ ចំណែកក្រសួងសុខាភិបាលក៏បានផ្ទេរមុខងារការគ្រប់គ្រងមណ្ឌលសុខភាពមកឱ្យថ្នាក់មូលដ្ឋាន ដែលកិច្ចការនេះសុទ្ធតែជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការបង្វិតសេវាក៏ដូចជា ការលើកកម្ពស់គុណភាពសេវាដល់ប្រជាពលរដ្ឋនៅមូលដ្ឋានផងដែរ" ។

ជាក់ស្តែង ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធនៅក្នុងក្រុងសៀមរាបកែលំអរផ្លូវចំនួន ៣៨ ខ្សែ ក្នុងក្រុងសៀមរាប ខេត្តសៀមរាបក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ផ្លូវទាំង៣៨ខ្សែនេះ មានប្រវែងសរុប ១០៨.៧៤គីឡូម៉ែត្រ ដោយគ្រោងប្រើប្រាស់ថវិកាជាតិសរុបប្រមាណ ១៤០លានដុល្លារអាមេរិក និងថវិកាជាង ៩លានដុល្លារអាមេរិកទៀត សម្រាប់ការងារចាំបាច់ក្នុងការរៀបចំស្ថាបនាប្រព័ន្ធបង្ហូរទឹកភ្លៀង និងទឹកកក្វក់ដែលនៅក្រៅគម្រោងសាងសង់ខ្សែផ្លូវទាំង៣៨នេះ។

តាមរយៈគម្រោងសាងសង់ផ្លូវទាំង៣៨ខ្សែនេះ នឹងធ្វើឲ្យទីក្រុងសៀមរាប ប្រែក្លាយរូបរាងជាទីក្រុងទំនើប និងទេសចរណ៍ ដ៏មានសក្តានុពល ដែលត្រូវបានរាជរដ្ឋាភិបាលកម្ពុជាកំណត់ជាតំបន់ស្នូលនៃប៉ូលអភិវឌ្ឍជាតិ ជាគោលដៅទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ និងធម្មជាតិ ស្របតាមរូបសាស្ត្រទីក្រុង រួមជាមួយការគិតគូរដល់ការការពារ និងកែលម្អបរិស្ថាន ជាសុកភាពរបស់ប្រជាពលរដ្ឋ និងការរៀបចំអភិវឌ្ឍទីក្រុងឆ្លាតវៃ (Smart City) ផងដែរ។ ទាំងនេះ គឺជាសមិទ្ធផលដែលកើតចេញពីគំនិតផ្តួចផ្តើមរបស់គណៈអភិបាលខេត្ត ដោយបានសិក្សាពីតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្នុងភូមិ។ នេះបើតាមការគូសបញ្ជាក់ពីរដ្ឋបាលខេត្តសៀមរាប ។

គម្រោងផ្លូវដែលយើងត្រូវធ្វើហ្នឹង យើងបានប្រមូលប្រជាពលរដ្ឋមកប្រជុំសិក្សាផលប៉ះពាល់ដីធ្លី ផលដំណាំគាត់ ដូច្នេះពេលគាត់ឯកភាពយើងចាប់ផ្តើមសិក្សាតែម្តង។ ភាគច្រើនពេលប្រជុំតែងតែលើកយកបញ្ហាហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវ ជីកស្រះ ស្ពារប្រឡាយ ដែលគាត់លើកផុលផុសច្រើន។ សព្វថ្ងៃប្រជាពលរដ្ឋចង់បានច្រើន តែថវិការបស់យើងមានតិចតួចមិនអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការទាំងអស់បាននោះឡើយ។

ជាពិសេសកសិករក្នុងមូលដ្ឋាន បានលើកឡើងថា បច្ចុប្បន្នហេដ្ឋារចនាសម្ព័ន្ធមានការអភិវឌ្ឍល្អប្រសើរជាងមុន បន្ទាប់ពីអាជ្ញាធរឃុំបានយកចិត្តទុកដាក់ដោះស្រាយរាល់សំណើ និងសេចក្តីត្រូវការរបស់ពលរដ្ឋ។ លើសពីនេះ ប្រជាពលរដ្ឋចង់ឱ្យក្រុមប្រឹក្សាឃុំបានលើកបញ្ហាជួបប្រទះ ជួយស្ពារ ប្រឡាយ និងជុសជុលផ្លូវលំដែលមានស្រាប់ ដើម្បីបម្រើសេចក្តីត្រូវការនៃការងារកសិកម្ម និងការដឹកជញ្ជូនកសិផលរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

ជុំវិញសារៈសំខាន់នៃការកៀរគរការចូលរួមរបស់ប្រជាពលរដ្ឋ ឯកឧត្តម តូច ពលពន្លក ទីប្រឹក្សាក្រសួងមហាផ្ទៃ បានផ្តល់អនុសាសន៍គន្លឹះមួយចំនួនដល់រដ្ឋបាលថ្នាក់ក្រោមជាតិថា រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋជាប្រចាំ ដើម្បីឱ្យបានដឹងពីការសម្រេចចិត្ត និងសកម្មភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លោកបន្តថា រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ស្វែងយល់ពីតម្រូវការ បញ្ហាប្រឈម ដើម្បីឈានទៅរកដំណោះស្រាយជូនប្រជាពលរដ្ឋ។ មួយវិញទៀតរដ្ឋបាលថ្នាក់

ក្រោមជាតិ គប្បីចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមផ្ទះ ជាពិសេសក្រុមគ្រួសារក្រីក្រ ដើម្បីបង្កើនទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ និងត្រូវចេះទទួលយកយោបល់ដោយមិនរើសអើងបក្សពួក។

ជាចុងក្រោយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបង្កើតទំនាក់ទំនងល្អជាមួយអង្គការសង្គមស៊ីវិល ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ បើយោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ដែលហៅកាត់ថា "គ.ជ.អ.ប" បានឲ្យដឹងថា ក្នុងរយៈពេលជិត២ទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលបានផ្ទេរថវិកាសរុបប្រមាណជាង២ពាន់លានដុល្លារអាមេរិក ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការចាត់ចែង ប្រើប្រាស់សម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

របាយការណ៍ដដែល បានបន្តថា ដោយផ្អែកលើធនធានទាំងនេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានអនុវត្តនូវគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តខ្នាតតូចជាច្រើន ដូចជា ផ្លូវលំជនបទ (ផ្លូវដី ផ្លូវក្រួសក្រហម ផ្លូវបេតុង និងស្ពាន) ប្រព័ន្ធស្រោចស្រព (ប្រឡាយ ទំនប់ទឹក និងសំណង់សិល្បការផ្សេងៗ) សំណង់អនាម័យជនបទ ( លូទឹក បង្គន់ និងប្រព័ន្ធបង្ហូរទឹក) សំណង់ផ្គត់ផ្គង់ទឹក ស្អាត (ស្រះទឹក អណ្តូងទឹក និងបណ្តាញទុយោទឹកស្អាត) សំណង់ផ្សេងៗទៀត (អគារសាលារៀនអគារ សុខាភិបាល អគារសង្គម សំណង់ផ្សារ និងសំណង់សម្រាប់ការពារទឹកជំនន់ បណ្តាញបង្ហូរសំណល់រាវតាមទីប្រជុំជន និងគម្រោងមិនមែនហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀតដូចជា ការលើកកម្ពស់ការផ្តល់សេវាសង្គមនានា ដូចជាអនាម័យជនបទ ការគាំពារមាតា និងទារក យេនឌ័រ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការចងក្រងសហគមន៍តាមមូលដ្ឋាន ដើម្បីលើកស្ទួយផលប្រយោជន៍ដល់ក្រុមជនងាយរងគ្រោះជាដើម) ។

របាយការណ៍ដដែល ក៏បានបញ្ជាក់ថា ទោះបីកំណែទម្រង់នេះ មានការវិវឌ្ឍទៅមុខជាលំដាប់ស្របតាមដំណាក់កាលនីមួយៗ ដូចបានកំណត់ក្នុងកម្មវិធីជាតិ រួមជាមួយនឹងការបង្កើតបាននូវសមិទ្ធផលជាច្រើនគួរឲ្យកត់សម្គាល់ក៏ដោយ ក៏បច្ចុប្បន្នកំណែទម្រង់នេះបាននិងកំពុងឈានចូលដល់ដំណាក់កាលកាន់តែស៊ីជម្រៅ និងកាន់តែសាំញ៉ាំ ទាំងក្នុងកិច្ចការនយោបាយ និងផ្នែកបច្ចេកទេសដែលទាមទារឲ្យបន្តពង្រឹងនូវការប្តេជ្ញាចិត្តខាងនយោបាយក្នុងរាជរដ្ឋាភិបាលទាំងមូល និងការពង្រឹងកិច្ចសហការ ការចូលរួម និងការគាំទ្រឲ្យកាន់តែខ្លាំងក្លាបន្ថែមទៀតក្នុងការបន្តអនុវត្តនូវកិច្ចដំណើរការកំណែទម្រង់ក្នុងដំណាក់កាលទី៣ នៃកម្មវិធីជាតិ ដើម្បីធានាឲ្យប្រព័ន្ធគ្រប់គ្រង នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យកាន់តែមានប្រសិទ្ធភាព កាន់តែឆ្លើយតប និងកាន់តែមានគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ ព្រមទាំងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ចូលរួមចំណែកកាត់បន្ថយនូវភាពក្រីក្រ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋទាំងមូល។

សូមរំឭកផងដែរថា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនឹងត្រូវចំណាយថវិកាប្រមាណមួយពាន់លានដុល្លារអាមេរិក សម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសម្រាប់រយៈពេលបីឆ្នាំ ពោគឺចាប់ពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០៕

# សេចក្តីសន្និដ្ឋាន

ផ្អែកទៅតាមការសិក្សាស្រាវជ្រាវ ពីដំណើរការនយោបាយវិមជ្ឈការរបស់ប្រទេសកម្ពុជា រួមមកយើងឃើញថាមានដំណើរការល្អបង្គួរ ព្រោះសកម្មភាព/សេវាដែលឃុំ ឬអង្គការ ស្ថាប័ននានាទាំងអស់បានឆ្លុះបញ្ចាំងពីដំណើរការអភិវឌ្ឍស្ទើរតែគ្រប់ផ្នែក គ្រប់វិស័យ ទាំងអស់របស់ថ្នាក់មូល ដ្ឋានដោយបានធ្វើឲ្យកាន់តែប្រសើរឡើងនូវវឌ្ឍនភាព និងការរីកចម្រើន ទៅថ្ងៃអនាគតរបស់ប្រជាពលរដ្ឋដែលនៅក្នុងមូលដ្ឋាន ។ ដោយសារតែនយោបាយវិមជ្ឈការ ជារឿងថ្មីសម្រាប់ថ្នាក់មូលដ្ឋានមែន តែសកម្មភាពរបស់ថ្នាក់មូលដ្ឋាន បានធ្វើឲ្យប្រជាពលរដ្ឋ និង សហគមន៍ទាំងមូលមានភាពប្រសើរឡើង តាមរយៈការអនុវត្តកិច្ចការនៅថ្នាក់មូលដ្ឋាន និង សហគមន៍ទាំងមូលមានភាពប្រសើរឡើង តាមរយៈការអនុវត្តកិច្ចការនៅថ្នាក់មូលដ្ឋាន និង ជាភ្នាក់ងារតំណាងរដ្ឋដែលសកម្មភាពទាំងនេះផ្តោតសំខាន់ទៅលើផ្នែករដ្ឋបាល និង សន្តិសុខ និងផ្នែកយេនឌ័រ ។

នយោបាយវិមជ្ឈការពិតជា ប្រព័ន្ធគ្រប់គ្រងដ៏ល្អប្រសើរបំផុតសម្រាប់ប្រទេសកម្ពុជា ជាពិសេសសម្រាប់ប្រជាពលរដ្ឋតាមមូលដ្ឋានតែម្តង ដោយហេតុថា ប្រព័ន្ធដឹកនាំតាមបែបវិមជ្ឈការគឺមានគោលដៅជា ចម្បងឆ្ពោះទៅរកការធ្វើឲ្យមានការទទួលខុសត្រូវ នៅកម្រិតថ្នាក់ក្រោមជាតិឲ្យកាន់តែច្រើន និងមានភាពជិតស្និទ្ធ ជាមួយប្រជាពលរដ្ឋនៅក្នុងដែនដីមូលដ្ឋាន ម្យ៉ាងទៀតអ្វី ដែលសំខាន់ទៅទៀតនោះ គឺការធ្វើឲ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានដូចជា អាជ្ញាធរដែនដី អង្គការ ស្ថាប័ន និងវិស័យឯកជននានា ជាពិសេសគឺការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងសហគមន៍មូលដ្ឋានផងដែរ ពីព្រោះថានយោបាយវិមជ្ឈការនឹងធ្វើឲ្យក្រុមប្រឹក្សាឃុំ មានលទ្ធភាពកាន់តែខ្លាំងក្នុងការឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងឃុំកាន់តែប្រសើរ ។

ក្រុមប្រឹក្សាឃុំបានបំពេញការងារបានយ៉ាងច្រើន នៅក្នុងមូលដ្ឋានរបស់ខ្លួនបើទោះបីការធ្វើសកម្មភាពមិនបានពេញលេញ ដើម្បីបម្រើនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក៏ដោយ។ បើយោងទៅលើការស្រាវជ្រាវបានបង្ហាញថា ការផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាឃុំ ដើម្បីបំពេញមុខងារផ្ទាល់ និងភ្នាក់ងារតំណាងរដ្ឋ។ ការបំពេញមុខងារនេះ នៅមានកម្រិតនៅឡើយ ដោយមើលឃើញយ៉ាងជាក់ស្តែងពី ការកង្វះធនធានមនុស្ស ធនធានថវិកា ធនធានសម្ភារៈ និងធនធានបច្ចេកទេស រីឯសេវាដែលឃុំ បានផ្តល់ឲ្យប្រជាពលរដ្ឋក្នុងឃុំ ជាសេវាកម្មដែលភាគច្រើនជាកិច្ចការសម្របសម្រួលនិង លិខិតស្នាមជាដើម ។

ទន្ទឹងនឹងភាពរីកចម្រើន និងចំណុចល្អខាងលើនេះ ឃុំ / ក្រុមប្រឹក្សាឃុំ ក៏មានចំណុចអវិជ្ជមានដែលជៀសមិនផុតដូចជា ប្រជាពលរដ្ឋមិនសូវមានការយល់ដឹងពីតួនាទី ការផ្តល់សេវាកម្មនានា និងភបូពជាម្ចាស់ដែនដីមូលដ្ឋាន ក្នុងការធ្វើឲ្យឃុំ មានការរីកចម្រើន និងមានកម្រិតជីវភាពរបស់ប្រជាពលរដ្ឋបានល្អប្រសើរនោះទេ។ តាមលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថាប្រជាពលរដ្ឋនៅតែមិនយល់ពីភាពចាំបាច់របស់ពួកគាត់ ក្នុងការចូលរួមរាល់សកម្មភាពអភិវឌ្ឍន៍នានារបស់ឃុំ ដូចជាការរៀបចំផែនការប្រចាំឆ្នាំ ការប្រជុំនានា និងសកម្មភាពផ្សេងទៀតក្នុងឃុំរបស់ខ្លួន ។ ការដែលប្រជាពលរដ្ឋមិនបានចូលរួមរាល់សកម្មភាពរបស់ឃុំនោះ នឹងធ្វើឲ្យដំណើរ

ការងារអភិវឌ្ឍន៍ដូចជាបញ្ហា ឬឧបសគ្គធ្ងន់ធ្ងរ គឺការយល់មិនពេញចិត្តនឹងសេវាកម្មដែលមិនបានឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ពួកគាត់ ។

ឯកសារគតិយុត្តិ ច្បាប់មួយចំនួនដែលចេញដោយស្ថាប័នព្រះមហាក្សត្រ រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងអន្តរក្រសួងនានា បានបង្ហាញឲ្យឃើញថា ភាពសម្បូរបែបជាច្រើនក្នុងការឲ្យឃុំ ជានីតិបុគ្គលក្នុងស្មារតីបម្រើដល់ដែនដីមូលដ្ឋាន ប៉ុន្តែឯកសារទាំងនោះគឺចេញដោយមិនមានលក្ខណៈជាប្រព័ន្ធ និងពិបាកយល់សម្រាប់ឃុំ ដែលចំណេះដឹងរបស់ឃុំនៅកម្រិតនៅឡើយនោះ ។

សរុបសេចក្តីមក យើងឃើញអាចធ្វើការសន្និដ្ឋានបានថា ថ្វីត្បិតមានសកម្មភាពអសកម្មមួយចំនួនយ៉ាងណាក៏ដោយ ក៏ឃុំនៅតែសម្រេចបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលខ្លះដែរដូចជា សេវាផ្នែករដ្ឋបាល និងសន្តិសុខ សការផ្សព្វផ្សាយពីច្បាប់ ទាក់ទងនឹងបរិស្ថាន យេនឌ័រ នឹងកិច្ចការសម្របសម្រួលកិច្ចការរបស់ប្រជាពលរដ្ឋ ( អត្រានុកូលដ្ឋាន ) កិច្ចការសម្របសម្រួលដល់អង្គការ ឬ ស្ថាប័ន ដែលជាដៃគូអភិវឌ្ឍន៍នានារបស់ឃុំជាដើម។ កិច្ចការទាំងនេះបានធ្វើឲ្យប្រសើរឡើងដូច្នេះ ប្រព័ន្ធគ្រប់គ្រងតាមនយោបាយវិមជ្ឈការ នឹងធ្វើឲ្យប្រជាពលរដ្ឋនៅក្នុងឃុំទាំងមូល មានកម្រិតជីវភាពបានល្អប្រសើរឡើង នូវទៅតាមដំណាក់កាលនៃភាពកាន់តែរឹងមាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ( ថ្នាក់មូលដ្ឋាន ) និងប្រជាពលរដ្ឋកាន់តែមានការយល់ពីតម្លៃនៃ ការចូលរួមសកម្មភាពនានាក្នុងការអភិវឌ្ឍនៅមូលដ្ឋាន ។ ជាងនេះទៅទៀតសម្រាប់ប្រទេសកម្ពុជាទាំងមូលនឹងកាន់តែមានវឌ្ឍនភាព នឹងរីកចម្រើនលើគ្រប់វិស័យ ។

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ អំពីដំណើរការនយោបាយវិមជ្ឈការ នៃការអភិវឌ្ឍ របស់ប្រទេសកម្ពុជា មកយើងឃើញថា នៅថ្នាក់មូលដ្ឋានយើងបានឃើញនូវចំណុចខ្វះខាតមួយចំនួន ដែលគួរតែធ្វើការកែលម្អដូចតទៅ ៖

- គ្រប់បណ្ដាអន្តរក្រសួង ឬស្ថាប័នដែលមានការពាក់ព័ន្ធ គឺគួរមានការយកចិត្តទុកដាក់ខ្ពស់ទៅលើការពង្រឹង និងធ្វើការការបណ្ដុះបណ្ដាលនូវធនធានមនុស្ស ( ក្រុមប្រឹក្សាឃុំ ) បង្កើនការងារបច្ចេកទេស និងផ្ដល់សម្ភារៈឲ្យ បានគ្រប់គ្រាន់ដើម្បីធ្វើការធានា និងជំរុញការងារ ( សេវាកម្ម ) របស់ក្រុមប្រឹក្សាឃុំ ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។
- កិច្ចការរបស់ក្រុមប្រឹក្សាឃុំ គឺត្រូវតែមានទំហំធំ សម្រាប់ដែនដីគ្រប់គ្រងរបស់ខ្លួន ដូច្នេះថវិកាជាតិប្រចាំឆ្នាំគឺគួរតែផ្ដល់ឲ្យបាន គ្រប់គ្រាន់ក្នុងបំពេញការងារ ជាភ្នាក់ងារបម្រើកិច្ចការថ្នាក់មូលដ្ឋាន និងជាភ្នាក់ងារតំណាងរដ្ឋ និងគួរមានការលើកទឹកចិត្តដល់ក្រុមប្រឹក្សាឃុំ សង្កាត់ រាជធានី ខេត្ត ក្រុង ទៅលើសម្ភារៈ ស្មារតី និងជាពិសេសថវិកា ដើម្បីធ្វើឲ្យក្រុមប្រឹក្សានោះមាន ឆន្ទៈខ្ពស់ក្នុងការបម្រើការងារឲ្យកាន់តែបានល្អប្រសើរ និងផ្ដល់ផលប្រយោជន៍ជូនប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូល ។
- ការផ្ទេរសិទ្ធិ អំណាច ការគ្រប់គ្រង និងធនធានមួយចំនួនពីរដ្ឋបាលថ្នាក់ជាតិ ( រដ្ឋបាលថ្នាក់កណ្ដាល ) មិនបានពេញលេញ ដែលជាបញ្ហាធ្វើឲ្យ ការបំពេញការងារនៅថ្នាក់មូលដ្ឋាននៅមាន កម្រិត។ ហេតុដូច្នេះហើយ រាជរដ្ឋាភិបាល និងអន្តរក្រសួង គួរទំលាក់នូវប្រតិកម្មមុខងារឲ្យបានច្រើនទៅតាមទំហំការងារ និងដែនដីវិសាលភាពរដ្ឋបាលរបស់ឃុំ ។
- ក្នុងដំណើរការនៃការអភិវឌ្ឍរបស់ឃុំ សង្កាត់ គ្រប់ក្រសួង ឬគ្រប់ស្ថាប័នដែលមានការពាក់ព័ន្ធ គួរតម្រូវឲ្យមានស្ត្រីចូលរួមឲ្យបានច្រើនគ្រប់វិស័យ ( ផ្នែក ) ទាំងប្រាំ ជាពិសេសផ្នែកសេដ្ឋកិច្ច និងការថែរក្សាសណ្ដាប់ធ្នាប់ តាមរយៈការកសាងសមត្ថភាព និងលើកទឹកចិត្តស្ត្រីឲ្យបានចូលរួមគ្រប់សកម្មភាពរបស់មូលដ្ឋាន ។
- រាល់ការសិក្សាវិស័យអាទិភាព និងកិច្ចអភិវឌ្ឍនានា គួរតែមានការចូលរួមយ៉ាងពេញលេញពីប្រជាពលរដ្ឋ ដើម្បីបង្ហាញសេចក្ដីត្រូវការ គំនិតយោបល់ ធនធានថវិកា ស្មារតី និងធនធានសម្ភារៈមួយចំនួនដើម្បីប្រមូលកម្លាំងជាធ្លុងមួយក្នុងការស្ថារ និងកសាងឲ្យសហគមន៍ និងសង្គមជាតិប្រកបដោយស្ថិរភាព និងវឌ្ឍនភាពជានិរន្តរ៍។

- អង្គការ និងស្ថាប័នពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាទាំងអស់ គួរមានសមត្ថកិច្ច និងសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពការងាររបស់ឃុំ អង្គការ ឬ ស្ថាប័នទាំងឡាយ ដើម្បីធានាកិច្ចការអភិវឌ្ឍឲ្យមានប្រសិទ្ធភាព និងប្រកបដោយនិរន្តរ៍ភាព ។
- អាជ្ញាធរមូលដ្ឋាន គួរលើកទឹកចិត្តបន្ថែមទៀតដល់វិនិយោគទុន ជាសាធារណៈ និងវិស័យឯកជន ដើម្បីឲ្យគេពេញចិត្តក្នុងការជួយដល់មូលដ្ឋានរបស់ខ្លួន ។
- ប្រព័ន្ធបណ្តាញផ្សព្វផ្សាយ និងប្រព័ន្ធទទួលព័ត៌មានទាំងឡាយ គួរជំរុញឲ្យបានដល់គ្រប់ទិសទីក្នុងមូលដ្ឋាន ។

# គន្ថនិទ្ទេស


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខេត្ត ឆ្នាំ ២០០៨
- សៀវភៅនីតិរដ្ឋបាលទូទៅ របស់បណ្ឌិត សាយ បូរី
- សៀវភៅនីតិរដ្ឋបាលទូទៅ របស់អនុបណ្ឌិត ហៀង សាង
- គ.ជ.វ.វ ខែ ឧសភា ឆ្នាំ ២០០៨
- សន្ទានុក្រម, ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨
- សៀវភៅ វិមជ្ឈការនៅប្រទេសកម្ពុជា ( លី វ៉ុង ) ឆ្នាំ២០១៧
- កម្មវិធីសិលា  សន គីណាល់ ( វិមជ្ឈការនៅកម្ពុជា ) ឆ្នាំ ២០០២
- អង្គការពុទ្ធសាសនាដើម្បីការអភិវឌ្ឍ ឆ្នាំ២០០៩
- ក្រសួង ផែនការ , ឆ្នាំ២០០៩
- សៀវភៅប្រព័ន្ធវិមជ្ឈការដែនដី ឆ្នាំ២០១២
- http://www.toupie.org/Dictionaire/Decentrazation.htm
- Rondinelli, What is Decentralization? World Bank Institute 1999

# ឧបសម្ព័ន្ធ

# និតិរដ្ឋបាលទូទៅ

# Droit Administratif Général



បណ្ឌិត **សាយ បូរី**

Say Bory

បោះពុម្ពលើកទី៤
4e Edition

ក្របសៀវភៅដើម

## ២. សហគ្គិភាព វិមជ្ឈការ-វិសហមជ្ឈការ

### ក.ដោះស្រាយបញ្ហា

**អត្ថបទទី ៣៥១**

ដើម្បីដោះស្រាយបញ្ហាដែលកើតមកពីគុណវិបត្តិនៃវិមជ្ឈការសុទ្ធសាធពេកនេះ គេមានរូបមន្តមួយថ្មី គឺធ្វើយ៉ាងណា ឱ្យមានសហគ្គិភាពវិមជ្ឈការ-វិសហមជ្ឈការ នៅគ្រប់ទីកន្លែង។ និយាយឱ្យងាយយល់ គឺថាអំណាចរាស្ត្រនិងអំណាចរដ្ឋត្រូវនៅជាមួយគ្នា ដើម្បីជួយគ្នាទៅវិញទៅមក ។ រដ្ឋជួយឃុំ ឃុំជួយរដ្ឋ ។

### ខ.ជួយគ្នាទៅវិញទៅមក

**អត្ថបទទី ៣៥២**

រដ្ឋជួយឃុំ ក្នុងរឿងបច្ចេកទេសគ្រប់វិស័យ (ពន្យល់ច្បាប់គ្រប់បែបយ៉ាង ផ្តល់បច្ចេកទេស និងមធ្យោបាយក្នុងការបណ្តុះបណ្តាលធនធានមនុស្ស) និងក្នុងរឿងទំនាស់រវាងឃុំនិងឃុំ ឬរវាងឃុំនិងអង្គការវិមជ្ឈការណាមួយផ្សេង។ រដ្ឋដើរតួនាទី ជាអ្នកសម្របសម្រួលនិងសម្រុះសម្រួល ។

ឃុំជួយរដ្ឋ ក្នុងបញ្ហាទាំងឡាយដែលនៅក្នុងវិស័យរបស់រដ្ឋ តាមការស្នើសុំពីរដ្ឋ (ជួយទារពន្ធដារឱ្យរដ្ឋ ឬធ្វើការសហការជាមួយរដ្ឋ ក្នុងគំរោងអភិវឌ្ឍន៍ផ្សេងៗ) ។

### គ.ឧស្សរៈវិស័យ

**អត្ថបទទី ៣៥៣**

ពេលណាគេជម្រុញវិមជ្ឈការឱ្យកាន់តែខ្លាំង (គឺ ថា អំណាចវិមជ្ឈការកាន់តែធំទូលាយ) គេត្រូវពង្រីកប្រព័ន្ធអំណាចវិសហមជ្ឈការ ឱ្យកាន់តែរីកសុះសាយ ទូលំទូលាយខ្លាំងឡើងជាមួយគ្នាដែរ ក្នុងគោលដៅសហគ្គិភាពដើម្បីវឌ្ឍនភាព មិនមែនដើម្បីគាបសង្កត់ទេ ។

ប្រទេសបារាំងបានធ្វើវិសោធនកម្មទៅលើគំនិតនេះរួចហើយ តាំងពីឆ្នាំ ១៩៨២ មកម្ល៉េះ ។ ច្បាប់ចុះថ្ងៃទី២មិនា១៩៨២ពង្រីកអំណាចវិមជ្ឈការកាន់តែខ្លាំងធំឡើង ដោយបានលុបបំបាត់អំណាចអាណាព្យាបាលរបស់រដ្ឋលើសមូហភាពវិមជ្ឈការ ទុកឱ្យតុលាការរដ្ឋបាលត្រួតពិនិត្យជាបច្ឆាកាល លើនីត្យានុកូលភាព ។ ប៉ុន្តែ ទន្ទឹមនឹងច្បាប់នេះ មានបទបញ្ញាតម្លៃតាម "ដេក្រេ" ចុះថ្ងៃទី ១ កក្កដា ១៩៩២ ស្តីពី "ធម្មនុញ្ញនៃ វិសហមជ្ឈការ" (charte de la déconcentration)ដែលបានប្រគល់តួនាទីយ៉ាងសំខាន់ដល់លោក« អភិបាលខេត្ត» "ប្រេហ្វេ" ក្នុងឋានៈជាតំណាងរដ្ឋ ក្នុងសមូហភាពដែនដី ។

## ៣ .វិមជ្ឈការបច្ចេកទេស

**<u>អត្ថបទទី ៣៥៤</u>**

វិមជ្ឈការបច្ចេកទេស (décentralisation technique) ដែលគេអាចហៅម្យ៉ាងទៀតថា វិមជ្ឈការតាមសេវាកម្ម (décentralisation par service) គឺជារបៀបគ្រប់គ្រងសេវាកម្មសាធារណៈមួយបែប ដែលគេប្រគល់សកម្មភាពបច្ចេកទេសណាមួយ របស់រដ្ឋ ឬ របស់សមូហភាពវិមជ្ឈការទៅឱ្យនីតិបុគ្គលសាធារណៈប្រភេទថ្មីមួយធ្វើ ដោយស្វ័យ-ភាព ក្នុងគោលដៅបំពេញផលប្រយោជន៍ទូទៅ ឱ្យមានប្រសិទ្ធភាព ។ នីតិបុគ្គលសាធារណៈប្រភេទថ្មីនេះ គេឱ្យឈ្មោះថា "គ្រឹះស្ថានសាធារណៈ" (Etablissement public) ។

ដូច្នេះ យើងនឹងសិក្សាដោយសង្ខេប ជាបន្តបន្ទាប់ អំពីសេវាកម្មសាធារណៈ និងគ្រឹះ-ស្ថានសាធារណៈ ។

### ក.សេវាកម្មសាធារណៈ

**<u>អត្ថបទទី ៣៥៥</u>**

សេវាកម្មសាធារណៈ ( service public) មានន័យ ៣ យ៉ាង :

- ជា *អង្គការ* ដែលមាន បុគ្គលិក ភ្នាក់ងារធ្វើការ និងមធ្យោបាយ សំរាប់បំពេញ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

យោងស្មារតីអង្គប្រជុំលើកទី១២ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី១៣ ១៤ ខែមីនា ឆ្នាំ២០០២

- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សាំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ស្របតាមមាត្រា៧៣ មាត្រា៧៩ មាត្រា៨១ មាត្រា៨២ និង មាត្រា៨៣នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ២.-**

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវបានបង្កើតឡើងដែលរួមមានបទប្បញ្ញត្តិ និងនីតិវិធីទាក់ទងទៅនឹងការងារដូចខាងក្រោម:

១/ ថវិកាឃុំ សង្កាត់

២/ ប្រពន្ធ័គណនេយ្យនិងប្រព័ន្ធទូទាត់សំរាប់ឃុំ សង្កាត់

៣/ ការគ្រប់គ្រងចំណាយរបស់ឃុំ សង្កាត់

៤/ ទ្រព្យសម្បត្តិឃុំ សង្កាត់

៥/ សវនកម្ម និង របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់ ។

## ជំពូកទី ២

## ថវិកាឃុំ សង្កាត់

### ផ្នែកទី ១

### ចំណូល ចំណាយរបស់ឃុំ សង្កាត់

**មាត្រា ៣.-**

ថវិកាឃុំ សង្កាត់ ជាលិខិតគតិយុត្តិដែលគ្រោង និង អនុញ្ញាតចំណូល និង ចំណាយដោយផ្អែកលើមូលដ្ឋានឆ្នាំ ។

ឆ្នាំថវិការបស់ឃុំ សង្កាត់ ចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា និង បញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ។

ថវិកាឃុំ សង្កាត់ត្រូវរួមបញ្ចូលរាល់ចំណូល ចំណាយរបស់ឃុំ សង្កាត់ដោយមិនគិតដល់ប្រភពដើម ឬ ចរិតលក្ខណៈឡើយ ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងរាល់ការចំណាយជាអាទិភាពនៃផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

ថវិកាឃុំ សង្កាត់ត្រូវបានរៀបចំឡើងជាពីរផ្នែក:

- ផ្នែកទី១: ចំណូល និង ចំណាយចរន្ត

– ផ្នែកទី២: ចំណូល និង ចំណាយមូលធន។

ចំណូលសរុបត្រូវតុល្យភាពនឹងចំណាយសរុប។ អតិរេកក្នុងផ្នែកទី១ ត្រូវបានប្រើប្រាស់ជាគុណប្រយោជន៍ក្នុងផ្នែកទី២។

ចំណូលមូលធនមិនត្រូវបានប្រើប្រាស់សំរាប់ធ្វើហិរញ្ញប្បទានដល់ចំណាយចរន្ត លើកលែងតែមានការអនុញ្ញាតដោយបទប្បញ្ញត្តិដោយឡែក។

**មាត្រា ៥.–**

ចំណាយចរន្តចែកចេញជា ៧ប្រភេទ :

ប្រភេទ១- ចំណាយបៀវត្ស និង ប្រាក់បំណាច់

ប្រភេទ២- ចំណាយរដ្ឋបាលទូទៅ

ប្រភេទ៣- ចំណាយសេវាសាធារណៈ

ប្រភេទ៤- ចំណាយសំរាប់មុខងារជាភ្នាក់ងារ

ប្រភេទ៥- ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច

ប្រភេទ៦- ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច

ប្រភេទ៧- ចំណាយមិនបានគ្រោងទុក

**មាត្រា ៦.–**

ចំណូលចរន្តចែកចេញជា ៥ប្រភេទ :

ប្រភេទ១- ចំណូលពន្ធមូលដ្ឋាន

ប្រភេទ២- ចំណូលមិនមែនសារពើពន្ធ

ប្រភេទ៣- ចំណូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់សំរាប់រដ្ឋបាលទូទៅ

ប្រភេទ៤- ចំណូលពីការអនុវត្តន៍មុខងារជាភ្នាក់ងារ

ប្រភេទ៥- ចំណូលចរន្តផ្សេងៗ ។

**មាត្រា ៧.–**

ចំណាយមូលធនចែកចេញជា ២ប្រភេទ :

ប្រភេទ១- ចំណាយវិនិយោគផ្នែករដ្ឋបាល

ប្រភេទ២- ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន។

**មាត្រា ៨.–**

ចំណូលមូលធនចែកចេញជា ៤ប្រភេទ :

ប្រភេទ១- ចំណូលមូលនិធិបំរុងដូចមានចែងក្នុងមាត្រា ២២នៃអនុក្រឹត្យនេះ

ប្រភេទ២- ចំណូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់សំរាប់អភិវឌ្ឍន៍មូលដ្ឋាន

ប្រភេទ៣- ចំណូលពីការរួមចំណែករបស់ប្រជាជនមូលដ្ឋានទៅក្នុងតំលៃគំរោង

ប្រភេទ៤- ចំណូលមូលធនផ្សេងៗ ។

មាត្រា ៩.-

ចំណាយទាំងឡាយខាងក្រោមនេះ ត្រូវបានចាត់ទុកជាចំណាយចាំបាច់ របស់ឃុំ សង្កាត់ ដែលត្រូវឆ្លុះបញ្ចាំងជាអាទិភាពក្នុងថវិកា :

១- ចំណាយបៀវត្ស និង ប្រាក់បំណាច់

២- ចំណាយទុកដាក់ថែរក្សាឯកសារ

៣- ចំណាយលើថ្លៃឈ្នួលថែទាំទីស្នាក់ការឃុំ សង្កាត់

៤- ចំណាយថែទាំ និង ប្រតិបត្តិការនៃហេដ្ឋារចនាសម្ព័ន្ធ ដែលឃុំ សង្កាត់ទទួលខុសត្រូវ

៥- ចំណាយរៀបចំផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់

៦- ចំណាយបន្តគំរោងការវិនិយោគកំពុងដំណើរការ

៧- ចំណាយចាំបាច់ដទៃទៀតដែលស្របតាមច្បាប់ ឬបទបញ្ញាដែលបានកំណត់ ។

មាត្រា ១០.-

ចំណូលរបស់ឃុំ សង្កាត់ត្រូវបានកំណត់ និងប្រមូល តាមបទប្បញ្ញត្តិដោយឡែក ។

ចំណាយរបស់ឃុំ សង្កាត់ត្រូវបានសន្យា ជំរះបញ្ជី ធ្វើអាណត្តិកិច្ច និង ទូទាត់ ដោយមានលិខិតយុត្តិការត្រឹមត្រូវច្បាស់លាស់ តាមនីតិវិធី និងបទប្បញ្ញត្តិ ដូចមានចែងក្នុង ជំពូកទី២ ជំពូកទី៣ និង ជំពូកទី៤ នៃអនុក្រឹត្យនេះ ។

ចំណាយប្រតិបត្តិការ និង ការថែទាំហេដ្ឋារចនាសម្ព័ន្ធ ត្រូវរ៉ាប់រងដោយខ្ទង់ចំណូលដែលបានមកពីបន្ទុកអ្នកប្រើប្រាស់ និង ចំណូលដែលទទួលបានពីមុខងារជាភ្នាក់ងារ ។

## ផ្នែកទី ២

## ការរៀបចំ និង ការអនុម័តថវិកា

មាត្រា ១១.-

គំរោងថវិកាត្រូវរៀបចំឡើង ក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងដោយមានជំនួយការពីគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យនិង អនុម័ត ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តគំរោងថវិកានាកិច្ចប្រជុំសាធារណៈអោយបានមុន ថ្ងៃទី៣១ ខែតុលា ។ ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវអនុម័តគំរោងថវិកាតាមជំពូកនិងតាមប្រភេទនីមួយៗ ។

**មាត្រា ១២.-**

មេឃុំ ចៅសង្កាត់ត្រូវធានាអោយមានការចូលរួមពីសាធារណជនមូលដ្ឋានក្នុងដំណើរការរៀបចំថវិកា តាមរយៈវិធានការទាំងឡាយដូចខាងក្រោមៈ

- គំរោងថវិកាត្រូវតែប្រកាសផ្សាយជាសាធារណៈ យ៉ាងតិច២សប្តាហ៍ មុនពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អង្គប្រជុំរបស់គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវបើកចំហដល់ សាធារណជនដែលចាប់អារម្មណ៍លើការពិនិត្យគំរោងថវិកានេះ
- ប្រជាពលរដ្ឋត្រូវតែបានផ្តល់កាលានុវត្តភាពក្នុងការចូលរួមសម័យប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលសំរេចលើគំរោងថវិកា ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើតនូវយន្តការផ្សេង១ ដើម្បីជំរុញអោយមានការចូលរួមពីសាធារណជន លើកិច្ចការមូលដ្ឋាន។

**មាត្រា ១៣.-**

មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនគំរោងថវិកាដែលបានអនុម័តរួចទៅអភិបាលខេត្ត ក្រុងអោយបានមុនថ្ងៃ ទី៥ ខែវិច្ឆិកា ដើម្បីបញ្ជាក់ទទួលស្គាល់ ។

គំរោងថវិកាត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោមៈ

- របាយការណ៍សង្ខេបស្តីពីមូលដ្ឋានក្នុងការរៀបចំចំណូល និង ចំណាយ ព្រមទាំងកិរិតចូលរួម របស់ ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកា
- របាយការណ៍ស្តីពីការអនុវត្តន៍ថវិកានៃឆ្នាំដំណើរការ
- តារាងសង្ខេប នៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ជាក់ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ប្រសិនបើមាន
- កំណត់ហេតុ ស្តីពី កិច្ចប្រជុំ អនុម័តលើគំរោងថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ១៤.-**

អភិបាលខេត្ត ក្រុង ត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគំរោងថវិកាអោយបានមុនថ្ងៃទី៣០ ខែវិច្ឆិកា ។

ការត្រួតពិនិត្យអនុលោមភាពត្រូវឆ្លើយតបទៅនឹងចំណុចដូចខាងក្រោមៈ

១-ទំរង់ថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការរៀបចំថវិកា

២-តុល្យភាពថវិកា និង ការប្រើប្រាស់ចំណូលមូលធនដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ

៣-ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់ដែលទទួលបាន

៤-ការគ្រោងឥណទានថវិកាទៅតាមគោលការណ៍ចំណាយចាំបាច់

៥-តំរូវការថវិកាវិនិយោគ សំរាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ជាក់ច្បាស់លាស់ក្នុងផែនការ របស់ឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុងមិនមានសិទ្ធិកែប្រែ ឬជំទាស់ទៅនឹងជំរើសនៃការចំណាយដែលបានសំរេចដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្រៅពីពិនិត្យលើល័ក្ខខ័ណ្ឌទាំងឡាយដែលឆ្លើយតបទៅនឹងការត្រួតពិនិត្យអនុលោមភាព ។

## មាត្រា ១៥.-

ប្រសិនបើ គំរោងថវិកាត្រូវបានបំពេញតាមល័ក្ខខ័ណ្ឌនៃការត្រួតពិនិត្យអនុលោមភាព ដូចមានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ អភិបាលខេត្ត ក្រុង ត្រូវបញ្ជាក់ទទួលស្គាល់លើគំរោងថវិកា និងចេញសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរ ជូនមេឃុំ ចៅសង្កាត់ ។ សេចក្តីជូនដំណឹងត្រូវភ្ជាប់ជាមួយឯកសារថវិកា ដែលមានហត្ថលេខាសង្ខេបរបស់ អភិបាលខេត្ត ក្រុង និងបោះត្រាលើទំព័រនីមួយៗ ។

អភិបាលខេត្ត ក្រុងត្រូវចំលងជូនសេចក្តីជូនដំណឹង ព្រមទាំងថវិកាដែលបានបញ្ជាក់ទទួលស្គាល់ទៅមន្ទីរ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង ។

## មាត្រា ១៦.-

ក្នុងករណីដែលអភិបាលខេត្ត ក្រុងមិនបញ្ជាក់ទទួលស្គាល់លើគំរោងថវិកា អភិបាលខេត្ត ក្រុងត្រូវជូនដំណឹងបន្ទាន់ ជាលាយល័ក្ខអក្សរដល់មេឃុំ ចៅសង្កាត់ដោយបញ្ជាក់ពីមូលហេតុហើយណែនាំដល់មេឃុំ ចៅសង្កាត់អោយអនុវត្តវិធានការ កែតម្រូវ ។

មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យកែសំរួលគំរោងថវិកាឡើងវិញតាមការណែនាំរបស់អភិបាលខេត្ត ក្រុង ហើយដាក់ជូន ក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តក្នុងរង្វង់១៥ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងរបស់អភិបាល ខេត្ត ក្រុង ។

បន្ទាប់ពីការពិភាក្សា មេឃុំ ចៅសង្កាត់ ផ្ញើគំរោងថវិកាកែតម្រូវជូនអភិបាលខេត្ត ក្រុង បញ្ជាក់ទទួលស្គាល់ ។

ប្រសិនបើ មេឃុំ ចៅសង្កាត់ ខកខានមិនបានបញ្ជូនគំរោងថវិកាដែលបានពិនិត្យឡើងវិញដល់អភិបាល ខេត្ត ក្រុង ក្នុងរង្វង់មួយខែបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងខាងលើ ឬ គំរោងថវិកាដែលបានពិនិត្យឡើងវិញនៅតែមិនទាន់ឆ្លើយតប បានទៅនឹងការត្រួតពិនិត្យអនុលោមភាព ពេលនោះអភិបាលខេត្ត ក្រុង មានសិទ្ធិចាត់វិធានការកែសំរួលចាំបាច់ មុនពេល បញ្ជាក់ទទួលស្គាល់លើគំរោងថវិកា ។អភិបាលខេត្ត ក្រុង ត្រូវជូនដំណឹងអំពីសេចក្តីសំរេចរបស់ខ្លួនដល់មេឃុំ ចៅសង្កាត់ មន្ទីរ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង តាមនីតិវិធីដូចមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ ។

ក្នុងករណីមានការមិនចុះសំរុងគ្នារវាងមេឃុំ ចៅសង្កាត់ ជាមួយអភិបាលខេត្ត ក្រុង មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូន ករណីនេះ ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យសំរេច ។ សេចក្តីសំរេច របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចាត់ទុកជាការសំរេច ចុងក្រោយ ។

**មាត្រា ១៧.-**

ក្នុងករណី អភិបាលខេត្ត ក្រុង មិនបានបញ្ជាក់ទទួលស្គាល់លើគំរោងថវិកា មុនថ្ងៃទី០១ ខែមករានៃឆ្នាំ មេឃុំ ចៅសង្កាត់ត្រូវបានអនុញ្ញាតអោយអនុវត្តជាបណ្តោះអាសន្នលើចំណាយប្រចាំខែក្នុងកំរិត ១/១២ នៃថវិកាដែលបានអនុម័ត ឆ្នាំមុន និងលើការប្រមូលចំណូលរបស់ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដែលបានអនុម័ត ដូចឆ្នាំមុនដែរ ។

## ផ្នែកទី ៣
## ការអនុវត្តន៍ថវិកា

**មាត្រា ១៨.-**

ថវិកាឃុំ សង្កាត់ អាចនឹងត្រូវបានកែតំរូវក្នុងអំឡុងឆ្នាំថវិកា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃ ល័ក្ខខ័ណ្ឌសេដ្ឋកិច្ច ឬ ហិរញ្ញវត្ថុ ដែលជះឥទ្ធិពលទៅលើការព្យាករណ៍ដំបូងនៃចំណូល និងចំណាយ ។

**មាត្រា ១៩.-**

ការកែតំរូវថវិកាត្រូវរៀបចំ ពិនិត្យ អនុម័ត និងបញ្ជាក់ទទួលស្គាល់ តាមនីតិវិធីដូចមានចែងក្នុងមាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៤ និងមាត្រា១៥នៃអនុក្រឹត្យនេះ ។

ប្រសិនបើ គោលបំណងនៃការកែតំរូវថវិកា គ្រាន់តែជាការវិភាជន៍ធនធានឡើងវិញ ក្នុងប្រភេទចំណាយតែមួយ ដោយមិនធ្វើអោយប្រែប្រួលចំនួនទឹកប្រាក់នៃប្រភេទចំណាយ ឬមិនធ្វើអោយប្រែប្រួលប្រភេទគំរោងវិនិយោគនៅក្នុងថវិកា ដំបូងនោះ ពុំចាំបាច់សុំការបញ្ជាក់ទទួលស្គាល់ឡើងវិញពីអភិបាលខេត្ត ក្រុងទេ ។ ក្នុងករណីនេះ មេឃុំ ចៅសង្កាត់ត្រូវជូន ដំណឹងដល់អភិបាល ខេត្ត ក្រុង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារខេត្ត ក្រុង អំពីការប្រែប្រួលធនធានវិភាជន៍ ឡើងវិញមិនអោយយឺតជាង៥ថ្ងៃ បន្ទាប់ពីការពិភាក្សាសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២០.-**

ឥណទានថវិកានៃប្រភេទចំណាយមិនបានគ្រោងទុក មិនត្រូវលើស ៣% នៃថវិកាសរុប ។ ខ្ទង់ថវិកានៃចំណាយមិន បានគ្រោងទុកអាចត្រូវបានប្រើប្រាស់ សំរាប់ធានាចំពោះចំណាយទាំងឡាយណាដែលការវិភាជន៍មិនត្រូវបានកំណត់ជាក់លាក់ នៅពេលឥណទានត្រូវបានអនុម័ត ឬសំរាប់ឥណទានបំពេញបន្ថែមជាគុណប្រយោជន៍ ដល់ប្រភេទចំណាយផ្សេងៗទៀតរបស់ ឃុំ សង្កាត់ ។

មេឃុំ ចៅសង្កាត់ត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សាឃុំ សង្កាត់មុនពេលសំរេចចិត្តលើការប្រើប្រាស់ឥណទានថវិកា ចំណាយមិនបានគ្រោងទុក ។

**មាត្រា ២១.-**

នៅដំណាច់ឆ្នាំថវិកា គណនេយ្យករឃុំ សង្កាត់នៅរតនាគារខេត្ត ក្រុងត្រូវរៀបចំបិទបញ្ជី និងធ្វើ...

គណនេយ្យករត្រូវធ្វើរបាយការណ៍បិទបញ្ជីជូនមេឃុំ ចៅសង្កាត់ដើម្បីផ្ទៀងផ្ទាត់គណនីថវិកា ជាមួយឃុំ សង្កាត់ ។ គណនេយ្យករ និងមេឃុំ ចៅសង្កាត់ ត្រូវពិនិត្យ កែតម្រូវលេខនា និង ឯកភាពលើរបាយការណ៍បិទបញ្ជីនោះ ។

របាយការណ៍បិទបញ្ជីបង្ហាញនូវតួលេខអនុវត្តជាក់ស្តែង របស់ថវិកាព្រមទាំងទ្រព្យសម្បត្តិ និង ស្ថានភាពគនះវត្ថុ ដំណាច់ឆ្នាំរបស់ឃុំ សង្កាត់ ។

## មាត្រា ២២.-

មេឃុំ ចៅសង្កាត់ត្រូវដាក់របាយការណ៍បិទបញ្ជីជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ អនុម័ត ក្នុងខែមីនានៃឆ្នាំបន្ទាប់។ បន្ទាប់ពីការពិភាក្សា ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តដោយបោះឆ្នោត លើសេចក្តីសំរេច ស្តីពីការបិទបញ្ជីថវិកា ។

សេចក្តីសំរេចស្តីពីការបិទបញ្ជីថវិកាត្រូវ:

១- បញ្ជាក់នូវចំណូល ចំណាយជាក់ស្តែងដែលសំរេចបានក្នុងឆ្នាំថវិកា

២- លុបចោលឥណទានថវិកាដែលមិនបានប្រើប្រាស់

៣- អនុញ្ញាតអោយផ្ទេរលទ្ធផលនៃឆ្នាំថវិកាទៅគណនី មូលនិធិបំរុង ។

បន្ទាប់ពីបានអនុម័តរយៈយ៉ាងយូរ៧ថ្ងៃ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូន "សេចក្តីសំរេចស្តីពីការបិទបញ្ជីថវិកា" ទៅអភិបាលខេត្ត ក្រុង ដើម្បីពិនិត្យបញ្ជាក់ទទួលស្គាល់ដោយភ្ជាប់ជាមួយនូវ:

- របាយការណ៍បិទបញ្ជីគណនេយ្យ
- របាយការណ៍ ស្តីពី សកម្មភាពទូទៅនៃឃុំ សង្កាត់
- កំណត់ហេតុនៃការពិភាក្សាអនុម័តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

## មាត្រា ២៣.-

មូលនិធិបំរុងត្រូវប្រើប្រាស់សំរាប់ហិរញ្ញប្បទានដល់ចំណាយមូលធននៃថវិកាឆ្នាំក្រោយ។

## ជំពូកទី ៣
## ប្រព័ន្ធគណនេយ្យនិងប្រព័ន្ធទូទាត់សំរាប់ឃុំ សង្កាត់

## មាត្រា ២៤.-

ប្រព័ន្ធគណនេយ្យឃុំ សង្កាត់ត្រូវបំរើដល់គោលបំណងទាំងឡាយដូចខាងក្រោម:

១- បញ្ជីការរាល់ប្រតិបត្តិការហិរញ្ញវត្ថុរបស់ឃុំ សង្កាត់

២- ធ្វើរបាយការណ៍ហិរញ្ញវត្ថុជាក់ស្តែងអោយទាន់ពេលវេលា ដែលអាចជាកម្មវត្ថុសំរាប់ ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់

៣- ផ្តល់មូលដ្ឋានសំរាប់តាមដានការអនុវត្តន៍ថវិការបស់ឃុំ សង្កាត់ ។

គណនេយ្យឃុំ សង្កាត់ រួមមាន:

ក) គណនេយ្យហិរញ្ញវត្ថុ : គណនា ចុះបញ្ជី និងធ្វើរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុ របស់ឃុំ សង្កាត់ ។

ខ) គណនេយ្យថវិកា : តាមដាន និងធ្វើរបាយការណ៍ស្ដីពីការអនុវត្តន៍ថវិកាដែលបានអនុម័ត ។

**មាត្រា ២៥.-**

គណនេយ្យហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ គឺផ្អែកលើមូលដ្ឋានសាច់ប្រាក់ និងតាមវិធីបញ្ជីកាទ្វេភាគ ។ មាតិកាគណនី ត្រូវស្របគ្នាជាមួយមាតិកាថវិការបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ណាដែលមានធនធានហិរញ្ញវត្ថុ ឬ សមត្ថភាពគ្រប់គ្រងមានកំរិតខ្សោយអាចប្រើប្រាស់មាតិកាគណនី និងមាតិកាថវិកាដែលមានលក្ខណៈសាមញ្ញ ។

**មាត្រា ២៦.-**

រតនាគារខេត្ត ក្រុងត្រូវបំពេញមុខងារជាគណនេយ្យករឃុំ សង្កាត់និងត្រូវអនុវត្តភារកិច្ចទាំងឡាយដូចខាងក្រោម :

១- ប្រមូល ឬ ទទួលចំណូលរបស់ឃុំ សង្កាត់

២- ទូទាត់ចំណាយដែលបានចេញអាណត្តិដោយមេឃុំ ចៅសង្កាត់

៣- គ្រប់គ្រង និង បើកផ្ដល់ថវិកាឃុំ សង្កាត់

៤- បញ្ជីកាប្រតិបត្តិការហិរញ្ញវត្ថុឃុំ សង្កាត់ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា២៥ នៃអនុក្រឹត្យនេះ

៥- រៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុតាមកាលកំណត់

៦- ថែរក្សាទុកដាក់រាល់ឯកសារសក្ខីប័ត្រ និង បញ្ជីគណនេយ្យរបស់ឃុំ សង្កាត់ ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់ជាអាណាប័ក មានសិទ្ធិសំរេចអោយប្រមូលចំណូល សន្យាចំណាយ និង បញ្ជាចំណាយ ដោយផ្អែកលើថវិកាឃុំ សង្កាត់ដែលបានអនុម័ត ។

មេឃុំ ចៅសង្កាត់អាចផ្ទេរសិទ្ធិជាលាយល័ក្ខអក្សរ ក្នុងការសំរេចលើថវិកាទៅអោយ ជំទប់ ចៅសង្កាត់រង ណាមួយរបស់រដ្ឋបាលឃុំ សង្កាត់ ។ ការផ្ទេរសិទ្ធិជាអាណាប័កនេះ ត្រូវធ្វើសកម្មភាពដោយស្ថិតនៅក្នុងការទទួលខុសត្រូវ និងត្រួតពិនិត្យរបស់មេឃុំ ចៅសង្កាត់ ។

អាណាប័ក និងអ្នកទទួលសិទ្ធិត្រូវតែតម្កល់គំរូហត្ថលេខាជាផ្លូវការដល់គណនេយ្យករមុខការ ។

**មាត្រា ២៨.-**

សិទ្ធិបញ្ជាចំណាយ និង ការទូទាត់មិនត្រូវប្រគល់អោយមនុស្សតែម្នាក់ លើកលែងតែករណីទាំងឡាយដូចមានចែងក្នុងមាត្រា ៣១នៃអនុក្រឹត្យនេះ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់នីមួយៗត្រូវបើកគណនីប្រាក់បញ្ញើមួយនៅរតនាគារខេត្ត ក្រុង ។ គណនីនេះត្រូវបានប្រើប្រាស់សំរាប់ទទួលចំណូល និងទូទាត់ចំណាយ ។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចអនុញ្ញាតដល់ឃុំ សង្កាត់ក្នុងការគ្រប់គ្រងទាំងស្រុង ឬមួយចំណែកនៃប្រតិបត្តិការសាច់ប្រាក់តាមរយៈគណនីបើកនៅធនាគារពាណិជ្ជប្រតិស្រុតណាមួយ ។

**មាត្រា ៣១.-**

ឃុំ សង្កាត់ត្រូវធ្វើការទូទាត់ដល់ចំណាយទាំងឡាយដែលមានចំនួនទឹកប្រាក់នៅក្រោមកំរិតមួយជាកំណត់ តាមនីតិវិធីបេឡាបុរេប្រទាន ។

មេឃុំ ចៅសង្កាត់ត្រូវតែងតាំងមន្ត្រីមួយរូបរបស់រដ្ឋបាលឃុំ សង្កាត់អោយទទួលខុសត្រូវក្នុងការគ្រប់គ្រងបេឡាបុរេប្រទាននេះ ។

បេឡាករបុរេប្រទានត្រូវទទួលខុសត្រូវលើសុវត្ថិភាពរបស់មូលនិធិ ព្រមទាំងឯកសារ សក្ខីប័ត្រពាក់ព័ន្ធ និង កត់ត្រារាល់ប្រតិបត្តិការ ។ បេឡាករបុរេប្រទានបំពេញភារកិច្ច ក្រោមការត្រួតពិនិត្យរួមគ្នា របស់មេឃុំ ចៅសង្កាត់ និងគណនេយ្យករឃុំ សង្កាត់ ។

**មាត្រា ៣២.-**

ការទទួលខុសត្រូវក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធអាចនឹងប្រគល់អោយមន្ត្រីម្នាក់ របស់រដ្ឋបាល ឃុំ សង្កាត់ ធ្វើជាភ្នាក់ងារប្រមូលចំណូល ។

ភ្នាក់ងារប្រមូលចំណូលត្រូវបានតែងតាំងឡើង និង បំពេញភារៈកិច្ចមានលក្ខណៈដូចគ្នា នឹងបេឡាករបុរេប្រទានដែរ ។

**មាត្រា ៣៣.-**

មេឃុំ ចៅសង្កាត់ត្រូវធានាថាប្រព័ន្ធគណនេយ្យថវិកាត្រូវបានអនុវត្ត ។

ប្រព័ន្ធគណនេយ្យថវិកាត្រូវបញ្ជីកា ការសន្យាចំណាយ និង ការអនុញ្ញាតអោយចំណាយដោយមេឃុំ ចៅសង្កាត់សំរាប់គោលបំណងនៃការតាមដានកិច្ចប្រតិបត្តិការថវិកា ។

## ជំពូកទី ៤

## ឆាយការណ៍ហិរញ្ញវត្ថុ

**មាត្រា ៣៤.-**

របាយការណ៍ហិរញ្ញវត្ថុត្រូវបំពេញនូវគោលបំណងដូចខាងក្រោម:

១- តាមដានកិច្ចប្រតិបត្តិការចំណូលនិងចំណាយរបស់ឃុំ សង្កាត់ ដោយប្រៀបធៀបជាមួយនឹងការព្យាករណ៍ថវិកា

២- វាយតំលៃស្ថានភាពហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ ដោយផ្តល់នូវពត៌មានអំពីប្រភព និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ

៣- បង្កលក្ខណៈដល់មេឃុំ ចៅសង្កាត់ក្នុងការទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងអាជ្ញាធរថ្នាក់លើ

៤- ឆ្លុះបញ្ចាំងអោយឃើញថាកិច្ចប្រតិបត្តិការឆ្លើយតបបានទៅនឹងថវិកាដែលបានអនុម័តនិងបទប្បញ្ញត្តិ គតិយុត្តិផ្សេងទៀត។

**មាត្រា ៣៥.-**

ឃុំ សង្កាត់ត្រូវរៀបចំរបាយការណ៍ដូចខាងក្រោម:

១- របាយការណ៍ស្តីពីការអនុវត្តន៍ថវិកាប្រចាំខែ : របាយការណ៍នេះត្រូវមានទំរង់ជារបាយការណ៍ចំណូល ចំណាយផ្អែកតាមមាតិកាថវិកា។ ត្រូវប្រៀបធៀបការអនុវត្តន៍ជាក់ស្តែងទៅនឹងការព្យាករណ៍ថវិកា និងបង្ហាញអំពីស្ថានភាពរតនៈវត្ថុរបស់ឃុំ សង្កាត់

២- របាយការណ៍ស្តីពីការអនុវត្តន៍ថវិកាប្រចាំឆមាស ដែលមានទំរង់ដូចគ្នាទៅនឹងរបាយការណ៍ប្រចាំខែ ដែរ

៣- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរួមមាន:

- របាយការណ៍ស្តីពីចំណូល ចំណាយប្រចាំឆ្នាំ
- ការផ្ទៀងផ្ទាត់គណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់នៅរតនាគារ
- របាយការណ៍ស្តីពីអចលនវត្ថុ។

របាយការណ៍ហិរញ្ញវត្ថុត្រូវមានភាពជាក់ស្តែងនិងប្រាកដប្រជា ទាក់ទងទៅ នឹងល័ក្ខខ័ណ្ឌទាំងឡាយ នៃការអនុវត្តន៍ថវិកាព្រមទាំងស្ថានភាពហិរញ្ញវត្ថុដំណាច់ឆ្នាំរបស់ឃុំ សង្កាត់ ។

**មាត្រា ៣៦.-**

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវភ្ជាប់ជាមួយនូវរបាយការណ៍លំអិត ស្តីពីសកម្មភាពរបស់ឃុំ សង្កាត់។ របាយការណ៍សកម្មភាពប្រចាំឆ្នាំត្រូវពិពណ៌នា និងវាយតំលៃ:

- ការអនុវត្តន៍ការងាររបស់ឃុំ សង្កាត់ ក្នុងការប្រមូលចំណូល និងចំណាយ
- សមិទ្ធិផលរបស់ឃុំ សង្កាត់ក្នុងការផ្តល់សេវាសាធារណៈ ប្រៀបធៀបជាមួយនឹងទិសដៅ ផែនការ
- ស្ថានភាពសេដ្ឋកិច្ចរបស់ឃុំ សង្កាត់ និងផលប៉ះពាល់ពីប្រតិបត្តិការរបស់ឃុំ សង្កាត់ លើសុខុមាលភាពរបស់ប្រជាជន ។

របាយការណ៍សកម្មភាព ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់។

របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាព ជាឯកសារជំនួយក្នុងការបិទបញ្ជីគណនីឃុំ សង្កាត់ តាមការកំណត់ ។

មាត្រា ៣៧.-

របាយការណ៍ហិរញ្ញវត្ថុត្រូវរៀបចំឡើងដោយគណនេយ្យកររបស់ឃុំ សង្កាត់ និងត្រូវផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍គណនេយ្យថវិកា ដែលគ្រប់គ្រងដោយរដ្ឋបាលឃុំ សង្កាត់ ស្របទៅតាមប្រតិទិន ដូចខាងក្រោម:

- អោយបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់សំរាប់របាយការណ៍ប្រចាំខែ
- អោយបានមុនថ្ងៃទី ២១ ខែកក្កដា សំរាប់របាយការណ៍ឆមាស
- អោយបានមុនថ្ងៃទី ៣១ ខែមករា នៃឆ្នាំបន្ទាប់សំរាប់របាយការណ៍ប្រចាំឆ្នាំ។

មាត្រា ៣៨.-

មេឃុំ ចៅសង្កាត់ត្រូវពិនិត្យនិងឯកភាពទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំដោយគណនេយ្យករ និងត្រូវផ្ញើជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិភាក្សា និងអនុម័តទាន់ពេលវេលា ដោយភ្ជាប់នូវរបាយការណ៍លំអិតអំពីសកម្មភាព ។

ក្រោយពីក្រុមប្រឹក្សាឃុំ សង្កាត់បានពិភាក្សា អនុម័តរួចមេឃុំ ចៅសង្កាត់ត្រូវ:

១- ផ្ញើរបាយការណ៍ជូនអភិបាលខេត្ត ក្រុង និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២- ផ្សព្វផ្សាយជាសាធារណៈ ។

## ជំពូកទី ៥
## ការគ្រប់គ្រងចំណាយ
### ផ្នែកទី ១
### ខួបនៃការចំណាយ

មាត្រា ៣៩.-

ចំណាយត្រូវសមស្របទៅនឹងថវិការបស់ឃុំ សង្កាត់និងសមស្របតាមច្បាប់ និង បទបញ្ជាទាំងឡាយ នៃ ព្រះរាជាណាចក្រកម្ពុជា ។

ដំណើរការនៃចំណាយរបស់ឃុំ សង្កាត់ រួមមានដំណាក់កាលទាំងឡាយដូចខាងក្រោម:

១- ការសន្យា

២- កិច្ចជំរះបញ្ជី

៣- អាណត្តិកិច្ច

៤- ការទូទាត់។

**មាត្រា ៤០.-**

ការសន្យាត្រូវមានកិច្ចសន្យាឬការព្រមព្រៀងក្នុងការទិញមានលក្ខណៈបន្ទាន់ ឬ ការផ្គត់ផ្គង់សំភារៈ និងសេវាកម្មនៅពេលខាងមុខ ។ ការសន្យាគឺជាការបញ្ជាក់នូវកាតព្វកិច្ចរបស់ឃុំ សង្កាត់ដែលត្រូវទូទាត់ ប្រសិនបើ អ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការបានបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យា ។

មុនពេលសន្យាលើចំណាយណាមួយ មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិត្រូវធានាថា:

១- ចំណាយដែលបានស្នើពិតជាត្រឹមត្រូវទៅតាមប្រភេទថវិកា

២- មាននៅក្នុងឥណទានថវិកាព្រមទាំងមានមូលនិធិទំនេរគ្រប់គ្រាន់ និង ត្រឹមត្រូវតាមមាតិកាថវិកា

៣- នីតិវិធីលទ្ធកម្មនឹងអនុវត្តបានត្រឹមត្រូវ

៤- ការសន្យាចំណាយត្រូវបានកត់ត្រាដូចដែលបានបញ្ជាក់ក្នុងមាត្រា ៣៣នៃអនុក្រឹត្យនេះ

ការសន្យាចំណាយមិនត្រូវស្ថិតជាកម្មវត្ថុនៃការត្រួតពិនិត្យជាមុនរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង អាជ្ញាធរខេត្ត ក្រុងទេ ។

**មាត្រា ៤១.-**

ក្នុងកិច្ចជំរះបញ្ជី មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិត្រូវធានាថា:

១- សំភារៈទាំងឡាយត្រូវបានប្រគល់ ឬសេវាត្រូវបានផ្តល់ដូចដែលបានបញ្ជាក់ត្រឹមត្រូវតាមកិច្ចសន្យា ឬការបញ្ជាទិញដែលបានព្រមព្រៀង

២- វិក័យប័ត្រដែលដាក់ជូនដោយអ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ត្រូវតែត្រឹមត្រូវទៅនឹងចំនួន និង ការងារអនុវត្តបាន ។

**មាត្រា ៤២.-**

បន្ទាប់ពីបញ្ចប់កិច្ចជំរះបញ្ជី មេឃុំ ចៅសង្កាត់ត្រូវចេញអាណត្តិបើកប្រាក់ ។

មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនអាណត្តិបើកប្រាក់រួមជាមួយឯកសារពាក់ព័ន្ធអោយគណនេយ្យករឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុង ហើយទន្ទឹមនឹងនេះ ជូនដំណឹងដល់អ្នកត្រូវទទួលប្រាក់ ។

ក្នុងករណី ចំនួនទឹកប្រាក់ចំណាយស្ថិតនៅក្នុងកំរិតកំណត់ ដែលបានអនុញ្ញាតអោយប្រើប្រាស់បេឡាបុរេប្រទាន ការទូទាត់ត្រូវអនុវត្តតាមនីតិវិធីចំណាយនៃបេឡាបុរេប្រទានរបស់ឃុំ សង្កាត់ ។

**មាត្រា ៤៣.-**

គណនេយ្យករត្រូវធ្វើការទូទាត់ដល់អ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ ឬក៏អ្នកទទួលសិទ្ធិដែលបានបញ្ជាក់ក្នុងអាណត្តិបើកប្រាក់ ។

មុនពេលទូទាត់ គណនេយ្យករត្រូវធ្វើការត្រួតពិនិត្យ និងបញ្ជាក់លើចំណុចដូចខាងក្រោម:

១- អាណត្តិបើកប្រាក់ត្រូវបានចុះហត្ថលេខាដោយអាណាប័កដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវ

២- មន្ត្រីមុខការបានបញ្ជាក់ថា សំភារៈត្រូវបានទទួល ឬសេវាត្រូវបានផ្តល់ត្រឹមត្រូវតាមការព្រមព្រៀង

៣- វិក័យប័ត្រ និងឯកសារទាំងឡាយដែលជាសំណូមពរនៃការទូទាត់ពិតជាត្រឹមត្រូវ

៤- ឥណទាយកពិតជាត្រឹមត្រូវតាមកិច្ចសន្យា

៥- សំណើទូទាត់ពិតជាត្រឹមត្រូវតាមប្រភេទចំណាយ ព្រមទាំងមានថវិកាទំនេរគ្រប់គ្រាន់ក្នុងប្រភេទ ចំណាយនេះ

៦- ស្ថានភាពគណនីប្រាក់បញ្ញើឃុំ សង្កាត់ មានលទ្ធភាពទូទាត់បាន

៧- ការទូទាត់ត្រូវមានលក្ខណៈជាការរំដោះបំណុល ។

ក្នុងករណីមិនបានបំពេញល័ក្ខខ័ណ្ឌខាងលើគ្រប់គ្រាន់ គណនេយ្យករមានសិទ្ធិផ្អាកការទូទាត់ ហើយជូនដំណឹងជាបន្ទាន់ដល់មេឃុំ ចៅសង្កាត់ដោយបញ្ជាក់អំពីមូលហេតុ និង សំណូមពរបំពេញបន្ថែម ។

**មាត្រា ៤៤.-**

ក្នុងករណីមានបញ្ហាក្នុងការទូទាត់ មេឃុំ ចៅសង្កាត់ និង គណនេយ្យករត្រូវពិភាក្សាដើម្បីរកដំណោះស្រាយស្រប តាមនីតិវិធីនៃការទូទាត់ ។

ប្រសិនបើការពិភាក្សាមិនបានឯកភាពគ្នាទេ មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនសំណុំរឿងនេះទៅអភិបាលខេត្ត ក្រុងជួយដោះស្រាយ ។ សេចក្តីសំរេចរបស់អភិបាលខេត្ត ក្រុងចាត់ទុកជាការសំរេចចុងក្រោយចំពោះទំនាស់នេះ និងត្រូវភ្ជាប់ជាឯកសារបន្ថែមនៃការទូទាត់ ។

## ផ្នែកទី២

## ការទារលទ្ធកម្មសាធារណៈ

**មាត្រា ៤៥.-**

លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សំភារៈ និង ការផ្តល់សេវាត្រូវតែស្របទៅតាមគោលការណ៍ទូទៅដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ។

**មាត្រា ៤៦.-**

មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មការលទ្ធកម្មមួយទទួលបន្ទុកការងារទាំងឡាយរួមមានៈ

១ -ធ្វើការវាយតំលៃលើការដេញថ្លៃរបស់អ្នកម៉ៅការ និង អ្នកផ្គត់ផ្គង់

២-ផ្តល់អនុសាសន៍ លើការសំរេចចុះកិច្ចសន្យា ។

គណៈកម្មការលទ្ធកម្មត្រូវធានាថាៈ

- លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សំភារៈ និងការផ្តល់សេវា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព និង សន្សំសំចៃ

- អ្នកម៉ៅការ និង អ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱកាសស្មើៗគ្នាក្នុងការចូលរួមប្រកួតប្រជែងផ្គត់ផ្គង់សំភារៈ និងផ្តល់សេវាក្រោមល័ក្ខខ័ណ្ឌតែមួយ
- លទ្ធផលនៃការងារលទ្ធកម្មត្រូវប្រកាសជាសាធារណៈ

**មាត្រា ៤៧.-**

គណៈកម្មការលទ្ធកម្មត្រូវមានសមាសភាពដូចខាងក្រោម:

| | |
|---|---|
| - មេឃុំ ចៅសង្កាត់ ឬ អ្នកទទួលសិទ្ធិ | ប្រធាន |
| - សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ពីររូប | សមាជិក |
| - ស្មៀនឃុំ សង្កាត់ | លេខាធិការ |

ប្រធានគណៈកម្មការលទ្ធកម្មអាចអញ្ជើញបុគ្គលមួយចំនួនចូលរួមជាអ្នកជំនួយការ ឬជាអ្នកសង្កេតការណ៍។ ក្នុងការប្រជុំពិភាក្សាការងារ របស់ គណៈកម្មការលទ្ធកម្ម អ្នកជំនួយការ លេខាធិការ និងអ្នកសង្កេតការណ៍ ពុំមានសិទ្ធិសំរេចទេ។ គណៈកម្មការលទ្ធកម្ម ត្រូវធ្វើសេចក្តីសំរេចដោយសំលេងភាគច្រើន ។

ក្នុងករណីមានសំលេងស្មើគ្នានោះ សំលេងរបស់ប្រធានចាត់ទុកជាសំលេងឧត្តមភាព ។

**មាត្រា ៤៨.-**

ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំ របស់គណៈកម្មការលទ្ធកម្ម មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសំរេចចុងក្រោយស្តីពីការប្រគល់កិច្ចសន្យា។

## ជំពូកទី ៦

## ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់

**មាត្រា ៤៩.-**

ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់រួមមានបីប្រភេទ:

១-ទ្រព្យសម្បត្តិដែលរាជរដ្ឋាភិបាលផ្ទេរសិទ្ធិអោយកាន់កាប់

២-ទ្រព្យសម្បត្តិដែលឃុំ សង្កាត់ទិញដោយខ្លួនឯង

៣-ទ្រព្យសម្បត្តិដែលបានមកពីអំណោយនានា។

**មាត្រា ៥០.-**

ឃុំ សង្កាត់ត្រូវរក្សាការកត់ត្រាដោយឡែកប្រភេទទ្រព្យសម្បត្តិទាំងបីខាងលើ តាមប្រភេទនីមួយៗ នូវព័ត៌មានដូចខាងក្រោម:

១- លេខរៀង ឬលេខកូដ

២- យថាប្រភេទ

៣- កាលបរិច្ឆេទផ្ទេរសិទ្ធិអោយកាន់កាប់

៤- បរិមាណ និង តំលៃ

៥- ទីតាំងដែលទ្រព្យសម្បត្តិនោះទុកដាក់ ឬប្រើប្រាស់

មេឃុំ ចៅសង្កាត់ត្រូវធានាកត់ត្រាក្នុងបញ្ជីទ្រព្យសម្បត្តិអោយបានត្រឹមត្រូវ ។

## មាត្រា ៥១.-

ចលនៈវត្ថុនានាត្រូវមានលេខកូដសំគាល់ដើម្បីងាយស្រួលដឹងថានៅទីកន្លែងណា និង អាចជួយដល់ការ កត់ត្រាបញ្ជីចលនៈវត្ថុ ។

មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មការមួយធ្វើសារពើភណ្ឌ អោយបានយ៉ាងតិច១ដងក្នុង១ឆ្នាំ ចំពោះអចលនៈវត្ថុរបស់ខ្លួន ដើម្បីដឹងបានចំនួនបាត់បង់ ហើយធ្វើការកែតម្រូវបញ្ជី ព្រមទាំងវាយតំលៃចំពោះស្ថានភាពរបស់ទ្រព្យសម្បត្តិ ដើម្បីរៀប ចំជួសជុល ថែទាំ ឬជំនួសថ្មី ។

លទ្ធផលនៃសារពើភណ្ឌ ត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយបញ្ជីអចលនៈវត្ថុ បើឃើញមានការខុសគ្នា ត្រូវតែធ្វើការអង្កេតបញ្ជាក់មូលហេតុច្បាស់លាស់ និងកែតម្រូវបញ្ជី អចលនៈវត្ថុទៅតាមនោះ ។

តារាងសង្ខេប ព្រមទាំងរបាយការណ៍សារពើភ័ណ្ឌអចលនៈវត្ថុ ចាំបាច់ត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ។

## មាត្រា ៥២.-

អនុលោមតាមមាត្រា៨១ នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរ ឬ ផ្ទេរកម្មសិទ្ធិ ឬ ផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលរាជរដ្ឋាភិបាលប្រគល់អោយ ដោយគ្មានការយល់ព្រមជាមុនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ ឯកភាពរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឡើយ ។

## មាត្រា ៥៣.-

ឃុំ សង្កាត់មានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែល[illegible]ទិញដោយធនធានផ្ទាល់របស់ខ្លួន ។

ការលក់ដូរ ឬ ការផ្ទេរកម្មសិទ្ធិ ឬការប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធី[illegible]

១- មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មការចំពោះកិច្ចមួយ ដើម្បី[illegible]ទ្រព្យសម្បត្តិ ។ គណៈកម្មការនេះត្រូវដឹកនាំដោយមេឃុំ ចៅសង្កាត់ និង[illegible]ទៀតជាគណនេយ្យករឃុំ សង្កាត់ ទេសរតនាគារខេត្ត ក្រុង ។ សេចក្តី[illegible]

២- ដំណើរការលក់ដូរ ឬផ្ទេរត្រូវធានាអោយមានតម្លាភាព និង[illegible]

៣-ក្នុងការលក់ដូរ ឬផ្ទេរ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសំរេចផ្អែកតាម[illegible]ចំពោះកិច្ច

៤- ចំនួនទឹកប្រាក់បានមកពីការលក់ទ្រព្យសម្បត្តិត្រូវរក្សាទុកក្នុងគណនីរបស់ឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុង ។

### មាត្រា ៥៤.-

ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ដែលបានមកពី អំណោយត្រូវគោរពទៅតាមល័ក្ខខ័ណ្ឌដែលបានព្រមព្រៀងរវាងម្ចាស់អំណោយនិងឃុំ សង្កាត់ ។

ក្នុងករណីអំណោយគ្មានល័ក្ខខ័ណ្ឌពីម្ចាស់អំណោយ ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា ៥៣នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៧

## សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ឃុំ សង្កាត់

### មាត្រា ៥៥.-

មេឃុំ ចៅសង្កាត់ត្រូវធានាថាយន្តការត្រួតពិនិត្យផ្ទៃក្នុងដែលមានក្នុងប្រព័ន្ធគ្រប់គ្រង ត្រូវបានអនុវត្តដើម្បីសំរេចអោយបានតាមគោលដៅដូចខាងក្រោម:

- ធនធានត្រូវបានប្រើប្រាស់ស្របតាមថវិកាដែលបានអនុម័តព្រមទាំងស្របតាម ច្បាប់ និង បទបញ្ជាជាធរមាន
- ធនធានត្រូវបានទុកដាក់គត់មត់ មិនបាត់បង់ និងមិនប្រើប្រាស់ខុសគោលការណ៍
- ទិន្នន័យហិរញ្ញវត្ថុពិតប្រាកដត្រូវបានរៀបចំ និង លាតត្រដាងក្នុងរបាយការណ៍ ។

### មាត្រា ៥៦.-

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ជាកម្មវត្ថុសំរាប់សវនកម្មរបស់ស្ថាប័នមានសមត្ថកិច្ច ។

គោលបំណងនៃសវនកម្មគឺសំដៅធានាភាពជាក់លាក់ ត្រឹមត្រូវនៃពត៌មានហិរញ្ញវត្ថុ វាយតំលៃការអនុវត្តន៍ថវិការបស់ឃុំ សង្កាត់ ប្រព័ន្ធគ្រប់គ្រង និង នីតិវិធី ។ របាយការណ៍សវនកម្មដែលមានរួមបញ្ចូលនូវមតិយោបល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយជាសាធារណៈ ។

### មាត្រា ៥៧.-

គណនី និង ប្រតិបត្តិការរបស់ឃុំ សង្កាត់អាចត្រូវធ្វើសវនកម្មដោយស្ថាប័នជាតិ ឬដោយសវនករឯករាជ្យមិនមែនរដ្ឋាភិបាល តាមសំណូមពររបស់ម្ចាស់ជំនួយក្រៅប្រទេស ដែលផ្តល់ហិរញ្ញប្បទានដល់ឃុំ សង្កាត់ ។

### មាត្រា ៥៨.-

អភិបាលខេត្ត ក្រុងត្រូវធានាថាសវនកម្មដែលមានលក្ខណៈជាការពិគ្រោះយោបល់ ធ្វើឡើងអោយឯករាជ្យភាព ព្រមទាំងជំនួយបច្ចេកទេស និងមានលក្ខណៈជាការកសាងសមត្ថភាពខាងការគ្រប់គ្រង ហិរញ្ញវត្ថុ និង កិច្ចប្រតិបត្តិការ ត្រូវបានផ្តល់អោយឃុំ

ដល់ឃុំ សង្កាត់ទៀងទាត់ជាប្រចាំ ។

មាត្រា ៥៩.-

ប្រជាពលរដ្ឋមានសិទ្ធិពេញលេញក្នុងការពិនិត្យ តាមដានការអនុវត្តន៍របស់ ក្រុមប្រឹក្សា និង រដ្ឋបាលឃុំ សង្កាត់ ។ មេឃុំ ចៅសង្កាត់ត្រូវធានាថា:

១- រាល់ពត៌មានស្តីពីសកម្មភាព និងគណនីរបស់ឃុំ សង្កាត់ត្រូវបានផ្សព្វផ្សាយជាសាធារណៈ

២- ការទទួលមតិសាធារណៈនិងការពិគ្រោះយោបល់ត្រូវបានប្រព្រឹត្តទៅក្នុងដំណើរការរៀបចំថវិកា

៣- ប្រជាពលរដ្ឋត្រូវបានទទួលការលើកទឹកចិត្ត និង អញ្ជើញអោយចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ជំពូកទី ៨

## ទោសប្បញ្ញត្តិ

មាត្រា ៦០.-

មេឃុំ ចៅសង្កាត់ ក្នុងឋានៈជាអាណាប័ក គណនេយ្យករឃុំ សង្កាត់ និងបុគ្គលទាំងឡាយដែលចូលរួមនៅក្នុងដំណើរការអនុវត្តន៍ថវិកាត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរាល់សកម្មភាពរំលោភទៅលើវិន័យថវិកា ដូចខាងក្រោម:

១- ការសន្យាចំណាយ លើសឥណទានថវិកាដែលបានទទួលការអនុញ្ញាត

២- រាល់អំពើដែលជាកម្មវត្ថុសំរាប់បង្កើនទឹកប្រាក់ឥណទានថវិកាដែលបានទទួលការអនុញ្ញាតដោយធនធានពិសេស ក្រៅពីករណីដែលបានកំណត់ដោយច្បាប់និងបទបញ្ញាជាធរមាន

៣- រាល់កំហុសធ្ងន់ធ្ងរដែលនាំអោយមានការខាតបង់ប្រាក់កាសដល់ហិរញ្ញវត្ថុ ឬទ្រព្យសម្បត្តិ របស់ឃុំ សង្កាត់ ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

មាត្រា ៦១.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំស្តីពីការអនុវត្តន៍ជាក់ស្តែង រាល់កិច្ចការទាំងឡាយ ដូចមានចែងនៅក្នុងជំពូកទី២ ដល់ជំពូកទី៧ នៃអនុក្រឹត្យនេះ ។

មាត្រា ៦២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត ក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី

ស ខេង យុ ហុកគ្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*<u>កន្លែងទទួល</u>*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២១៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
# រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីគោលការណ៍ យន្តការ និងនីតិវិធីសម្រាប់ការពិគ្រោះយោបល់ក្នុងការរៀបចំការគ្រប់គ្រងនិងការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានកំណត់ត្រង់មាត្រា៣៨និងមាត្រា៣៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២.-**

រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអនុក្រឹត្យនេះ សំដៅត្រឹមតែរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមិនត្រូវអនុវត្តចំពោះការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ លើកលែងតែសកម្មភាពមួយចំនួនដែលទាក់ទងនឹងការចូលរួមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍក្រុង ស្រុក ខណ្ឌ។

ផែនការអភិវឌ្ឍនិងកម្មវិនិយោគរបស់ខណ្ឌ សង្កាត់ ត្រូវដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់រាជធានីភ្នំពេញ។

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់សង្កាត់ក្នុងក្រុង ត្រូវដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ក្រុង។

**មាត្រា ៤.-**

ផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើប្រាស់ធ្វើជាមូលដ្ឋានយុទ្ធសាស្ត្រសម្រាប់ណែនាំរាល់ការធ្វើសេចក្តីសម្រេចក្នុងការងារអភិវឌ្ឍ ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលនឹងត្រូវទទួលហិរញ្ញប្បទានក្រោមក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងធនធាន ថវិកាពីប្រភពនានាតាមលទ្ធភាពជាក់ស្តែង។ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២

## គោលការណ៍រួម

## នៃការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

## របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៥.-**

ការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រព្រឹត្តទៅតាមគោលការណ៍រួម ដូចខាងក្រោម ÷

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាពនិងសុខដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពសេដ្ឋកិច្ចនិងសង្គម
- ការធានាចីរភាពធនធានធម្មជាតិនិងបរិស្ថាន
- ការធានាសមធម៌។

## ជំពូកទី៣
## យន្តការនិងនីតិវិធីក្នុងការកសាងនិងអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**មាត្រា ៦.-**

ក្រុមប្រឹក្សាទទួលខុសត្រូវ ៖

- ណែនាំគោលនយោបាយទូទៅសម្រាប់រៀបចំខ្លឹមសារផែនការអភិវឌ្ឍ រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយរក្សាសង្គតិភាពជាមួយក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំនិងធនធានថវិកាពីប្រភពនានាតាមលទ្ធភាពជាក់ស្តែង
- ពិនិត្យនិងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍនៅឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន និងកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំ
- ពិនិត្យនិងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍក្នុងករណីចាំបាច់
- ផ្តល់សុពលភាពដល់លទ្ធផលត្រួតពិនិត្យនិងវាយតម្លៃអំពីការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលរាយការណ៍ដោយគណៈអភិបាល។

**មាត្រា ៧.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សា ទទួលខុសត្រូវ ៖

- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

- ពិនិត្យនិងជូនយោបល់ទៅក្រុមប្រឹក្សា មុនធ្វើការអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យនិងជូនយោបល់ទៅក្រុមប្រឹក្សាលើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

**មាត្រា ៨.-**

គណៈអភិបាល ទទួលខុសត្រូវ ÷

- ដឹកនាំការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំនៅថ្នាក់រដ្ឋបាលខ្លួន ស្របតាមការណែនាំពីក្រុមប្រឹក្សា ដូចបានកំណត់ក្នុងមាត្រា៦ខាងលើ ដោយធានាលក្ខណៈសង្គតិភាពរវាងខ្លឹមសាររបស់ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាមួយនឹងផែនការនិងគោលការណ៍ជាធរមាននានារបស់ជាតិ របស់រដ្ឋបាលថ្នាក់លើ និងផ្តោះទៅរកការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ
- ដឹកនាំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ចាត់ចែងអនុវត្តនិងតាមដានពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រាយការណ៍ជូនគ្រប់អង្គប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាមួយនឹងអនុសាសន៍ចាំបាច់ សម្រាប់លើកកម្ពស់ការអនុវត្តផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សារួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យរបស់ ÷
    - ក្រុមប្រឹក្សារួមគ្នា
    - ប្រភេទក្រុមប្រឹក្សាផ្សេងៗ
    - ក្រសួង ស្ថាប័នឬអង្គភាពនានារបស់រាជរដ្ឋាភិបាល
    - ដៃគូពាក់ព័ន្ធនានា
- ធានាឱ្យមានអន្តរាគមន៍រហ័សក្នុងការដោះស្រាយការលំបាកឬបញ្ហានានាដែលកើតមានឡើងដោយថាហេតុក្នុងអំឡុងពេលអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

**មាត្រា ៩.-**

តាមការឯកភាពពីក្រុមប្រឹក្សានិងដោយមានការគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ខ្លួន។ ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ ត្រូវមានសមាសភាពយ៉ាងតិច ÷

- អភិបាលរាជធានី ខេត្ត ប្រធាន

- អភិបាលរងរាជធានី ខេត្ត០១រូប | អនុប្រធាន
- នាយករដ្ឋបាលសាលារាជធានី ខេត្ត | សមាជិក
- ប្រធានមន្ទីរផែនការរាជធានី ខេត្ត | សមាជិកអចិន្ត្រៃយ៍
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត | សមាជិក
- នាយកទីចាត់ការហិរញ្ញវត្ថុក្រុមប្រឹក្សារាជធានី ខេត្ត | សមាជិក
- ប្រធានឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ | សមាជិក
- ប្រធានឬតំណាងមន្ទីរនិងអង្គភាពជំនាញនានានៅរាជធានី ខេត្ត | សមាជិក
- នាយកឬតំណាងទីចាត់ការលំណុះសាលារាជធានី ខេត្ត | សមាជិក

**មាត្រា ១០.-**

តាមការឯកភាពពីក្រុមប្រឹក្សានិងដោយមានការគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ខ្លួន។ ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ ត្រូវមានសមាសភាពយ៉ាងតិច ÷

- អភិបាលក្រុង ស្រុក ខណ្ឌ | ប្រធាន
- អភិបាលរងក្រុង ស្រុក ខណ្ឌ០១រូប | អនុប្រធាន
- នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | សមាជិក
- ប្រធានការិយាល័យផែនការ ស្ថិតិក្រុង ស្រុក ខណ្ឌ | សមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ | សមាជិក
- ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុសាលាក្រុង ស្រុក ខណ្ឌ | សមាជិក
- ប្រធានឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ | សមាជិក
- តំណាងអង្គភាពគាំទ្រឃុំ សង្កាត់ | សមាជិក
- ប្រធានឬតំណាងការិយាល័យនិងអង្គភាពជំនាញនានានៅក្រុង ស្រុក ខណ្ឌ | សមាជិក
- ប្រធានឬតំណាងការិយាល័យលំណុះសាលាក្រុង ស្រុក ខណ្ឌ | សមាជិក

**មាត្រា ១១.-**

ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ មានភារកិច្ច ÷

- រៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលជូនគណៈអភិបាល
- ជួយគណៈអភិបាល ធ្វើការរៀបចំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយផ្អែកលើលទ្ធផលរបស់សិក្ខាសាលានិងកិច្ចប្រជុំពិគ្រោះយោបល់នានា។

# ជំពូកទី៤
# នីតិវិធី
## ការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**មាត្រា ១២.-**

ក្នុងឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន ក្រុមប្រឹក្សាត្រូវកសាងផែនការអភិវឌ្ឍដែលមានសុពលភាពរយៈពេលប្រាំឆ្នាំ និងរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលលើកទី១ សម្រាប់ថ្នាក់រដ្ឋបាលខ្លួន។ កម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

**មាត្រា ១៣.-**

ក្នុងការរៀបចំនិងអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវមានការពិគ្រោះយោបល់ជាមួយនឹង ÷

- ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រភេទក្រុមប្រឹក្សាដទៃទៀតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- និងអ្នកពាក់ព័ន្ធនានា។

**មាត្រា ១៤.-**

វិធីសាស្ត្រសម្រាប់ធ្វើការប្រជុំពិគ្រោះយោបល់អំពីការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវកំណត់ដោយក្រុមប្រឹក្សា តាមតម្រូវការចាំបាច់។

រាល់សេចក្តីសម្រេចរបស់កិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាធាតុចូលសម្រាប់ក្រុមប្រឹក្សាធ្វើការពិនិត្យនិងអនុម័តលើសេចក្តីព្រាង។

**មាត្រា ១៥.-**

ក្នុងកិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ត្រូវមានការចូលរួមពីប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ពីក្រុង ស្រុក ខណ្ឌនៅក្នុងរាជធានី ខេត្ត។

**មាត្រា ១៦.-**

ក្នុងកិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌ ត្រូវមានការចូលរួមពីមេឃុំ ចៅសង្កាត់ និងអ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំ សង្កាត់ ពីឃុំ សង្កាត់នីមួយៗនៅក្នុងក្រុង ស្រុក ខណ្ឌ។

# ជំពូកទី៥
## ការអនុម័ត ការចាត់ចែងអនុវត្ត
## ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**មាត្រា ១៧.-**

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវអនុម័តដោយសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សា។

**មាត្រា ១៨.-**

សេចក្តីស្នើកែសម្រួលលើផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវអនុម័តដោយសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សា។

**មាត្រា ១៩.-**

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវតម្កល់ទុកជាឯកសារមួយច្បាប់នៅសាលារាជធានី ខេត្ត មួយច្បាប់នៅមន្ទីរផែនការរាជធានី ខេត្ត មួយច្បាប់នៅក្រសួងមហាផ្ទៃ មួយច្បាប់នៅក្រសួងផែនការ។

**មាត្រា ២០.-**

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវតម្កល់ទុកជាឯកសារមួយច្បាប់នៅសាលារាជធានី ខេត្ត មួយច្បាប់នៅមន្ទីរផែនការរាជធានី ខេត្ត មួយច្បាប់នៅសាលាក្រុង ស្រុក ខណ្ឌ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈនិងបន្ទាន់នូវផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលបន្ទាប់ពីអនុម័តរួច ជូនសាធារណជន និងភាគីពាក់ព័ន្ធបានដឹង។

**មាត្រា ២២.-**

ក្រុមប្រឹក្សាត្រូវណែនាំឱ្យគណៈអភិបាលចាត់ចែងអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័ត ដោយមានតម្លាភាព មានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធភាព។

**មាត្រា ២៣.-**

ករណីក្រុមប្រឹក្សាត្រូវបានរំលាយមុនអាណត្តិ ក្រុមប្រឹក្សាថ្មីដែលទទួលការងារបន្តអាចទទួលយកផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលមុនទាំងស្រុងឬអាចរៀបចំកែសម្រួលផែនការអភិវឌ្ឍសម្រាប់រយៈពេលដែលនៅសល់របស់អាណត្តិ។

**មាត្រា ២៤.-**

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល មានសុពលភាពរហូតដល់មានផែនការអភិវឌ្ឍថ្មី និងកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្មីដែលបានអនុម័តដោយក្រុមប្រឹក្សាអាណត្តិបន្ទាប់។

## ជំពូកទី៦
## ការតាមដាន វាយតម្លៃ និងរបាយការណ៍

**មាត្រា ២៥.-**

ក្រុមប្រឹក្សាត្រូវចាត់ចែងឱ្យមានការតាមដានពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងបណ្តាសកម្មភាពពាក់ព័ន្ធដែលអនុវត្តដោយស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិនានា និងផ្នែកឯកជននៅក្នុងដែនដីរដ្ឋបាលរបស់ខ្លួន។

**មាត្រា ២៦.-**

នៅចុងឆ្នាំសារពើពន្ធនីមួយៗ គណៈអភិបាលត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ជូនក្រុមប្រឹក្សាពិនិត្យ។ របាយការណ៍ប្រចាំឆ្នាំត្រូវមាន ÷

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តក្នុងឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម។

**មាត្រា ២៧.-**

ក្រុមប្រឹក្សាត្រូវអនុម័តនិងផ្ញើជូនទៅគ្រប់ថ្នាក់ពាក់ព័ន្ធមានសមត្ថកិច្ចនូវរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្នុងអំឡុងពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗ។

**មាត្រា ២៨.-**

សេចក្តីណែនាំលំអិតសម្រាប់អនុវត្តការកសាងនិងការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្នុងអនុក្រឹត្យនេះ ត្រូវកំណត់និងអាចធ្វើបច្ចុប្បន្នភាពតាមតម្រូវការជាក់ស្តែង ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃនិងក្រសួងផែនការ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ២៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៥ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

គណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

*.ក្រសួងព្រះបរមរាជវាំង*
*.អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*.អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*.អគ្គលេខាធិការរាជរដ្ឋាភិបាល*
*.ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*.ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*.ដូចមាត្រា៣០*
*.រាជកិច្ច*
*.ឯកសារ កាលប្បវត្តិ*

# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងរដ្ឋបាល

## រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នា សម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបាន ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

## ជំពូកទី ១

## អំពីបទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ២.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**មាត្រា ៣.-**

ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លើកលែងតែបញ្ញត្តិទាំងឡាយណាដែលបានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.-**

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ចែកជាខណ្ឌ ។

ខណ្ឌ ចែកជាសង្កាត់ ។

**មាត្រា ៥.-**

ខេត្ត ចែកជាក្រុង និងជាស្រុក ។

ក្រុង ចែកជាសង្កាត់ ។

ស្រុក ចែកជាឃុំ និងជាសង្កាត់ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះខេត្ត ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការកំណត់ព្រំប្រទល់រាជធានីភ្នំពេញ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៨.-**

ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន ។

**មាត្រា ៩.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលនៃនីតិសាធារណៈ ។

មាត្រា ១០.-

នីតិបុគ្គលនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយជាតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

មាត្រា ១១.-

នីតិបុគ្គលនីមួយៗត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

មាត្រា ១២.-

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន :

-ភាពជាតំណាងសាធារណៈ

-ស្វ័យភាពរបស់មូលដ្ឋាន

-ការពិគ្រោះយោបល់ និងការចូលរួម

-ការឆ្លើយតប និងគណនេយ្យភាព

-ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

-ការលើកស្ទួយសមធម៌

-តម្លាភាព និងសុចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

**មាត្រា ១៣.–**

នីតិបុគ្គលទទួលសិទ្ធិអំណាចរបស់ខ្លួន ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដទៃទៀត ដែលស្របនឹងច្បាប់នេះ ។

## ជំពូកទី ២
## អំពីក្រុមប្រឹក្សា

### ផ្នែកទី ១
### ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ១៤.–**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា "ក្រុមប្រឹក្សា" ។

**មាត្រា ១៥.–**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១៦._**

ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១៧._**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ។

ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា ។

ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

**មាត្រា ១៨._**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រនិងកត្តាភូមិសាស្ត្រ ដូចខាងក្រោម :

-ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន(០៩)រូប ដល់ម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំ(១៥)រូប

-ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំបួន(១៩)រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យ ចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបដូចគ្នានៃក្រុមប្រឹក្សាអាណត្តិចាស់ ។

**មាត្រា ១៩.-**

ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២០.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២១.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិ ដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត

- មានអាយុយ៉ាងតិចម្ភៃប្រាំ(២៥)ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោត

- មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**មាត្រា ២២.-**

សមាជិកក្រុមប្រឹក្សាម្នាក់ ត្រូវបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សាក្នុងករណីណាមួយ ដូចខាងក្រោម :

- សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌ សម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

- សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សា

- សាមីខ្លួនទទួលមរណភាព

- សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នា ចាប់ពីពីរ(០២)ដងឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត

-សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬ បទបញ្ជាផ្ទៃក្នុង ឬ ក្រមសីលធម៌របស់ក្រុមប្រឹក្សា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេច និងប្រកាសពីការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ក្នុងករណីដូចខាងលើនេះ ។

## មាត្រា ២៣.–

នៅពេលដែលមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ ពីក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសក្នុងរយៈពេលយ៉ាងយូរដប់បួន(១៤)ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## មាត្រា ២៤.–

ប្រសិនបើក្រុមប្រឹក្សាណាមួយអនុវត្តផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សានោះឱ្យគោរព និងអនុវត្តបទប្បញ្ញត្តិទាំងនោះ នៅក្នុងអំឡុងពេលជាក់លាក់ និងសមហេតុផល ។

ក្នុងករណីក្រុមប្រឹក្សានោះនៅតែមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលត្រូវរំសាយក្រុមប្រឹក្សានោះដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## មាត្រា ២៥.–

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "គ.ជ.ប" ត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សា ក្នុងករណីណាមួយដូចខាងក្រោម :

-ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មីដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីររយសែសិប (២៤០) ថ្ងៃ

-ក្រុមប្រឹក្សាដែលត្រូវរំសាយតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០) ថ្ងៃ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះ ។

**មាត្រា ២៦.–**

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនលើសពីមួយរយប៉ែតសិប(១៨០)ថ្ងៃ ។

**មាត្រា ២៧.–**

ក្នុងករណីដែលមានក្រុមប្រឹក្សាណាមួយត្រូវរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់វិធានការដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

**មាត្រា ២៨.–**

សមាជិកក្រុមប្រឹក្សានៅក្នុងមុខតំណែង ត្រូវទទួលប្រាក់ឧបត្ថម្ភ ដែលត្រូវបើកចេញពីគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានោះ ។

ប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២

## តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

**មាត្រា ២៩.–**

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ ។

**មាត្រា ៣០.–**

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងនីតិប្រតិបត្តិ ។

**មាត្រា ៣១.–**

ក្រុមប្រឹក្សា ត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្ដីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្ដីសម្រេចនោះត្រូវបានអនុវត្ត ។

**មាត្រា ៣២.–**

ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីកា ស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ២ នៃច្បាប់នេះ ។

**មាត្រា ៣៣.–**

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយធ្វើសេចក្ដីសម្រេច នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ។

**មាត្រា ៣៤.–**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្ដីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្ដល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាលនិងអភិបាល ។

**មាត្រា ៣៥.–**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា ។

**មាត្រា ៣៦.–**

រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្ដីសម្រេច ឬ ដីកាតាមការចាំបាច់ [illegible]តទិន[illegible]នឹង :

-ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ

-មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥) ឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

-បញ្ហាហិរញ្ញវត្ថុផ្សេងទៀត

-ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

-ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ

-កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ ។

**មាត្រា ៣៧.–**

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេលប្រាំ(៥)ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ ។

**មាត្រា ៣៨.–**

ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ :

-ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា ។

នីតិវិធីនៃការពិគ្រោះយោបល់នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍរបស់រដ្ឋ-បាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៣៩.–**

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍ ដែលរួមមាន :

-ចក្ខុវិស័យរបស់ក្រុមប្រឹក្សា ដោយបង្ហាញពីគោលដៅ និងគោលបំណងសម្រាប់អភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

-ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសំខាន់ៗរួមមាន :

+ តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ

+ សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់នានា

+ ការកាត់បន្ថយភាពក្រីក្រ

+ តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ រួមទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

-ក្របខ័ណ្ឌអភិវឌ្ឍដែលត្រូវចែងអំពីគោលការណ៍ណែនាំជាមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នោះ

-ផែនការគ្រប់គ្រងគ្រោះមហន្តរាយ

-ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងផែនការអភិវឌ្ឍមូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរ (១២)ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី (៣)ឆ្នាំចាប់ពីពេលរៀបចំផែនការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

-យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍ ដើម្បីធានាឱ្យមានតម្លាភាពនិងគណនេយ្យភាព ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ស្ថានការបំពេញការងារសំខាន់ៗ និងគោលដៅនានាទាក់ទិននឹងអាទិភាព និងទិសដៅអភិវឌ្ឍនីមួយៗដូចមានចែងក្នុងផែនការអភិវឌ្ឍ

ក្រុមប្រឹក្សាត្រូវកំណត់ឱ្យដាច់ពីគ្នានៅក្នុងផែនការអភិវឌ្ឍ និងថវិកានូវមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ។

បែបបទ នីតិវិធីជាក់ស្តែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៤០.-**

ក្រុមប្រឹក្សា ត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

-ក្រុមប្រឹក្សាប្រភេទរួមគ្នា

-ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត

-ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា។

**មាត្រា ៤១.-**

ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍបន្ទាប់ពីបានអនុម័តរួចហើយភ្លាម ។

សាធារណជន អាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យរបស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃ ឬ អាចស្នើសុំជាវឯកសារផែនការនេះពីក្រុមប្រឹក្សា ដោយគិតត្រឹមតម្លៃដើម ។

**មាត្រា ៤២.-**

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញផលការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

-តម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំសម្រាប់ទទួលមុខងារ ភារកិច្ច និងធនធានថ្មីៗ

-សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់

-ការកាត់បន្ថយភាពក្រីក្រ

-តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ និងកុមារ ក្រុមជនងាយរងគ្រោះដោយរួមបញ្ចូលទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

**មាត្រា ៤៣.-**

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុ ឱ្យមានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។

**មាត្រា ៤៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ត្រូវមានថវិកាផ្ទាល់របស់ខ្លួន ដែលហៅកាត់ថាថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ។

ខណ្ឌ និងសង្កាត់ចំណុះរាជធានី ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់រាជធានី ។

សង្កាត់ចំណុះក្រុង ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់ក្រុង ។

ក្រុមប្រឹក្សាត្រូវអនុម័តលើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមនីតិវិធីនិងប្រតិទិននៃការកសាងថវិការដ្ឋជារៀងរាល់ឆ្នាំ ។

ក្រុមប្រឹក្សាត្រូវអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។

ការគ្រប់គ្រងនិងការអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ ត្រូវផ្អែកតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ថវិកាត្រូវរៀបចំឡើងដោយគោរពតាមគោលការណ៍សំខាន់ៗទាំងអស់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL